ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jan-2012, 15:26
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១១ ខែមករា ឆ្នាំ២០១២**

**ម៉ោង ០៩: ០៩នាទី**

**សវនាការលើកទី១៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា

*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី

*(Ms. Faiza ZOUAKRI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក ឌេល លីសាក់ *(Mr.Dale LYSAK)*

លោក ច័ន្ទ តារាស្មី

លោក សេង ប៊ុនឃាង

លោក វេង ហ៊ត់

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់

*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ូនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោក ហុង គឹមសួន

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

លោកស្រី ស៊ីន សុវ៉ន

លោក សំ សុគង់

លោក វ៉េន ពៅ

លោក គឹម ម៉េងឃី

លោក ឡោ ជុនធី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោក បាណាបេ ណេគ្វី | បារាំង |
| លោក នួន ជា | ខ្មែរ |
| លោក ក្លាន ទ្រឹត | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅជនជាប់ចោទ នួន ជា**

សួរដោយលោក ខេល លីសាក់ ផ្តើមពី ........................................................................ ទំព័រ ០៧

**ការសួរសំណួរទៅសាក្សីដើមបណ្តឹងរដ្ឋប្បវេណី ក្លាន វិុត** (TCP-185)

សួរដោយលោក សុន អរុណ ផ្តើមពី .........................................................................ទំព័រ ៣៨

សួរដោយលោក អាង ឧត្តម ផ្តើមពី........................................................................ ទំព័រ ៤៨

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៩:១៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ នៅព្រឹកនេះ ដំណើរការសវនាការពិភាក្សាដេញដោលសួរចម្លើយជនជាប់ចោទ នួន ជា នឹងបន្តដោយសហព្រះរាជអាជ្ញា។ ប៉ុន្តែមុននឹងបន្ត និងប្រគល់វេទិកាទៅសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមរំឭក និងជម្រាបជូនទជនជាប់ចោទ និងមេធាវីការពារក្តីរបស់ជនជាប់ចោទបានជ្រាបថា ប្រសិនបើជនជាប់ចោទចង់ស្នើសុំការដកខ្លួនពីបន្ទប់សវនាការនៅពេលដែលនីតិវិធីកំពុងតែដំណើរការនោះ ក្រុមមេធាវីការពារក្តីដែលពាក់ព័ន្ធពុំគួរបង្អាក់សវនាការដើម្បីស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះឡើយ ពោលគឺត្រូវរង់ចាំដល់អង្គជំនុំជម្រះផ្អាកសវនាការ ឬនៅពេលណាមួយដែលសមស្រប។ ជនជាប់ចោទត្រូវបន្តនៅក្នុងសវនាការទាល់តែមានការអនុញ្ញាតពីអង្គជំនុំជម្រះ។ មេធាវីការពារក្តីមិនគួរស្នើសុំការអនុញ្ញាតនៅពេលដែលអង្គជំនុំជម្រះ ឬភាគីកំពុងតែតាំងសំណួរទៅបុគ្គលណាមួយ ឬនៅពេលដែលភាគីកំពុងថ្លែងមកកាន់អង្គជំនុំជម្រះនោះឡើយលើកលែងតែក្នុងករណីបន្ទាន់ ចាំបាច់បំផុតប៉ុណ្ណោះ។

ដូច្នេះ សូមរំឭកបន្ថែមដោយសារបញ្ហានេះ អង្គជំនុំជម្រះបានណែនាំរួចហើយតាមអនុស្សរណៈចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១ ប៉ុន្តែអង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា មេធាវីការពារក្តីនៅតែមិនអាច ឬក៏មិនព្រមគោរព និងអនុវត្តតាមការណែនាំនេះ។ អង្គជំនុំជម្រះបន្ថែមទៀតថា ប្រសិនបើលោកមេធាវីនៅតែមានចេតនាធ្វើដូចកាលពីម្សិលមិញ គោលបំណងនៃការស្នើសុំនឹងមិនទទួលបានតាមសំណើឡើយ។

ជាកិច្ចបន្តអង្គជំនុំជម្រះ សូមប្រគល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរសួរដេញដោលចំពោះជនជាប់ចោទ នួន ជា ។ សូមអញ្ជើញ!

[០៩:១២:៣៥]

**លោក ផេល លីសាក់៖**

សូមអរគុណលោកប្រធាន។

ពីម្សិលមិញនៅពេលយើងសម្រាក ការសាកសួរលោក នួន ជា នៅពេលពិសាបាយថ្ងៃត្រង់ទាក់ទងទៅនឹងយថាភាពនៃឯកសារចុះ ខែកញ្ញា ១៩៧៧ ខ្ញុំចង់ជូនន្ធូវព័ត៌មានមួយជូនទៅលោក នួន ជា ឲ្យបានដឹង។ ទាក់ទងទៅនឹងទង់បដិវត្តនេះគឺថា វាមិនមែនជាបញ្ហាធម្មតាទេ វាជាឯកសារមួយដែលពាក់ព័ន្ធនឹងសុន្ទរកថាសំខាន់ៗរបស់ ប៉ុល ពត នៅរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយមុនពេលឈប់សម្រាកគឺថានៅក្នុងខែធ្នូ គឺថាសុន្ទរកថាមួយបានថ្លែងឡើងដោយវិទ្យុរបស់រដ្ឋាភិបាល ដោយបានធ្វើការរៀបរាប់និងធ្វើប្រតិចារឹក ដែលវាខុសពីសុន្ទករថាផងទៃៗទៀតនៅពេលដែលគេធ្វើការផ្សព្វផ្សាយគឺថាត្រូវធ្វើការកែតម្រូវឡើងវិញ។ ប៉ុន្តែសុន្ទរកថានេះ គឺថាជាសុន្ទរកថាមួយដែល ប៉ុល ពត បានថ្លែងក្នុងរយៈពេលដល់ទៅប្រាំម៉ោងឯណោះ។ ឯកសារនៅក្នុងសំណុំរឿងគឺថាបានឆ្លុះបញ្ចាំងអំពីការផ្សព្វផ្សាយនេះ ហើយគឺវាទាក់ទងទៅនឹងបញ្ហាយថាភាពនៃឯកសារនេះ។

ដូច្នេះ ខ្ញុំសូមជូនឯកសារនេះជូនអង្គជំនុំជម្រះ ដាក់ជូនអង្គជំនុំជម្រះ។ ការផ្សព្វផ្សាយភ្លាមៗគឺដែលត្រូវបានរាយការណ៍នៅក្នុងឯកសារ D26 ចុះឆ្នាំ១៩៧៧ នៅក្នុងឯក-- 00689 ខ្ញុំសូមអាននៅផ្នែកទីមួយនៃសុន្ទរកថារបស់ ប៉ុល ពត ដែលមានសារៈសំខាន់បំផុតដែលទាក់ទងទៅនឹងការពិភាក្សាពីម្សិលមិញ។

[០៩:១៥:៥៥]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមធ្វើការជំទាស់។ មេធាវីការពារក្ដី គឺថាអ្វីដែលគាត់យល់ថា មានសារៈសំខាន់។ ខ្ញុំសូមជំទាស់។ គាត់ត្រូវការយកសាក្សី អ្នកណាដែលត្រូវបង្ហាញភស្តុតាងនេះឡើង។ គាត់មិនត្រូវការធ្វើសក្ខីកម្មទាក់ទងទៅនឹងចំណុចនេះទេ ថាតើអង្គជំនុំជម្រះទទួលយកឯកសារនេះ ឬក៏អត់នោះ? នោះគឺជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសម្រាប់សប្ដាហ៍ក្រោយនេះ។

**លោក ឌេល លីសាក់៖**

លោកប្រធាននេះមិនមែនជា--

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១៦:០១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញាបន្តកិច្ចការរបស់ខ្លួន។ ហើយអង្គជម្រះសូមរំឭកដល់មេធាវី

ការពារក្តីថា មេធាវីការពារក្តីមិនគប្បីប្រើប្រាស់នូវសិទ្ធិរបស់ខ្លួនក្នុងការជំទាស់នៅក្នុងអំឡុងពេល ដែលភាគីខាងសហព្រះរាជអាជ្ញាកំពុងតែធ្វើការបទបង្ហាញនោះឡើយ។ សូមស្តាប់ភាគីម្ខាងទៀត ឲ្យធ្វើការបញ្ហានេះឲ្យអស់ចប់សព្វគ្រប់ ប្រសិនបើសុំធ្វើការជំទាស់នោះ ដោយមានការអនុញ្ញាតពីអង្គជម្រះគឺអង្គជម្រះនឹងអនុញ្ញាត។

[០៩:១៧:១៣]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

ដូចដែលខ្ញុំជម្រាបជូន ការចាប់ផ្តើមនៃសុន្ទរកថា ដែលផ្សាយតាមវិទ្យុផ្សាយសំឡេងអន្តរជាតិគឺថាសេវាផ្សព្វផ្សាយក្នុងស្រុក ក្នុងទីក្រុងភ្នំពេញនៅក្នុងថ្ងៃទី២០-- ពីថ្ងៃទី២៣ ទៅដល់ថ្ងៃទី២៧។ នៅថ្ងៃទី២៨ ខែកញ្ញា រហូតដល់ទៅដល់ថ្ងៃទី-- តាមរលកធាតុអាកាស 0430GMT ដែលត្រូវបានរាយការណ៍នៅថ្ងៃទី២៧ ខែកញ្ញា នៅក្នុងមហាសន្និបាតប្រារព្ធទិវាជ័យជម្នះនៃកម្ពុជាប្រជាធិបតេយ្យ។ យោងទៅតាមអ្នកផ្សព្វផ្សាយព័ត៌មានគឺថារាល់កម្មាភិបាលទាំងអស់របស់កម្ពុជាប្រជាធិបតេយ្យនឹងដែលមានតំណាងមកពីជាងមួយម៉ឺននាក់ និងមកពីអង្គភាពផ្សេងៗក្រសួងដទៃទៀតនៅក្នុងទីក្រុងភ្នំពេញ។

[០៩:១៨:២១]

គណៈមជ្ឈិមលេខាធិការបក្ស ប៉ុល ពត គឺបានថ្លែងសុន្ទរកថា រយៈពេល៥ម៉ោង តាមរយៈការផ្សព្វផ្សាយនេះគឺថា មហាជនត្រូវបានបញ្ចប់នូវម៉ោងដប់ប្រាំពីរនៅក្នុងប្រទេសកម្ពុជា ដោយមានការចូលអបអរសាទរយ៉ាងក្រៃលែងទៅនឹងជ័យជម្នះរបស់កម្ពុជាប្រជាធិបតេយ្យ។ ហើយរបាយការណ៍សុន្ទរកថានោះក៏ត្រូវបញ្ចប់នៅវេលាម៉ោង 045GMT ក្នុងប្រទេសកម្ពុជា។ ហើយសុន្ទរកថានេះមិនទាន់បានបកប្រែនៅឡើយទេ។ ហើយជាការពិតណាស់លោកប្រធាន មានឯកសារនៃសុន្ទរកថា នៅក្នុងសំណុំរឿងជាច្រើនរួមទាំងឯកសារ ដែលត្រូវបានផ្សព្វផ្សាយនៅសហរដ្ឋអាមេរិក ដោយយោងទៅលើការ វិទ្យុផ្សាយសំឡេងព័ត៌មានអន្តរជាតិនេះ។

[០៩:១៩:១៨]

ហើយគឺថា ឯកសារ IS4.0 ហើយនៅក្នុងឯកសារនេះផងដែរ ក៏មាននៅក្នុងសំណុំរឿងឯកសារ D366/7.1.459 ហើយនេះគឺជាបញ្ហាមួយដែលទាក់ទងទៅនឹងយថាភាព ហើយបានខ្ញុំសូមបង្ហាញថា ហេតុនេះឯងបានជាសហព្រះរាជអាជ្ញា សម្រេចថា យកឯកសារនេះយកមកបង្ហាញ។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធានខ្ញុំសូមបញ្ជាក់ថា ដោយសារគាត់បានបញ្ចប់នូវសេចក្តីថ្លែងរបស់គាត់នេះហើយ សហព្រះរាជអាជ្ញារង។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

កាលម្សិលមិញនោះ បើតាមខ្ញុំចាំអង្គជំនុំជម្រះសម្រេចថា សហព្រះរាជអាជ្ញាអាចនឹងបន្តដោយប្រើប្រាស់ឯកសារ និងដាក់ចេញនូវសំណួរផ្សេងៗដើម្បីសួរជនជាប់ចោទ។ តាមដែលខ្ញុំដឹងគឺថាសប្តាហ៍ក្រោយគឺថា យើងពាក់ព័ន្ធទៅនឹងយថាភាពនៃឯកសារទាំងឡាយដែលត្រូវយកមកការដេញដោលគ្នា។ អង្គជំនុំជម្រះបានផ្តល់ពណ៌លឿងទៅឲ្យសហព្រះរាជអាជ្ញា ឥឡូវនេះគាត់បានប្រើប្រាស់ឱកាសនេះដើម្បីបង្ហាញទាំងពីយថាភាពនៃឯកសារ ដោយអះអាងថា ដោយសារឯកសារនេះត្រូវបានរាយការណ៍នៅកន្លែងណាមួយ នៅទីណាមួយ នៅពេលណាមួយ ដោយរបៀបណាមួយ ថាឯកសារនេះមានយថាភាពហើយ។

[០៩:២១:១០]

ហើយការលើកជំទាស់តវ៉ាថា ឯកសារនេះពិតជាមានយថាភាពគួរណាតែលើកទៅជំទាស់តវ៉ានៅសប្តាហ៍ក្រោយឯណោះ។ ប្រសិនជានីតិវិធីនៅក្នុងតុលាការ-- ខ្ញុំកំពុងតែគិតថា តើយើងកំពុងតែប្រើប្រាស់នីតិវិធីមួយណា? ភាគីទាំងសងខាងអាចក្រោកឈរ និងធ្វើការសាកសួរបាន ព្រោះគោលបំណងយើងដើម្បីចង់បានសក្ខីកម្ម។ សហព្រះរាជអាជ្ញាត្រូវចាប់ផ្តើមសាកសួរនូវអ្វីដែលសំខាន់ ហេតុម៉េចបានវាសំខាន់ ហើយទាំងនេះគឺជាអង្គហេតុដែលយើងមានជាភស្តុតាងរួចទៅហើយ។ ហើយការសួរសាក្សី ឬក៏សួរជនជាប់ចោទគឺថាយើង-- ដូច្នេះខ្ញុំសូមស្នើសុំថា យើងគួរណាតែមានការណែនាំឲ្យបាន គោលការណ៍ណែនាំឲ្យបានច្បាស់លាស់ ថាតើត្រូវសួរយ៉ាងម៉េច? ហើយម៉េចបានទៅជាអះអាងថាឯកសារនេះ មានយថាភាព ឬយើងក៏ត្រូវមាននីតិវិធីមួយដែលថា អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចថា ឯកសារនេះមានយថាភាពអាចគួរឲ្យទុកចិត្តបាន ហើយនិងបន្តតាំងសំណួរតទៅទៀតនោះ។

[០៩:២២:២៨]

ដោយសារខ្ញុំយល់ឃើញថា ទាក់ទងទៅនឹងភាពគួរឲ្យជឿជាក់បាន ហើយនិងទម្ងន់នៃភស្តុតាង គឺត្រូវពិភាក្សានៅពេលក្រោយ ជាពិសេសនៅពេលដែលអង្គជំនុំជម្រះបានសម្រេចរួចហើយថាគាត់អាចបន្ត និងបន្តតាំងសំណួរបានតទៅទៀត។ ខ្ញុំគិតឃើញថា ការធ្វើបែបនេះគឺថាជារឿងមួយដែលមិនមានប្រក្រតីភាពទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៣:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការលើកឡើងរបស់សហព្រះរាជអាជ្ញា ក៏ដូចជាការកត់សម្គាល់ ឬក៏មតិយោបល់របស់មេធាវីការពារក្តីលោក អៀង សារី នោះគ្រាន់តែជាការកត់សម្គាល់នូវបញ្ហាខ្លះៗតែប៉ុណ្ណោះ។ ហើយចំណែកឯវិធីសាស្ត្រ ឬក៏នីតិវិធីនៃការសួរដេញដោលរបស់ភាគីម្ខាងនោះ គឺជាវិធីសាស្ត្រ ឬក៏ជាយុត្តិសាស្ត្រក្នុងការការពារក្តី ឬក៏ការតតាំងក្តីនៅចំពោះមុខអង្គជំនុំជម្រះប៉ុណ្ណោះ។

បញ្ហានេះមិនទាន់-- ភាគីខាងសហព្រះរាជអាជ្ញាមិនទាន់បង្ហាញថា យកឯកសារនេះមកស្នើសុំដេញដោលនូវពេលនេះទេ គ្រាន់តែលើកឡើងបង្ហាញជាការបញ្ជាក់អំពីភស្តុតាង ឬឯកសារនានាដែលពាក់ព័ន្ធនឹងបញ្ហានេះ។ ហើយទំនងជានៅពេលក្រោយ យើងនឹងអាចលើកឡើងនឹងជជែកពិភាក្សានូវបញ្ហាទាំងអស់នេះ នៅពេលដែលកិច្ចពិភាក្សាដោះស្រាយបញ្ហាឯកសារ យថាភាពនៃឯកសារនេះបានប្រព្រឹត្តទៅចប់សព្វគ្រប់។

បាទអរគុណដែលនូវការកត់សម្គាល់របស់ភាគីទាំងសងខាងលើបញ្ហានេះ។ សូមប្រគល់--

សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន! ខ្ញុំមើលឃើញអង្គសវនាការបានធ្វើពីរថ្ងៃហើយកាលពីវគ្គមុនបានក៏បានយករឿងទង់បដិវត្តហ្នឹងមកនិយាយ។ កូនក្តីរបស់ខ្ញុំបានមិនទទួលឆ្លើយនឹងសំណួរទាំងអស់ហ្នឹង ដោយទាមទារយកឯកសារដើម ហើយក្នុងមួយអាទិត្យនេះទៀត មកពេលនេះទៀតតាំងពីម្សិលមិញដល់ថ្ងៃនេះនៅតែធ្វើដដែលៗទៀត។ បើសិនជាលោកប្រធានអនុញ្ញាតឲ្យខ្ញុំបាទសុំសួរទៅព្រះរាជអាជ្ញានៅពេលនេះ អនុញ្ញាតពេលវេលាឲ្យខ្ញុំបានសួរទៅព្រះរាជអាជ្ញានៅពេលនេះ

ខ្ញុំនឹងធ្វើ។ អាហ្នឹងបើសិនថាមិនមែនជាពេលវេលា ក៏ខ្ញុំបាទមិនសួរ។

[០៩:២៦:១២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតទេ។ បញ្ហាដែលលើកឡើងអម្បាញ់មិញនេះ គឺអង្គជំនុំជម្រះបានសម្រេចរួចហើយកាលពីម្សិលមិញ។ ដូច្នេះអង្គជំនុំជម្រះមិនទាន់បានកែប្រែនូវសេចក្ដីសម្រេចរបស់ខ្លួនទេ សេចក្ដីសម្រេចនូវជាធរមាន ហើយអនុវត្តចាប់ពីម្សិលមិញតទៅ។ ថ្ងៃនេះបើមានបញ្ហាអីទៀត យើងនឹងបញ្ជាក់ជំហរជាថ្មីបន្ថែមទៀតលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះដែលបានសម្រេចរួចហើយ ពីពេលនេះទៅរហូតដល់មានការសម្រេចជាថ្មី បន្ថែមលើបញ្ហាទាំងអស់ពាក់ព័ន្ធនឹងយថាភាពនៃឯកសារនេះ។

**លោក សុន អរុណ៖**

ដោយព្រះរាជអាជ្ញាលើករឿងដដែលៗមកនិយាយ បដិសេធបីដងបួនដងហើយនៅនិយាយដដែលហើយអ៊ីចឹងមានន័យថា ព្រះរាជអាជ្ញាមិនគោរពការសម្រេចរបស់តុលាការទេ។ បើអ៊ីចឹងខ្ញុំសូមគាំទ្រតុលាការថា អាហ្នឹងបន្តរឿងទៅមុខទៀត មិនមែនយករឿងដដែលមកនិយាយតទៀតទេ ចាំដល់ពេល។ សូមអរគុណ។

[០៩:២៧:២៦]

**ប្រធានអង្គជំនុំ៖**

ខ្ញុំគិតថា មេធាវី សុន អរុណ កំពុងតែបំភ្លៃនូវសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ។ សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ គឺចាត់ទុកជាឯកសារដែលមាននៅក្នុងសំណុំរឿង ជាឯកសារភស្តុតាងដែលដាក់ដេញដោលបាន។ ចំណែកឯការសម្រេចថា សម្រេចថាយ៉ាងដូចម្ដេចជាភស្តុតាង ឬមិនមែនជាភស្តុតាងជាបានការ ឬឥតបានការនោះ អង្គជំនុំជម្រះនឹងពិចារណាសម្រេចនៅចុងក្រោយនៃកិច្ចដំណើរការពិភាក្សាដេញដោលនៅក្នុងសំណុំរឿងក្ដីនេះ។

សូមពិនិត្យមើលឡើងវិញនូវសេចក្ដីសម្រេចកាលពីម្សិលមិញនៅក្នុងប្រតិចារឹកមានហើយ យើងមិនធ្វើការបញ្ជាក់បញ្ហានេះបន្ថែមទៀតទេ ពីរឿងដដែល។ លោកខំចំទាលថារឿងនេះជារឿងដដែលប៉ុន្តែគឺខ្លួនឯងទេដែលនិយាយពីរឿងដដែល។

សូមអញ្ជើញលោកសហព្រះរាជអាជ្ញា សូមប្រគល់វេទិកាដើម្បីសួរបន្ត។ សួរដេញដោលអង្គហេតុទាក់ទងទៅនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ដែលអង្គជំនុំជម្រះបានកំណត់ជាអង្គហេតុវគ្គដំបូង

សម្រាប់ដេញដោលចំពោះជនជាប់ចោទ។

[០៩:២៩:០២]

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ នៅពេលដែលយើងសម្រាកអម្បាញ់មិញយើងនិយាយអំពីសមាជឆ្នាំ១៩៧០-- (សុំទោស) ១៩៦០ ទាក់ទងទៅនឹងការចាត់តាំងសមាជិកគណៈមជ្ឈិមក៏ដូចជាតំណាងរបស់បក្ស។ មុននឹងត្រឡប់ទៅនឹងគោលនយោបាយបក្ស ខ្ញុំសូមបញ្ជាក់នូវបញ្ហាមួយទាក់ទងទៅនឹងតំណាងរបស់បក្ស លោក នួន ជា លោកបានបញ្ជាក់ថា អ្នកដែលមានចូលរួមនៅក្នុងសមាជនេះរួមទាំងថ្នាក់ដឹកនាំក៏ដូចជាថ្នាក់ដឹកនាំភូមិភាគ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ខ្ញុំសូមសួរលោកចំពោះថ្នាក់ដឹកនាំភូមិភាគមួយចំនួនមួយ គឺភូមិភាគពាយ័ព្យ។ ថាតើមានតំណាងណាមកពីភូមិភាគពិសាន១ មានមកពីភូមិភាគព្រិសានទេ? មាន នន់ នាម (ឮមិនច្បាស់) ឬ គង់ សុផល ហ្នឹង គាត់បានចូលរួមក្នុងសមាជនេះដែរ ឬទេ លោក នួន ជា?

[០៩:៣០:១៧]

**លោក នួន ជា៖**

**ឆ៖** សូមគោរពលោកប្រធាន តាមសំណួរអម្បាញ់មិញនេះ ខ្ញុំសូមបញ្ជាក់ថា ពេលនោះ មានតំណាងម្នាក់មកពីភូមិភាគព្រិសាន គឺមិត្ត ឡាំង។

**ស៖** ប្រហែលជាខ្ញុំខុស គឺខ្ញុំសូមអធ្យាស្រ័យ ខ្ញុំនិយាយទាំងពីភូមិភាគព្រិសាន ទាំងភូមិភាគពាយ័ព្យផង។ បាទទាំងពីរ។

**ឆ៖** សូមជម្រាបលោកប្រធាន ភូមិភាគពាយ័ព្យមានម្នាក់ឈ្មោះ រស់ ញឹម។

**ស៖** សូមអរគុណលោក នួន ជា។ តើនៅម៉ោងប៉ុន្មានដែរ ឬក៏ថានៅពេលណាដែលលេខាភូមិភាគត្រូវបានចាត់តាំងឲ្យធ្វើជាតំណាងរបស់បក្សនោះ?

[០៩:៣២:០៨]

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ។

**ស៖** តើគេតែងតាំងទៅជាលេខាភូមិភាគចាប់ពីសន្និបាតឆ្នាំ១៩៦០ មកដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន បញ្ហានេះ ខ្ញុំសូមនិយាយឲ្យវែងបន្តិចទេ គឺការដែលធ្វើមហាសន្និបាតចាត់តាំងបក្សឆ្នាំ១៩៦០ នេះ ដែលជ្រើសរើសតំណាងពីគ្រប់ភូមិភាគ គឺគេតស៊ូមកតាំងពីសម័យបារាំងមក ហើយអ្នកអស់នេះជាខ្មែរ អ្នកអស់នេះជាប្រធានភូមិភាគ។ ដូច្នោះជ្រើសតាំងយក-- ជ្រើសរើសយកអ្នកចាស់នេះមកធ្វើជាមហាសន្និបាត។

**ស៖** តើលោកចាំទេ ថាតើនៅពេលណាដែលបក្សបានបែងចែកប្រទេសទៅជាភូមិភាគផ្សេងៗពីគ្នានោះបាទ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ។

**ស៖** កាលពីខែមុន នៅក្នុងការសួរសំណួរដោយចៅក្រមនោះ លោកបានបញ្ជាក់ថា មានមេដឹកនាំលេខាភូមិភាគខ្លះមិនមែនជាសមាជិករបស់បក្សទេ តើលោកអាចជម្រាបតុលាការបានទេ ថាតើប្រធានភូមិភាគណាខ្លះដែលមិនមែនជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជានោះ?

[០៩:៣៥:០៦]

**ឆ៖** សូមជម្រាបលោកប្រធាន ទាំងអស់ហ្នឹង សុទ្ធតែជាសមាជិក តាំងជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា។ ឯប្រជាជនធម្មតាមិនមែនមកធ្វើបានទេ។ នេះកុំឲ្យច្រឡំជាមួយ ន៎ែ គណៈជាតិមុតគាហា រំដោះជាតិ។ ជួនណា វាមានពីរច្រឡំគ្នាអ៊ីចឹង។ មួយ បក្ស។ ពីរ រណសិរ្ស។

**ស៖** តើលោកអានពន្យល់តុលាការទៀតបានទេ ថាតើអ្វីដែលហៅថាគណៈរណសិរ្ស តើរណសិរ្សដែលត្រូវបានបង្កើត បន្ទាប់ពីទសវត្សរ៍ឆ្នាំ១៩៧០ ក្រោយពីដែលក្រោយពីមានរដ្ឋប្រហារទម្លាក់ព្រះមហាក្សត្រនោះដែរឬទេ?

**ឆ៖** រណៈ-- សូមជម្រាបលោកប្រធាន តាមខ្ញុំចាំ គណៈរណសិរ្សនេះហៅថា គណៈជាតិមុតគាហា មានមុនមកហើយ គឺកាលនោះមាន-- បើលោកប្រធានអនុអញ្ញាតខ្ញុំរៀបរាប់ឈ្មោះ។ បើមិនអនុញ្ញាតទេ ខ្ញុំគ្រាន់តែជម្រាបប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

**លោក នួន ជា៖**

**ឆ៖** វាជាប់នឹងប្រវត្តិបន្តិច។ មួយ អាចារ្យមាន ហៅ សឹង-- ប្រែឈ្មោះជា ស៊ីន ង៉ុកមិញ ធ្លាប់បួសនៅភ្នំពេញ។ ពីរ ស៊ីវ ហេង។ បី លោកតា ទូ សាមុត។ បួន លោកតា ចាន់ សម័យ ហៅ ឡាំផៃ។

អ្នកទាំងបួននាក់នេះ សុទ្ធតែខ្មែរកម្ពុជាក្រោមទាំងអស់។ ចាត់តាំង យួនជាអ្នកចាត់តាំង ហៅថាគណៈជាតិមុតគាហា។ គណៈជាតិមុតគាហានេះ មិនសូវមានអ្នកណាគេយល់ទេ ពីព្រោះពាក្យបាលី ហៅឲ្យចំគឺ "គណៈរំដោះជាតិ" ប៉ុន្តែក្រោមការដឹកនាំបញ្ជារបស់យួនទាំងអស់។

**ស៖** សូមអរគុណលោក នួន ជា។ មនុស្សចុងក្រោយមួយ ដែលខ្ញុំចង់សួរលោក ថាតើគាត់វត្តមានដែរឬទេ នៅក្នុងសន្និបាតឆ្នាំ៦០នោះ។ មនុស្សម្នាក់ដែលអ្នកណែនាំលោកឲ្យស្គាល់ ប៉ុល ពត នោះ គឺឈ្មោះ ចាន់។ ឈ្មោះ ចាន់ សាម៉ន ហៅ ខ្មៅ តើគាត់វត្តមាននៅក្នុងមហាសន្និបាតឆ្នាំ៦០ នោះដែរឬទេ?

[០៩:៣៩:១៩]

**ឆ៖** សូមជម្រាបលោកប្រធាន ចាន់ សាម៉ន នេះ គ្មានមុខនៅក្នុងមហាសន្និបាតឆ្នាំ១៩៦០ ទេ។

**ស៖** លោក នួន ជា ឥឡូវនេះ ខ្ញុំសូមអានសេចក្តីដកស្រង់ជូនលោកអំពីសេចក្តីសុន្ទរកថាឆ្នាំ១៩៧០ របស់លោក ប៉ុល ពត ឯកសារ ERN ខ្មែរ 63135 អង់គ្លេស 186226 បារាំង ERN492811។

**លោក ឌេល លីសាក់៖**

លោកប្រធានសូមអនុញ្ញាតដាក់បង្ហាញឯកសារនេះនៅលើអេក្រង់ ដើម្បីជូនភាគី និងជនជាប់ចោទបានពិនិត្យ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**សួរដោយលោក ឌេល លីសាក់៖**

លោកនួន ជា ខ្ញុំអានជូនលោកស្តាប់អំពីសេចក្តីដកស្រង់អំពីសុន្ទរកថា កញ្ញា ៧៧ "មហាសន្និបាតទីមួយ ប្រជុំនៅភ្នំពេញ នៅថ្ងៃ ៣០ កញ្ញា ឆ្នាំ១៩៦០ គឺគោលបំណងដើម្បីបង្រ្កាបខ្មាំងសត្រូវ។ កម្មាភិបាលដែលជាបញ្ញវន្តស្ថិតនៅក្រោមការបង្ក្រាបរបស់ខ្មាំង ហើយត្រូវបានចាប់"។

**ស៖** សំណួររបស់ខ្ញុំគឺថាតើត្រូវទេ ចាប់ពីខែកញ្ញា ឆ្នាំ១៩៧៧ តើគណៈប្រធានរដ្ឋនោះជាលោក ខៀវ សំផន ដែរឬទេ?

**លោក នួន ជា៖**

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនបានពាក់ព័ន្ធពីខាងរដ្ឋបាលទេ។ ខ្ញុំទទួលភារកិច្ចខាងបក្សខាងផ្នែកអប់រំ។

**ស៖** តើលោកមិនដឹងទេថា លោកខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យទេឬ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំគ្រាន់តែឮ។

**ស៖** ថាតើការពាក់ព័ន្ធរបស់លោក ខៀវ សំផន ហ្នឹង ចាប់ពីឆ្នាំ១៩៦០ ខែកញ្ញាមក គាត់ពាក់ព័ន្ធនឹងបក្សដូចម្តេចខ្លះ?

**ឆ៖** សូមជម្រាបលោកប្រធាន តាមខ្ញុំដឹងគ្មានពាក់ព័ន្ធអីទេ ព្រោះគាត់ខាងផ្នែកបញ្ញាជនផ្សេង។ ត្រង់នេះខ្ញុំសូមជម្រាបឲ្យច្បាស់បន្តិច ប៉ុល ពត ហៅខ្ញុំទៅប្រាប់ថា ដូចជាខ្ញុំធ្លាប់និយាយម្តងទៅហើយ ប៉ុន្តែខ្ញុំខ្លាចលោកភ្លេច "មិត្តមិនបាច់រវល់នៅខាងរណសិរ្សបញ្ញាជនទេ មានគេខាងនោះហើយ។ មិត្តគិតតែពីខាងអប់រំទៅ!" ប្រាប់ខ្ញុំតែប៉ុណ្ណឹង ពីរនាក់មុខ ពីរនាក់។ ដូច្នេះអ្នកណាខ្លះអី អ្នកណាខ្លះ ខ្ញុំមិនដឹងទេខាងផ្នែកនោះ។

[០៩:៤៩:១៨]

**ស៖** លោក នួន ជា ផ្ទុយទៅអ្វីដែលលោកបានជម្រាបចៅក្រម ឡាវ៉ែន៍ ពីខែមុននោះដែលថា លោកមិនដឹងថា ពេលណាលោក ខៀវ សំផន បានចូលបក្សទេ នៅឆ្នាំ-- ពិភាក្សាឆ្នាំ១៩៩៨ ជាមួយ ខឹម នន់ នោះលោកបាននិយាយប្រាប់ខឹម នន់ ថាចាប់ពីឆ្នាំ១៩៦៣ មក ខៀវ សំផន ហ្នឹងមិនទាន់បានចូលមជ្ឈិមទេ ប៉ុន្តែគាត់បានចូលបក្សហើយ។ ហើយសេចក្តីដកស្រង់អំពីឯកសារ IS20.8 ខ្មែរ ERN 87196 អង់គ្លេស 6677 បារាំង--

**អ្នកបកប្រែ៖**

គាត់លឿនពេកលោកប្រធាន ERN ខ្ញុំតាមអត់ទាន់ បាទ។

**ប្រធានអង្គជំនុំ៖**

សុំសាជាថ្មីម្តងទៀត។ ទីមួយគឺអាននូវលេខERN ហ្នឹងអម្បាញ់មិញនេះឲ្យបានច្បាស់លាស់ ពីព្រោះខាងអ្នកបកប្រែស្តាប់មិនទាន់ទេ។ មិនអាចបកប្រែបានទេ។ ទីពីរ អំណោះតទៅ នៅពេលដែលលោកយោងទៅឯកសារ ហើយអានលេខសម្គាល់ចំពោះឯកសារនីមួយៗ សូមអានយឺតៗ ដើម្បីឲ្យបានកត់ត្រា និងបកប្រែហ្នឹងឲ្យបានត្រឹមត្រូវ ដើម្បីកត់ត្រាចូលទៅក្នុងប្រតិចារឹក។

**លោក ឌេល លីសាក់៖**

សូមអភ័យទោសលោកប្រធាន។ ឯកសារនោះគឺលេខ IS20.78 ERNខ្មែរ 00078196

អង់គ្លេស ERN00184667 ហើយបារាំង ERN00596190។

**ស៖** សំណួរដែលខ្ញុំសួរទៅលោក នួន ជា នោះថាតើត្រូវដែរឬទេនៅឆ្នាំ១៩៦៣ មិនទាន់បានចូលក្នុងគណៈមជ្ឈិមទេ ប៉ុន្តែបានចូលបក្សរួចហើយ។

**លោក ម៉ៃខល ផេសមិន៖**

លោកចៅក្រម! ខ្ញុំសូមជំទាស់សំណួរនេះ ពីព្រោះថាឯកសារនេះ សហព្រះរាជអាជ្ញាបានសួរសន្និដ្ឋានថា ឯកសារនេះជាប្រតិចារឹកត្រឹមត្រូវដែលបានកត់ត្រាពីបទសម្ភាសន៍រវាងកូនក្តីខ្ញុំ ជាមួយនឹងជនម្នាក់ទៀត។ ហើយតាមដែលខ្ញុំយល់ គឺកូនក្តីរបស់ខ្ញុំបានជំទាស់ទៅលើខ្លឹមសារនេះ។ ដូច្នេះ សូមតុលាការពិចារណា ហើយគាត់មិនដឹងថាតើឯកសារនោះកត់ត្រាត្រឹមត្រូវឬទេ ហើយសម្តីនោះមានអ្វីខ្លះហើយមានយថាភាពដែរឬទេ។ ដូច្នេះ--

[០៩:៤៧:៤៦]

**លោក ឌេល លីសាក់៖**

ខ្ញុំគ្រាន់តែសួរឲ្យគាត់បញ្ជាក់ថា តើខ្លឹមសារត្រឹមត្រូវដែរឬទេ ដើម្បីឲ្យជនជាប់ចោទប្រាប់យើងថាតើព័ត៌មាននោះត្រឹមត្រូវ ឬមិនត្រឹមត្រូវតែប៉ុណ្ណោះ។ ដូច្នេះសូមតុលាការជម្រាប។

**ប្រធានអង្គជំនុំ៖**

ជំទាស់គ្មានប្រសិទ្ធភាព។ ជនជាប់ចោទឆ្លើយនឹងសំណួរនេះ។

លោកព្រះរាជអាជ្ញាសួរម្តងទៀត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក នួន ជា ថាតើត្រូវដែរឬទេ នៅឆ្នាំ១៩៦៣ លោក ខៀវ សំផន មិនទាន់បានចូលគណៈមជ្ឈិមទេ ប៉ុន្តែគាត់បានចូលបក្សរួចហើយ?

**លោក នួន ជា៖**

**ឆ៖** ជម្រាបលោកប្រធាន គាត់ចូលបក្សអីពីអង្កាល់ អីពីអង្កាល់ ខ្ញុំមិនដឹងទេ ពីព្រោះខ្ញុំមិនបានទាក់ទងជិតស្និតអីជាមួយលោក ខៀវ សំផន ទេ។

**ស៖** សូមអរគុណលោក នួន ជា។ សំណួរ ឥឡូវនេះត្រឡប់ទៅរកសំណួរមួយចំនួនទាក់ទងទៅនឹងមាគ៌ាបក្សដែលអនុម័តនៅក្នុងមហាសន្និបាតឆ្នាំ៦០ នៅក្នុងសេចក្តីបើកសវនាការនោះ លោកបាននិយាយថាមាគ៌ាបក្សហ្នឹងគឺកំណត់នៅក្នុងមហាសន្និបាតទីមួយរបស់បក្សដើម្បីកំណត់ខ្មាំងរបស់បដិវត្តន៍

ដែលលោកនិយាយថា គឺអ្នកឈ្លានពានបរទេស អ្នកដែលរំខានកិច្ចការផ្ទៃក្នុងទឹកដីកម្ពុជា ហើយនិងជាក្រុមមួយចំនួន។ តើអ្នកខ្លះដែលលោកនិយាយថានៅក្នុងបន ឬក្រុមនោះ? នៅក្នុងក្រុម ឬក្នុងបននោះថាជាបនខ្មាំង ក្រុមខ្មាំងនោះ។ តើអ្នកណាខ្លះ?

[០៩:៥០:០៥]

**ឆ៖** សូមជម្រាបលោកប្រធាន ដើម្បីច្បាស់លាស់នោះ ខ្ញុំសូមយកឯកសារនោះមកមើលមើល៍ ខ្ញុំនិយាយអ៊ីចឹងមែនឬយ៉ាងម៉េច? ក្នុងឯកសារហ្នឹងមាត៌ា ព្រោះអានេះជាមាត៌ា។

**ស៖** លោក នួន ជា ខ្ញុំដកស្រង់ពីសម្ដីដែលលោកបានបញ្ជាក់ជូនតុលាការនៅថ្ងៃទី២២ វិច្ឆិកា ឆ្នាំទៅជូនតុលាការនៅក្នុងសំណុំរឿង E1/14.1 នៅទំព័រ ៨៣ នេះជាសេចក្ដីដកស្រង់ចេញពីសម្ដីដែលលោកបានបញ្ជាក់នៅក្នុងសេចក្ដីថ្លែងបើកសវនាការនោះ។ តើលោកអាចឆ្លើយទាក់ទងទៅនឹងសំណួរថា តើនៅពេលដែលលោកនិយាយថា បក្សបានកំណត់ថាជាខ្មាំងរបស់បក្សហ្នឹងមានជនឈ្លានពានបរទេស ហើយនិងខ្មាំងមួយចំនួនដែលហៅថា ជាឃ្លិច ជាក្រុម ជាបនខ្មាំង ហ្នឹងថាតើ ក្រុម ឬបនខ្មាំងនោះមានអ្នកណាខ្លះ?

[០៩:៥១:៣២]

**ឆ៖** ខ្ញុំសូមបញ្ជាក់ម្ដងទៀត។ សូមយកឯកសារហ្នឹងមកឲ្យខ្ញុំមើលមើល៍ ព្រោះយកពាក្យនិយាយមក វាមិនច្បាស់។

**ស៖** បើសិនជាលោកមិនចាំទេ អំពីថ្លែងការណ៍របស់លោកៗអាចបានប្រាប់ខ្ញុំ អ៊ីចឹងយើងអាចនឹងរកមើលថា តើអ្វីដែលមានន័យថា “បន” របស់គេនោះបាទ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនចាំ ហើយពាក្យ “បន” នេះ ខ្ញុំមិនសូវដែលនិយាយទេ។

**ស៖** ទាក់ទងទៅនឹងថាតើនរណាជាខ្មាំងរបស់បក្សបដិវត្តន៍នៅក្នុងឆ្នាំ១៩៦០នោះ ខ្ញុំអានសេចក្ដីថ្លែងការណ៍មួយទៀតរបស់ ប៉ុល ពត។ នៅក្នុងសុន្ទរកថា ប៉ុល ពត ឆ្នាំ១៩៧៧ ខែកញ្ញា នោះដែលថានៅក្នុងគំនិតមួយដែលគាត់និយាយថា ឯកសារ D242/2.1.12 នៅខ្មែរ ERN00063145 អង់គ្លេស ERN00486233 និងបារាំង ERN00492820 ហើយយើងក៏មានឯកសារនេះ ដើម្បីបង្ហាញដែរប្រសិនបើលោកប្រធានទាមទារចង់ឲ្យបានឃើញច្បាស់នៅឯកសារនេះបាទ។

**ឆ៖** សូមជម្រាប សូមទាមទារយកឯកសារនេះមកមើលឲ្យច្បាស់។

[០៩:៥៤:១៥]

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាអន្តរជាតិ ក្រៅពីការដាក់បង្ហាញនូវឯកសារនេះនៅលើអេក្រង់ទូរទស្សន៍ សូមថតចម្លងនូវចំណុចដែលត្រូវសួរដេញដោលនេះ ដាក់ជូនទៅជនជាប់ចោទ ដើម្បីឱ្យគាត់អាចពិនិត្យដោយផ្ទាល់ ហើយអក្សរហ្នឹងឱ្យសមល្មម កាលបើធំពេក វានឹងអាចមើលទៅក៏មិនច្បាស់ដែរ ហើយតូចពេកក៏ៗមើលមិនច្បាស់ដែរ ដើម្បីឱ្យគាត់បានពិនិត្យនូវមើលដោយផ្ទាល់ ពីព្រោះការមើលនៅកញ្ចក់អេក្រង់ទូរទស្សន៍នេះមិនជាការងាយប៉ុន្មានទេ។

**លោក ខេល លីសាក់៖**

បាទលោកប្រធាន ខ្ញុំមានឯកសារនៅលើក្រដាស ហើយយើងបោះពុម្ពគឺថា អាច-- បើគាត់មិនអានលើអេក្រង់បានទេ ឬក៏គាត់មិនអាចអានលើក្រដាសបានទេ យើងអាចស្នើក្រឡាបញ្ជីឱ្យអានជូនគាត់ស្តាប់បាន។

[០៩:៥៦:០១]

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីអាននូវឯកសារដែលសហព្រះរាជអាជ្ញា មានបំណងដាក់បង្ហាញ ហើយនិងសួរដេញដោលនេះ ផ្នែកដែលពាក់ព័ន្ធនឹងការសួរដេញដោលអានដើម្បីឱ្យច្បាស់ៗ ដើម្បីឱ្យជនជាប់ចោទបានស្តាប់ឮ។ លោក ផារី!

**ក្រឡាបញ្ជី៖**

ជាមាគ៌ា យើងបានលើកឡើង! ការវិភាគទំនាស់នៅក្នុងសង្គម នៅក្នុងប្រទេសជាតិកម្ពុជារួចហើយ។ តើត្រូវកំណត់សត្រូវនៃបដិវត្តន៍យ៉ាងម៉េច និងកម្លាំងបដិវត្តន៍យ៉ាងម៉េច?

សត្រូវមានពីរ ដែលត្រូវវាយ។ សត្រូវទីមួយ គឺចក្រពត្តិនិយម ពិសេសចក្រពត្តិអាមេរិកាំង។ ទីពីរ គឺវណ្ណៈសក្តិភូមិ ម្ចាស់ដី និងៗ*(ឮមិនច្បាស់)* ប្រតិកិរិយា។ កម្លាំងមានកម្មករ កសិករ មានអនុជននាយទុនជាតិ មានឥស្សរជនចម្រើនស្នេហាជាតិ។ កម្លាំងនៅក្នុងសង្គមជាតិទាំងប៉ុន្មាន គឺប្រមូល--

[០៩:៥៨:០៧]

**ប្រធានអង្គជំនុំ៖**

អានផ្នែកដែលគេគូសក្រហមរង្វង់ជុំវិញនោះណា។ ទៅអានឯណា?

បានហើយអរគុណអង្គុយចុះ!

អញ្ជើញ សហព្រះរាជអាជ្ញាមានអី សំណួរទៀតទេ?

**សួរដោយលោក ខេល លីសាក់៖**

សូមអភ័យទោស លោកប្រធាន ខ្ញុំមានសំណួរបាទ។

ខ្ញុំមានសំណួរពីរជូនលោកនួន ជា អំពីសេចក្តីថ្លែងការណ៍ដែលបានអានអម្បាញ់មិញនេះ។

**ស៖** សំណួរទីមួយសួរថា ដូចដែលបានបញ្ជាក់នៅក្នុងឯកសាររបស់បក្សនេះ តើអ្នកដែលគេសម្រេចថា ជាខ្មាំងរបស់បដិវត្តន៍ពីដំបូងនោះ នៅក្នុងសន្និបាតដំបូង គឺពួកចក្រពត្តិនិយម ឬក៏ពួកសក្តិភូមិនិយមហ្នឹង មានពីរហ្នឹងដែរឬទេ?

[០៩:៥៩:៣៧]

**លោក នួន ជា៖**

**ឆ៖** សូមជម្រាបលោកប្រធាន។ ខុស! មិនត្រូវទេ។

**ស៖** ថាតើក្នុងបរិបទណាដែលលោកថា មិនត្រូវនោះបាទ?

**ឆ៖** ភាគទីពីរ សក្តិភូមិ ពាក្យថា "សក្តិភូមិ" នេះមិនមែនមនុស្សសក្តិភូមិទេ គឺរបបសក្តិភូមិប្រតិកិរិយា បរិវារចក្រពត្តិឃោរឃៅទៀត មិនមែនសក្តិភូមិទទេៗទេ។ ដូច្នោះនិយាយវាមិនអស់សេចក្តីធ្វើឱ្យតុលាការហ្នឹងភ័ន្តច្រឡំអាចនឹងភ័ន្តច្រឡំ។ និយាយឱ្យអស់សេចក្តីក្នុងឯកសារ ខ្លាចមិនមែនឯកសារខ្ញុំ។ សត្រូវវាមានពីរ មួយពួកចក្រពត្តិឈ្លានពាន វាតទីលេបទឹកដីបំបាត់ពូជសាសន៍។ មួយទៀត បរិវារវា។ ឯសក្តិភូមិចែក-- មិនមែនមនុស្សសក្តិភូមិទេ របបសក្តិភូមិដែលយើងត្រូវតស៊ូបំបាត់។ ដូចជាខ្ញុំបាននិយាយច្រើនដងហើយរបបសក្តិភូមិហ្នឹងវាស្អីខ្លះ រឿងខ្ចីបុលបណ្តាក់អីៗអស់នេះ មិនបាច់និយាយទៀតទេ អាហ្នឹងនៅក្នុងមាគ៌ាអស់ហើយ។ ខ្ញុំនិយាយម្តងហើយ ហើយលោកប្រធានបានហាមឃាត់ខ្ញុំថាមិនបាច់និយាយទៀតទេ ព្រោះនិយាយរួចហើយ។

[១០:០២:០៤]

**ស៖** ខ្ញុំមិនសូមឱ្យលោកបញ្ជាក់ដដែលទេ ខ្ញុំសួរឱ្យពន្យល់ថា តើពាក្យថា "ពួកបរិវារចក្រពត្តិ" នោះ តើពួកមនុស្សប្រភេទមនុស្សណាតាមនិយមន័យរបស់លោក?

**ឆ៖** ពួកខ្ញុំបម្រើចក្រពត្តិ ក្បត់ជាតិឯង ចូលជាមួយចក្រពត្តិ ធ្វើខ្ញុំបម្រើចក្រពត្តិ។

**ស៖** មានសេចក្តីយោងនៅក្នុងឯកសារនេះ ដែលគេហៅថា "ប្រតិកិរិយា" នោះ តើលោកអាចជម្រាបតុលាការបានដែរឬទេ? ថាតើពួកប្រតិកិរិយានោះ ជាក្រុមមនុស្សប្រភេទណាដែរបាទ?

**ឆ៖** សូមជម្រាបលោកប្រធាន ប្រតិកិរិយាហ្នឹងប្រែថា ពួកដែលប្រឆាំង ពួកដែល-- ប៉ុន្តែវាមិនមាន-- វាមានច្រើនប្រភេទ។ សួរមួយមាត់ៗអ៊ីចឹងខ្ញុំពិបាកឆ្លើយ ខ្ញុំឆ្លើយវាមិនអស់។ ប្រតិកិរិយាឃោរឃៅ ប្រតិកិរិយាដោយចាំបាច់ ប្រតិកិរិយាដោយគេបង្ខំ អាហ្នឹងវាត្រូវបែងចែកច្រើនទៅទៀត។ យកមួយមាត់ៗមកសួរ ខ្ញុំឆ្លើយមិនអស់ទេ ហើយវាមិនត្រឹមត្រូវផង មិនមែនស្អីបន្តិចក៏ប្រតិកិរិយាៗ។

**ស៖** តើត្រឹមត្រូវទេលោក នួន ជា ពាក្យថាដែលថា នៅសម័យមុនឆ្នាំ១៩៧៥ បក្សបានសន្និដ្ឋានឬក៏បានចាត់ទុកថាមន្ត្រីរបស់ពីមុនរបស់ លន់ នល់ គឺជាផ្នែកនៃពួកចក្រពត្តិនិយមតើលោកយល់ដូចម្តេចដែរ?

**ឆ៖** សូមជម្រាបលោកប្រធាន មិនត្រឹមត្រូវទេ ហើយមិនដែលចាត់ទុកពួកអ្នកអស់នេះជាសត្រូវទេ។

[១០:០៥:១២]

**ស៖** ថាតើមិនត្រឹមត្រូវទេឬលោក នួន ជា ដែលថាពួកសក្តិភូមិ បក្សបានកំណត់និយមន័យថាមានពីរ ទីមួយជាម្ចាស់ដី ទីពីរ គឺពួកអភិជន ឬក៏ពួកអនិជនអារីស្តូក្រាដនោះ?

**ឆ៖** រឿងនេះវារួម សូមជម្រាបគោរពលោកប្រធាន។ អ្នកដែលគេត្រឹមត្រូវក៏វាអារីស្តូក្រាដអភិជនដែលគេល្អក៏មានដែរ។ ប៉ុនអភិជនដែលក្បត់ជាតិក៏មាន ដូច្នោះយើងទៅម៉ៅទាំងអស់វាមិនបានទេ ត្រូវបែងចែកឲ្យច្បាស់លាស់។ ពួកសក្តិភូមិក៏អ៊ីចឹងដែរ សក្តិភូមិប្រតិកិរិយា សក្តិភូមិខ្លះ គេមានស្មារតីជាតិដែរ អភិជនខ្លះគេមានស្មារតីជាតិ មិនមែនចេះតែក្បត់ជាតិទាំងអស់ឯណា។ លោកយកមួយម៉ាត់ៗ មកសួរអ៊ីចឹង ខ្ញុំមិន-- ពិបាកឆ្លើយណាស់ បើឆ្លើយមួយម៉ាត់ៗអ៊ីចឹង បើឆ្លើយឲ្យហូរហែអំមិញទៅវាស្រួលស្តាប់ជាង វាបែងចែកច្រើន។ បើអ៊ីចឹងជាតិយើងវាបែកបាក់ខ្ទេចខ្ទីអស់ហើយ អាណាក៏សត្រូវៗ សូម្បីតែនៅក្នុងព្រះរាជវង្សានុវង្ស ក៏មានរាជវង្សានុវង្សខ្លះ គេមានស្មារតីជាតិ គេស្រឡាញ់ជាតិ គេប្រឆាំងពួកឈ្លានពានពីក្រៅប្រទេស។ អាហ្នឹងយើងចាត់ទុកគេជាអភិជនជាសត្រូវក៏មិនបានខុសៗមាគ៌ារណសិរ្ស ដូច្នោះការសួររបស់លោកព្រះរាជអាជ្ញាហ្នឹងឲ្យវាហ្មត់ចត់បន្តិច កុំចេះតែសួរមួយកំណាត់ៗនោះខ្ញុំពិបាកឆ្លើយណាស់។ បើខ្ញុំឆ្លើយខ្លីទៅវាខុស វាមិនគ្រប់ជ្រុង វាមិនគ្រប់ន័យ ព្រោះក្នុងមាគ៌ាហ្នឹងវានិយាយល្អិតណាស់។

សូមគោរពលោកប្រធានប៉ុណ្ណឹង។

[១០:០៨:២៦]

**ស៖** អរគុណចំពោះការពន្យល់របស់លោក។ ខ្ញុំចង់សួរថាតើបក្សកំណត់ថា អ្នកណាមិនល្អ សក្តិភូមិ ឬក៏ជា-- អ្នកណាជាចក្រពត្តិ អ្នកណាជាម្ចាស់ដី អ្នកណាជាមនុស្សល្អ តើបក្សកំណត់ដោយរបៀបណាដែរទៅលើប្រភេទមនុស្សទាំងអស់នេះ?

**ឆ៖** សូមគោរពលោកប្រធាន ចក្រពត្តិ គឺពួកដែលឈ្លានពានប្រទេសយើង ចង់យកប្រទេសយើងទៅធ្វើខ្ញុំវា អាហ្នឹងចំហើយ ឬហៅថាអាណានិគមនិយម ដូចជាអាណានិគមនិយមសម័យបារាំងស្អីពីដើមនេះ។ ឯមកក្រោយទៀត ពួកអ្វីដែលលោកមានប្រសាសន៍អំមិញហ្នឹង ក៏ដូចជាខ្ញុំបានជម្រាបអ៊ីចឹង វាមិនមែនម៉ៅទាំងអស់ទេ វាបែងចែកពួកឃោរឃៅ ពួកមិនឃោរឃៅ ពួកគេអ្នកល្អក៏មានដែរ គេស្នេហាជាតិ។ ខ្ញុំលើកឧទាហរណ៍បន្តិចទៅចុះ ប៉ុន្តែសម័យនេះវាហួសមកហើយ ដូចជាពួកត្រកូលជួន ជឿន។ ជួន ជឿន នេះ គាត់ត្រកូលខ្ពស់ណាស់ ប៉ុន្តែគាត់លះបង់ទៅធ្វើបដិវត្តន៍។ ជួន ជឿន, ជួន មុំ, ជួន ប្រាសិទ្ធ ពួកខ្សែ ជួន។ ដូច្នោះបើយើងចេះតែម៉ៅទាំងអស់ ប្រទេសជាតិយើងវាខ្ទេចខ្ទីអស់ហើយ។

**ស៖** អរគុណចំពោះការពន្យល់នេះលោក។ ឥឡូវខ្ញុំសូមត្រឡប់ទៅឯកសារមួយនៅក្នុងខែសីហា ១៩៧៤ ដែលចុះផ្សាយនៅក្នុងទង់យុវជនយុវនារី គឺថាពួកសក្តិភូមិចែកជាពីរ គឺជាសក្តិភូមិអារីស្តូក្រាដមាននាទីពីរ គឺជាពួកសក្តិភូមិប្រភេទម្ចាស់ដី ហើយពួកសក្តិភូមិប្រភេទអារីស្តូក្រាដនេះ គឺសូមដកស្រង់សម្តី "គឺជាអ្នកដែលត្រួតត្រាគ្រប់គ្រងបញ្ជប់ ហើយក្នុងនោះគឺរាប់មានស្តេច មន្ត្រីជាន់ខ្ពស់ ចៅហ្វាយខេត្ត ចៅហ្វាយស្រុក រហូតទៅដល់មេឃុំ ក៏ដូចជាជំទប់ និងក្រឡាបញ្ជីផង និងស្មៀនឃុំផងដែរ"។

[១០:១១:៤៦]

ហើយជាឯក-- នៅជាភាសាខ្មែរ ERN00283409 ហើយជា គឺមាន0053746 ជាភាសាបារាំង 00611810។ សំណួររបស់ខ្ញុំ លោក នួន ជា ថាតើលោកថាមិនមែនពួកសក្តិភូមិទាំងអស់ជាចាត់ទុកថាជាខ្មាំងនោះទេ ទាក់ទងទៅនឹងវណ្ណៈម្តង នៅក្នុងឯកសារនេះគឺថាពួកសក្តិភូមិអារីស្តូក្រាដនេះ ប្រភេទនេះរួមមានស្តេច មន្ត្រីរបស់ មន្ត្រីរដ្ឋកាលផ្សេងៗ។ សូមលោកជួយពន្យល់បានទេ?

**ឆ៖** ខ្ញុំសូមជម្រាបគោរពលោកប្រធាន ខ្ញុំសូមលោកយកឯកសារហ្នឹងមកឲ្យខ្ញុំមើលមើល៍ តើជាឯកសាររបស់បក្សមែន ឬមិនមែន?

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយកឯកសារពីសហព្រះរាជអាជ្ញាអន្តរជាតិទៅបង្ហាញជនជាប់ចោទ!

**លោក ខេល លីសាក់៖**

លោកប្រធាន! ខ្ញុំក៏សូមយកការដកស្រង់សម្ដីដាក់ជូននៅលើអេក្រង់នេះដែរ។ សូមស្នើសុំដាក់ដូច្នេះ។

[១០:១៤:០២៣]

**ប្រធានអង្គជំនុំ៖**

លោក ផារី ត្រៀមមើលឯកសារដើម្បីអានក្នុងករណីជនជាប់ចោទពិបាកអាននូវឯកសារដែលបានដាក់ជូនគាត់។

**លោក នួន ជា៖**

គ្រាន់ជាអក្សរនេះ ខ្ញុំមិនដែលឃើញទេ។ ហើយក្នុងយុវជន មិនដែលរៀនដល់ប៉ុណ្ណឹងទេ។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោក នួន ជា ខ្ញុំមិនបានស្នើសុំឲ្យលោកផ្ដល់យថាភាពទៅលើឯកសារនេះ ថាឯកសារនេះត្រឹមត្រូវ មិនត្រឹមត្រូវនោះទេ។ គ្រាន់តែសុំឲ្យលោកជួយជម្រាបមកខ្ញុំ ថាតើនេះវាត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវដែលបក្សកំណត់ថា ពួកអភិជនមានពីរ គឺមានអភិជនសក្តិភូមិ រួមមានស្តេច រួមមាននាហ្មឺន កុង្សីយ៍ ហ្វាយខេត្ត ហ្វាយស្រុក រហូតដល់មេឃុំ ជំទប់ ព្រមទាំងស្មៀនទៀតផង តើនេះត្រឹមត្រូវដែរឬទេលោក?

**លោក នួន ជា៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់ហើយ សូមគោរពលោកប្រធាន មិនត្រឹមត្រូវទេ។

**ស៖** អ៊ីចឹង ថាតើបក្សបានកំណត់វណ្ណៈសក្តិភូមិប្រភេទអារីស្តូក្រាដនេះដោយរបៀបណាដែរ?

**ឆ៖** សូមបញ្ជាក់លោកប្រធាន បើគ្រាន់តែសួរថាសក្តិភូមិ កំណត់សក្តិភូមិហ្នឹង វារួមណាស់។ សក្តិភូមិនេះ វាច្រើនប្រភេទ។ បើផ្អែកក្នុងបក្សចង់និយាយនែ៎ គឺសក្តិភូមិពួកម្ចាស់ដីប្រតិកិរិយាឃោរឃៅផុតលេខ ខ្ញុំសូមបញ្ជាក់ហើយបញ្ជាក់ទៀត មិនមែនចេះថាអ្នកណាក៏សក្តិភូមិ អ្នកណាមានដីសក្តិភូមិប្រែថា អ្នកមានដី ម្ចាស់ដី។ មិនមែនចេះតែកំណត់ពាសវាលពាសកាលអ៊ីចឹងទៅ វាបែកបាក់រណសិរ្សអស់ហើយ ជាតិយើងនោះ ប្រមូលកម្លាំងវាមិនបានទេ ពីព្រោះទិសដៅនៃការបដិវត្តរបស់កម្ពុជាប្រជាធិបតេយ្យគឺ បន្ថយមិត្ត-- អ៎! បន្ថយសត្រូវ បន្ថែមមិត្តជាអតិបរមា។ ទោះបីជាគេជាវណ្ណៈអីក៏ដោយឲ្យតែគេមានស្មារតីស្នេហាជាតិខ្លះ ក៏យើងត្រូវប្រមូលយកទាំងអស់។ នេះ ខ្ញុំសូមបញ្ជាក់ឲ្យ

ច្បាស់។ ដូចជាខ្ញុំបាននិយាយ ក្រៅតែពីពួកដែលតាំងចិត្តបម្រើចក្រពត្តិ បំផ្លាញប្រទេសជាតិខ្លួន លក់ប្រទេសជាតិខ្លួនឲ្យចក្រពត្តិ ធ្វើខ្ញុំបម្រើចក្រពត្តិ។

[១០:១៨:៤០]

**ស៖** សូមអរគុណលោក នួន ជា លោកបានបញ្ជាក់ថា នៅពេលដែលយើងនិយាយអំពីការបំពាក់បំប៉នវគ្គនយោបាយកាលពីខែមុន ទាក់ទងទៅនឹងទង់បដិវត្តនេះ គឺថាមានឯកសារជាច្រើនដែលបក្សបានប្រើប្រាស់សម្រាប់ការអប់រំរៀនសូត្រ។ ឥឡូវ ខ្ញុំសូមបង្ហាញនូវឯកសារសារាចរ គឺមាន D366/7.1.56 គឺថាឯកសារនេះ ជាឯកសារដែលបក្សបានប្រើប្រាស់សម្រាប់ការអប់រំបណ្តុះបណ្តាល។

**លោក ខេល លីសាក់៖**

លោកប្រធាន យើងខ្ញុំមានឯកសារនេះនៅក្នុងសំណុំឯកសារនេះ ខ្ញុំចង់យកទំព័រនេះគឺថាសុំដាក់សុំបង្ហាញជូននូវទំព័រដែលខ្ញុំបានលើកឡើងអម្បាញ់មិញ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីច្បាប់យកឯកសារទៅជូនលោក នួន ជា ហើយនិងអនុញ្ញាតឲ្យដាក់បង្ហាញឯកសារទំព័រដែលត្រូវដេញដោលនេះនៅលើអេក្រង់ទូរទស្សន៍។

**លោក ខេល លីសាក់៖**

លោកប្រធាន ទំព័រពាក់ព័ន្ធដែលខ្ញុំចង់បង្ហាញជាភាសាខ្មែរគឺ ERN00442434 រហូតដល់ 004424 ជាអង់គ្លេស 007378 រហូតដល់ 99។ ជាភាសាបារាំង 007217 រហូតដល់ 88 គឺមានឯកសារ D66.7.1.5.6 ជាឯកសារដែលបក្សបានប្រើប្រាស់ក្នុងការបំពាក់បំប៉នមនោគមន៍វិជ្ជាដ៏ជ្រាលជ្រៅបំផុត។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកនួន ជា សេចក្តីថ្លែងដែលខ្ញុំចង់បញ្ជាក់នៅក្នុងឯកសារនេះគឺបានលើកឡើងដូចតទៅនេះ ខ្ញុំសូមដកស្រង់ទាំងស្រុង គឺថា “នៅតែមានការទំនាស់គ្នារវាងវណ្ណៈសក្តិភូមិ រួមមានម្ចាស់ដី ក៏ដូចជាពួកអភិជន គឺក្នុងនោះមាន មេឃុំ ចៅហ្វាយស្រុក ចៅហ្វាយខេត្ត មន្ត្រីរាជការ ប៉ូលិស និងទាហាន” ឯកសារនេះបន្តទៅទៀតថា “នេះគឺជាទំនាស់ស្រួចស្រាល់ ទំនាស់ស្លាប់រស់” ដូច្នេះសំណួររបស់ខ្ញុំគឺថាតើវាត្រឹមត្រូវឬក៏អត់ ការលើកឡើងនៅក្នុងឯកសារនេះ ដែលថា បក្សបានសម្រេចថា ទំនាស់សន្និដ្ឋាន

ថា ទំនាស់ជាមួយនឹងពួកអភិជន ក៏ដូចជាម្ចាស់ដី គឺត្រូវចាត់ទុកថា ជាទំនាស់ស្រួចស្រាល់ និងជាទំនាស់ស្លាប់រស់?

[១០:២៣:៥៣]

**លោក នួន ជា៖**

**ឆ៖** សូមជម្រាបលោកប្រធាន ខុស! ទំនាស់នេះ អ្នកណាទៅទំនាស់ជាមួយមេឃុំ ជំទប់អី ជាមួយគ្នាឯងទៅជាទំនាស់ស្រួចស្រាល់ ស្លាប់រស់អីនោះ? វាខុសទេ! វាមិនមែនទេ! នាហ្នឹងមន្ត្រីអីខ្លះក៏គេល្អក៏មានដែរ។ មិនមែនចាត់ទុកទាំងអស់ទេ ខ្ញុំបញ្ជាក់ហើយបញ្ជាក់ទៀត។ ហើយលោកនៅតែសួរដដែលទៀត។ ឆ្លើយ ខ្ញុំមិនឆ្លើយទេ។ ព្រោះខ្ញុំឆ្លើយច្រើនដងមកទៅហើយ។

**ស៖** សូមអរគុណលោក នួន ជា។ យើងបាននិយាយគ្នាអំពីមាគ៌ាបក្ស គឺថានិយាយអំពីមាគ៌ាបក្សដែលត្រូវបានសម្រេចនៅមហាសន្និបាត១៩៦០ បន្ទាប់មកមានកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ រវាងខែកញ្ញា ១៩៦០ រហូតដល់១៧ មេសា ១៩៧៥ ថាតើបក្សដែលនិយាយ ឬក៏ធ្វើការសម្រេចជាបន្តទៅទៀត ថាតើក្រុមមនុស្សប្រភេទណាដែលត្រូវចាត់ទុកថាជាខ្មាំងរបស់បក្សនោះ?

**ឆ៖** តាមខ្ញុំចាំមិនដែលចាត់ទុកជាក្រុមទេ ជាខ្មាំងរបស់បក្សនោះទេ ជាបុគ្គលអាចមាន ដែលពួកបំផ្លាញ ដែលពួកឲ្យដំណើងទៅខ្មាំង ឲ្យខ្មាំងមកទម្លាក់បេ៥២ អីៗអស់នេះ។ ដូច្នោះខ្ញុំសូមជម្រាបហើយជម្រាបទៀត កុំនិយាយម៉ៅនាហ្នឹង មន្ត្រី អ្នករាជការមេឃុំ ជំទប់ អីអស់នេះ ក៏មិនមែនជាសត្រូវអី ក្រៅតែពីពួកដែលបម្រើខ្មាំងឯណា ដូចដែលខ្ញុំបានជម្រាបមកហើយ ច្រើនដងមកហើយ។ បើទុកពួកអស់នេះជាសត្រូវ បដិវត្តន៍មានមនុស្សឯណាធ្វើបដិវត្តន៍ វាអស់រលីងហើយ។ អាណាក៏ជាសត្រូវៗនោះ។ ដូចជាខ្ញុំជម្រាបហើយ ជម្រាបទៀត វាមានគោលការណ៍របស់វា បន្ថយមិត្ត-- បន្ថយសត្រូវ បន្ថែមមិត្តជាអតិបរមា។ នេះជាពាក្យស្លោក ប្រមូលគ្រប់កម្លាំងស្នេហា កម្លាំងមិនបាច់ស្នេហាជាតិទេ ឲ្យតែមានស្មារតីជាតិក៏ប្រមូលយកដែរ គឺថាគេមិនចូលខ្មាំង ក៏ទុកគេមានស្មារតីជាតិ ជួនណាគេនៅអព្យាក្រឹតក៏យកគេដែរ។ ជួនណាខ្មាំងគេមិនចូល ខាងយើង ខាងបដិវត្តន៍ក៏គេមិនចូល គេនៅកណ្ដាល អាហ្នឹងក៏យើងត្រូវប្រមូលគេ មិនមែនទុកជាសត្រូវអី។ អានេះខ្ញុំសូមបញ្ជាក់ហើយ បញ្ជាក់ទៀត បញ្ជាក់ច្រើនដងណាស់ទៅហើយ។ ព្រោះខ្ញុំសូមជម្រាបអីចេះ មិនមែនខ្ញុំ អត់ទោស ខ្ញុំមិនមែនទៅវ៉ៃតម្លៃលោកអីទេ ព្រោះលោកមិនដែលស្គាល់អ្នកក្រទេ។

លោកទៅមើលអ្នកក្រនៅអមលាំង នៅប្រាំបីមុំយ៉ាងម៉េច។

[១០:២៨:២០]

**ប្រធានអង្គជំនុំ៖**

លោក នួន ជា លោកផ្តល់ស្មារតី ហើយឆ្លើយតបទៅនឹងសំណួរដែលសួរបានហើយ ហើយសំណួរឯណាដែលលោកគិតថា លោកសម្រេចចិត្តមិនឆ្លើយតប លោកគ្រាន់តែឆ្លើយថា លោកមិនឆ្លើយតបទៅនឹងសំណួរទៅបានហើយ។ លោកមិនមានសិទ្ធិឯណាមកប៉ះពាល់ដល់ភាគីនៃរឿងក្តីចំពោះកិច្ចដំណើរការនៃការសួរដេញដោលចំពោះលោកនោះឡើយ។

នេះជាបច្ចេកទេស ឬក៏ជាវិធីសាស្ត្រក្នុងការសួរដេញដោលទៅតាមភាគីនៃរឿងក្តី ក៏ដូចជាបច្ចេកទេស និងវិធីសាស្ត្រនៃបុគ្គលដែលត្រូវចូលរួមនៅក្នុងការអនុវត្តនីតិវិធីចំពោះមុខតុលាការ។

**លោក នួន ជា៖**

លោកប្រធាន ខ្ញុំគោរពតុលាការ ក៏ប៉ុន្តែដូចខ្ញុំជម្រាបនេះ គ្រាន់តែជាឧទាហរណ៍ទេ។ ពីព្រោះអ្នកខ្លះមិនដែលស្គាល់អ្នកក្រយ៉ាងម៉េចផងនៅតែក្រុង។ និយាយពីអ្នកក្រហ្នឹង មិនស្គាល់អ្នកក្រផង ខ្ញុំសូមជម្រាបជាក់ស្តែងមានពួកមកពីប្រទេសក្រៅ ឃើញស្រូវក្នុងស្រែ សួរថាគេដាំស្មៅធ្វើអីហ្នឹង? មិនស្គាល់ទាំងស្រូវផង។ អាហ្នឹងនេះខ្ញុំគ្រាន់តែលើកឧទាហរណ៍ឲ្យច្បាស់អ៊ីចឹង។ ដូច្នោះការរស់នៅខុសគ្នា ទស្សនៈវាខុសគ្នា។ ការរស់នៅអំបិលប្រហុក វាមានទស្សនៈទៅផ្សេងទៅ ប៉ុន្តែការរស់នៅដោយអំណាចអាជ្ញា ស្រីស្រា លុយកាក់ ល្បែងស៊ីសង វាមានទស្សនៈទៅផ្សេងទៅ។ ខ្ញុំសូមឧទាហរណ៍អ៊ីចឹង ខ្ញុំសូមលើកការជាក់ស្តែងអ៊ីចឹងចុះ។

[១០:៣០:៤៧]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ នេះជានីតិវិធីតាមផ្លូវតុលាការ គឺលោកស្តាប់នូវសំណួរដែលសួរ ហើយឆ្លើយតបទៅតាមគំនិត និងការយល់ឃើញរបស់លោក ហើយក្នុងករណីដែលមិនអាចឆ្លើយតប ឬក៏មិនយល់ថាមិនចាំបាច់ក្នុងការឆ្លើយតប គឺលោកអាចសម្តែងនូវមតិថា លោកមិនឆ្លើយតបនឹងសំណួរនេះទេព្រោះ គុណភាពរបស់លោកមិនអាចពាក់ព័ន្ធ ប៉ះពាល់ទៅលើភាគីម្ខាងទៀតបានទេ។

ឥឡូវដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ សូមអញ្ជើញសម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:៣១ នាទី ដល់ម៉ោង ១១:០៤ នាទី)*

[១១:០៣:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សូមប្រគល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរចំពោះជនជាប់ចោទ នួន ជា។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅពេលដែលយើងសម្រាកនោះ លោក នួន ជា យើងបានពិភាក្សាគ្នាមួយចំនួននោះ ខ្ញុំបានសួរសំណួរទូទៅមួយចំនួន ទាក់ទងទៅនឹងចំណុចមួយចំនួន ដែលថា និយមន័យរបស់បក្សហ្នឹងមានន័យដូចម្ដេច? កែប្រែដែរឬទេ? ឥឡូវនេះ ខ្ញុំនឹងសួរសំណួរជាក់លាក់។ នៅពេលដែលលោកផ្ដល់សក្ខីកម្មនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ការងាររបស់បដិវត្តន៍នោះ ដែលកំណត់ដោយបក្ស គឺកម្ទេចកាកសំណល់នៃអាណានិគមនិយម ដែលជាផ្នែកមួយនៃសង្គមកម្ពុជា ហើយលោកក៏បានពន្យល់តទៅទៀតថា គោលបំណងរបស់បក្សប្រជាជាតិកម្ពុជានោះ គឺលុបបំបាត់ពួកនាយទុននិយម ពួកនាយទុន។

[១១:០៥:០៧]

សំណួរ ដែលខ្ញុំចង់សួរលោកនៅពេលនេះ នៅចំណុចណាមួយនៃពេលវេលាថា តើគោលបំណងបក្សកែប្រែទេ ដែលប្ដូរពីបដិវត្តន៍ប្រជាជាតិធិបតេយ្យ ទៅជាបដិវត្តន៍សង្គមនិយមហ្នឹងមានការផ្លាស់ប្ដូរគោលបំណងទេ? បើផ្លាស់ប្ដូរ ផ្លាស់ប្ដូរនៅពេលណា?

**លោក នួន ជា៖**

**ឆ៖** តាមសំណួរ-- គោរពលោកប្រធាន តាមសំណួររបស់លោកព្រះរាជអាជ្ញា តើមានឯកសារច្បាស់លាស់ទេ ដែលខ្ញុំទៅនិយាយអ៊ីចឹង? សូមឯកសារយកមកមើលមើល!

**ស៖** ខ្ញុំមិនអានចេញពីឯកសារទេ។ ខ្ញុំគ្រាន់តែសួរសំណួរថាតើនៅពេលណាមួយ ដែលគោលបំណងរបស់បក្សបានផ្លាស់ប្ដូរ អំពីបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ហើយប្ដូរទៅជាបដិវត្តន៍សង្គម

និយមនោះបាទ?

[១១:០៦:២៨]

**ជ៖** អាហ្នឹងទាល់តែ-- សូមជម្រាបលោកប្រធាន។ ទាល់តែខ្ញុំឃើញឯកសារច្បាស់សិនបាន ខ្ញុំឆ្លើយបានបាទ។ បើមិនឃើញឯកសារឲ្យខ្ញុំឆ្លើយយ៉ាងម៉េច?

**សៈ** លោក នួន ជា ខ្ញុំមិនអានពីឯកសារទេ។ ប៉ុន្តែអ្វីដែលខ្ញុំអាន គឺអានសក្ខីកម្មរបស់លោកពីមុនដែលលោកពន្យល់ថា គោលដៅរបស់បក្ស គឺលុបបំបាត់ចោលនូវកាកសំណល់របស់អាណានិគម ប្រតិកិរិយា។ អ្វីដែលលោកពន្យល់នោះគឺថា ភាគីបន្តនូវបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ។ អ្វីដែលខ្ញុំសួរលោកពេលនេះ ថាតើនៅពេលណាមួយ ទិសដៅរបស់បក្សហ្នឹងផ្លាស់ប្តូរទេ ពីបដិវត្តន៍ប្រជាធិប-តេយ្យប្តូរទៅជាបដិវត្តន៍សង្គមនិយមហ្នឹង មានការផ្លាស់ប្តូរដែរឬទេ? ប្តូរពេលណា?

[១១:០៧:៤០]

**ជ៖** ខ្ញុំសូមបញ្ជាក់លោកប្រធានថែមទៀត។ តើមានសរសេរក្នុងឯកសារទេ ដែលលោកយកមកនិយាយនេះ?

**សៈ** ខ្ញុំសួរតាមន័យផ្សេង ដើម្បីឲ្យលោក នួន ជា មានឱកាសឆ្លើយ។ តើពេលណាមួយដែលពួកវណ្ណៈនាយទុននោះ ត្រូវបានគេចាត់ទុកថា ជាខ្មាំងរបស់បដិវត្តន៍ដែរឬទេ?

**ជ៖** សូមជម្រាបលោកប្រធាន គ្មានពេលណាដែលបក្សចាត់ទុកនាយទុនជាខ្មាំងរបស់បដិវត្តន៍ទេ។

**សៈ** សូមអរគុណលោក នួន ជា។ ហើយនៅក្នុងចម្លើយរបស់លោកពីខែមុននោះ លោកបាននិយាយថា ការតស៊ូប្រដាប់អាវុធ មិនចាប់ផ្តើមទេរហូតទាល់តែឆ្នាំ១៩៦៨។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថាតើការតស៊ូប្រដាប់អាវុធនោះគឺមិនចាប់ផ្តើមទេ រហូតទាល់តែឆ្នាំ១៩៦៨ ខែមករា ក្រោយពេលដែលមហាសន្និបាតអនុវត្ត សម្រេចថាឲ្យធ្វើការតស៊ូប្រដាប់អាវុធ កាលពីមហាសន្និបាតឆ្នាំ១៩៦០ តើត្រូវដែរឬទេ?

[១១:០៩:៤៤]

**ជ៖** ស្នើលោកព្រះរាជអាជ្ញា សរុបសំណួរឲ្យខ្លីបន្តិច ខ្ញុំស្តាប់មិនសូវបានទេ។

**សៈ** បាទសំណួរខ្លី ថាតើត្រឹមត្រូវទេនៅក្នុងសន្និបាតឆ្នាំ១៩៦០ បក្សបានឯកភាព ឬក៏បានសម្រេចឲ្យប្រើការតស៊ូហិង្សាប្រដាប់អាវុធនោះ?

**ឆ៖** តាមខ្ញុំចាំ បក្សនៅតែតស៊ូនយោបាយជាមូលដ្ឋានដដែល ឯការតស៊ូដោយអាវុធជាការរួមផ្សំបន្ទាប់បន្សំគ្រាន់តែការពារខ្លួនទេ ការពារកម្មាភិបាលទេ ដូចខ្ញុំបានជម្រាបរួចមកហើយពីលើកមុននោះ។ ឯការតស៊ូនោះ នៅតែតស៊ូនយោបាយនៅឡើយទេ។

**ស៖** ខ្ញុំនឹងបង្ហាញលោកនូវឯកសារមួយ ដែលជាឯកសារផ្សាយព័ត៌មានអន្តរជាតិនៅក្នុងសុន្ទរកថាដែលលោកបានប្រកាសនៅពិធីបុណ្យខួបលើកទី៩ នៃកងទ័ពបដិវត្តន៍កម្ពុជានៅថ្ងៃទី១៦ មករា ឆ្នាំ១៩៧៧ ដែលផ្សាយតាមកម្ពុជាប្រជាធិបតេយ្យឯកសារលេខ D26.26 (ស៊ីក) ហើយនៅក្នុងខ្លឹមសារនោះ គឺមានសុន្ទរកថា ដែលជាខ្មែរ ERN0067979 រហូតដល់ 67802។ ហើយអង់គ្លេស ERN00168465 រហូតដល់ 168970 បារាំង ERN00698444 រហូតទៅដល់ 698450។

លោកប្រធានសូមអនុញ្ញាតឲ្យមន្ត្រីតុលាការ យកឯកសារភាសាខ្មែរបង្ហាញជូនជនជាប់ចោទ។

[១១:១៣:០២]

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការ យកឯកសារពីព្រះរាជអាជ្ញាទៅជូនជនជាប់ចោទ!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក នួន ជា នៅក្នុងសុន្ទរកថារបស់លោក ដែលលោកបានធ្វើ ហើយនៅក្នុងខាងក្រោមទំព័រនោះ សូមលោកពិនិត្យមើលនៅខាងក្រោមទំព័រទីមួយនៃឯកសារនេះ ហើយសូមលោកប្រាប់ខ្ញុំតើលោកចាំទេ ដែលលោកបានធ្វើសុន្ទរកថាទៅដល់កងទ័ពបដិវត្តន៍កម្ពុជានៅខួបទី៩ នៃកំណើតកងទ័ពហ្នឹងនៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៧។

[១១:១៤:៣២]

**លោក នួន ជា៖**

**ឆ៖** ខ្ញុំសូមជម្រាបលោកប្រធាន ខ្ញុំត្រូវការពេលវេលា ដើម្បីពិនិត្យឯកសារនេះ។

**ស៖** លោក នួន ជា លោកអាចប្រើពេលអាន ប៉ុន្តែសំណួររបស់ខ្ញុំសួរថា តើលោកនៅចាំទេថា លោកបានធ្វើសុន្ទរកថានៅថ្ងៃខួបឆ្នាំទីប្រាំបួន នៃបក្ស នៃកងទ័ពបដិវត្តន៍កម្ពុជា ដែលធ្វើឡើងនៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៧។ តើលោកនៅចាំថាលោកបានធ្វើសុន្ទរកថានុ៎ងទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ។ ព្រោះខ្ញុំមិនមែនខាងយោធាទេ។ ប្រធានគណៈកម្មាធិការយោធាគឺ ប៉ុល ពត។ ដូច្នោះបើធ្វើសុន្ទរកថា គឺ ប៉ុល ពត ធ្វើសុន្ទរកថា មិនមែនខ្ញុំទេ។

**ស៖** ខ្ញុំយល់ហើយនោះគឺជាករណីធម្មតា លោក នួន ជា ប៉ុន្តែយើងមើលសេចក្តីផ្តើមនៃសុន្ទរកថានោះ គេបាន-- សុន្ទរកថានោះកំណត់ថាលោក នួន ជា គឺជាប្រធាននៃសភាប្រជាជនកម្ពុជា ហើយជានាយករដ្ឋមន្ត្រីស្តីទី តើត្រឹមត្រូវដែរឬទេ លោក នួន ជា ដែលថានៅពេលមួយ ដោយហេតុថា ប៉ុល ពត នោះមានជំងឺ ហើយគេបានចាត់តាំងឲ្យលោកធ្វើជានាយករដ្ឋមន្ត្រីស្តីទី ដើម្បីជំនួសគាត់ តើត្រូវដែរឬទេ?

[១១:១៦:៣៩]

**ជ៖** សូមជម្រាបលោកប្រធាន ខុសទេ។ ខ្ញុំមិនដែលធ្វើនាយករដ្ឋមន្ត្រីទេ។ ខ្ញុំសូមជម្រាបអ៊ីចេះឲ្យច្បាស់ ប៉ុល ពត ហើយនិងខ្ញុំអាយុច្រើនហើយកាលណោះ ត្រៀមអ្នកជំនួសគឺ សុន សេន។ ដូច្នោះខ្ញុំមិនទទួលខាងយោធាអីទេ។ អ្នកជំនួស ប៉ុល ពត សម្រាប់ ប៉ុល ពត គាត់មានគ្រោះថ្នាក់អីយ៉ាងម៉េចៗទៅ គឺកសាង សុន សេន ជាបណ្តើរៗ។ មិនមែនខ្ញុំទេ។

**ស៖** តើលោកមិនចាំទេឬ ថានៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៦ ជាសាធារណៈ គេបានប្រកាសថា លោកត្រូវបានជំនួស ប៉ុល ពត ជាបណ្តោះអាសន្នក្នុងឋានៈជាលេខាបក្សនៅពេលដែលគាត់កំពុងឈឺ តើលោកមិនចាំទេឬ លោក នួន ជា?

**ជ៖** ខ្ញុំមិនដែលឮ សូមជម្រាបលោកប្រធាន។

[១១:១៨:១៧]

**ស៖** តើមិនមែនជាករណីដែរឬទេ ស្ទើរតែមួយឆ្នាំដែលលោកបានធ្វើការជានាយករដ្ឋមន្ត្រីស្តីទី ដែលបានចុះហត្ថលេខា ដែលបានធ្វើកិច្ចការអីមួយចំនួនក្នុងឋានៈរបស់ ប៉ុល ពត ដែលគាត់ឈឺនោះ។ តើពិតដែរឬក៏មិនពិត?

**ជ៖** សូមជម្រាបលោកប្រធាន មិនពិតទេ។ សូមបញ្ជាក់ហើយ បញ្ជាក់ទៀត អ្នកដែលជំនួសគឺ សុន សេន ព្រោះកសាង សុន សេន ឲ្យទៅជាលេខាបក្សទៅថ្ងៃមុខ។ ពេលដែល ប៉ុល ពត ឈឺនោះ សុន សេន ទេ ជាអ្នកជំនួស មិនមែនខ្ញុំទេ។

**ស៖** ចាតើ ប៉ុល ពត ឈឺនោះអស់រយៈពេលប៉ុន្មានដែរ ដែលចាត់តាំង សុន សេន ឲ្យជំនួស ប៉ុល ពត នោះ?

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសូមអនុញ្ញាតជំទាស់ទៅនឹងសំណួរនេះលោកប្រធាន។ ដោយសារថា សំណួរនេះមិនទាក់ទង

ទៅនឹងផ្នែកទីមួយនៃសវនាការនេះទេ ពីព្រោះនេះវាហួសពីវិសាលភាពនៃសវនាការនេះ ពីព្រោះថាយើងត្រូវនិយាយតែពីរឿងការជម្លៀសដំណាក់កាលដំបូងតែប៉ុណ្ណោះនៅក្នុងរឿងក្តី ០០២ នេះ។

សូមតុលាការជ្រាប។

[១១:២០:០០]

**លោក ខេល លីសាក់៖**

ខ្ញុំមិនចូលទៅដល់ជម្រៅនោះទេ ខ្ញុំគ្រាន់តែចង្អុលបង្ហាញឯកសារដែលបានពិភាក្សាអំពីប្រវត្តិមូលដ្ឋានរបស់បក្ស ហើយខ្ញុំកំណត់ថាតើចង់ឲ្យដឹងថាអ្នកណាជាអ្នកធ្វើសុន្ទរកថានោះតែប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

ការជំទាស់របស់មេធាវីការពារក្តី មិនមានប្រសិទ្ធភាពទេ។ ដូច្នេះសហព្រះរាជអាជ្ញាអាចបន្តការសួរសំណួរ ហើយជនជាប់ចោទត្រូវឆ្លើយទៅនឹងសំណួរដែលសហព្រះរាជអាជ្ញាសួរ។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោក នួន ជា ខ្ញុំសួរថាតើរយៈពេលប៉ុនណាដែលលោក សុន សេន ជំនួសលោក ប៉ុល ពត ក្នុងឋានៈជានាយករដ្ឋមន្ត្រីនៅពេលដែល ប៉ុល ពត គាត់ឈឺ បាទ?

**ឆ៖** កាលណោះ ខ្ញុំចាំ ប៉ុល ពត ឈឺច្រើនខែហើយ គាត់ឈឺរហូត។ ដូច្នេះ សុន សេន ជាអ្នកជំនួសរហូតមក។ មិនដឹងប៉ុន្មានឆ្នាំ មិនប៉ុន្មានខែអី ខ្ញុំមិនចាំទេ។

**ស៖** ដោយហេតុថា ខ្ញុំសួរសំណួរដើម្បីកំណត់ថាតើអ្នកណាជាអ្នកធ្វើសុន្ទរកថានោះ។ សំណួរថាតើត្រឹមត្រូវទេ នៅពេលដែល ប៉ុល ពត គាត់ឈឺ។ មេដឹកនាំផ្សេងទៀត បានធ្វើសុន្ទរកថា ដូចជានិយាយនៅក្នុងខួបកងទ័ពបដិវត្តន៍កម្ពុជានោះ។ បើសិនជាអ្នកមេដឹកនាំឈឺ ហើយត្រូវមានអ្នកផ្សេងធ្វើសុន្ទរកថា តើមានហេតុការណ៍បែបនេះដែរឬទេ?

[១១:២២:២៧]

**ឆ៖** សូមជម្រាបលោកប្រធាន សុន សេន ជាប្រធានសេនាធិការ ដូច្នោះគេមានភារកិច្ចខាងយោធា។

**ស៖** ខ្ញុំគ្រាន់តែចង់ដឹងថា នៅក្នុងពេលដែល ប៉ុល ពត ឈឺ តើមានមេដឹកនាំណាផ្សេងទៀត ដូចជា សុន សេន, ខៀវ សំផន ឬក៏រូបលោកផ្ទាល់ដែលត្រូវធ្វើសុន្ទរកថានៅក្នុងសន្និបាតនោះ ជំនួស ប៉ុល ពត សំណួរខ្ញុំសួរអ៊ីចឹងបាទ?

**ឆ៖** សូមជម្រាបលោកប្រធាន បញ្ហានេះ វាគ្មានពាក់ព័ន្ធខាងជាមួយលោក ខៀវ សំផន ទេ។ ព្រោះ ខៀវ សំផន គាត់មិនមែនខាងយោធាឯណា។ ហើយខ្ញុំខាងប្រធានសភាឯណោះ។ ដូច្នោះ មានតែ សុន សេន ទេ ដែលជាប្រធានសេនាធិការ។ សូមបញ្ជាក់ហើយ បញ្ជាក់ទៀត។

**ស៖** សូមអរគុណ ហើយយើងនឹងជជែកគ្នាម្តងទៀតពីបញ្ហានេះ។ ឥឡូវនេះ ខ្ញុំចូលទៅដល់ចំណុចមួយ នៅក្នុងសេចក្តីថ្លែងការណ៍ នៅក្នុងឯកសារដែលខ្ញុំបានជូនទៅលោកអម្បាញ់មិញនេះ។ យើងបាននិយាយអំពីបញ្ហា អំពីការផ្តល់ការយល់ព្រម ឲ្យការប្រើអំពើហិង្សាប្រដាប់អាវុធនៅក្នុងឆ្នាំ ១៩៦០ នៅក្នុងសន្និបាត។ ដូច្នេះខ្ញុំនឹងអានឯកសារ D262.62 ខ្មែរ ERN 00679796 អង់គ្លេស ERN 00168467 ហើយបារាំង ERN 00698446 ហើយយើងមានសេចក្តីដកស្រង់ ហើយសូមអនុញ្ញាតតុលាការដាក់បង្ហាញនៅក្នុងអេក្រង់សម្រាប់ភាគី និងជនជាប់ចោទផងដែរ។ អរគុណ។

[១១:២៥:០០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**លោក នួន ជា៖**

សូមជម្រាបលោកប្រធាន ខ្ញុំសូមយកឯកសារហ្នឹងមកមើលមើល៍! ឯកសារដើមហ៎។ បង្ហាញខ្ញុំបានទេ បើមាន?

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នេះជាឯកសារដែលខ្ញុំបានជូនទៅលោកប្រហែល ឯកសារ D626.626។ ចំណុចដែលខ្ញុំយោងឲ្យលោកពិនិត្យនោះ គឺនៅក្នុងការពិភាក្សាអំពីសុន្ទរកថា អំពីមាគ៌ាយុទ្ធសាស្ត្រ មាគ៌ាយុទ្ធវិធី ដែលពិភាក្សានៅក្នុងឆ្នាំ១៩៦៦នោះ គឺថា "យើងប្រកាន់គោលជំហរច្បាស់លាស់ក្នុងការកម្ទេច និងផ្តួលរំលំពួកចក្រពត្តិអាមេរិក និងពួកបរិវារ និងវណ្ណៈជិះជាន់ទាំងអស់។ សកម្មភាពនយោបាយតែឯកឯងមិនអាចទទួលជោគជ័យបានទេ។ ខ្មាំងប្រើប្រាស់អាវុធ និងតួនាទីផ្តាច់ការ ដើម្បីគាបសង្កត់ និងសម្លាប់ប្រជាជនយើង។ ដោយសារមូលហេតុនេះក្រោយឆ្នាំ១៩៦០ អង្គការបដិវត្តន៍យើងបានសម្រេចច្បាស់ថា យើងត្រូវតែប្រើសកម្មភាពនយោបាយ និងអំពើហិង្សាប្រដាប់វុធ ដើម្បីផ្តួលរំលំ និងកម្ទេចខ្មាំង"។

[១១:២៦:៥៦]

សំណួររបស់ខ្ញុំ ថាតើនេះជាសេចក្តីត្រឹមត្រូវនៃមាគ៌ាបក្សដែលត្រូវបានអនុម័តនៅក្នុងមហា

សន្និបាតឆ្នាំ១៩៦០ ដែរឬទេ?

**ឆ៖** ខ្ញុំទទួចហើយទទួចទៀត។ សូមយកឯកសារហ្នឹងឲ្យខ្ញុំមើលឲ្យច្បាស់សិន បានខ្ញុំឆ្លើយបាន។ បើគ្រាន់តែសួរអ៊ីចឹង ខ្ញុំឆ្លើយម៉េចកើត។

**លោក ឌេល លីសាក់៖**

លោកប្រធានខ្ញុំពេញចិត្តនឹងជូនឯកសារនេះដល់ជនជាប់ចោទ ឲ្យគាត់អាចអាន ហើយថ្ងៃស្អែកយើងខ្ញុំអាចនឹងសួរគាត់។ បាទ, ដូច្នេះនៅក្នុងពេលនេះ យើងទុកបញ្ហានេះមួយឡែកសិន ខ្ញុំសួរផ្សេងក៏បាន។ សូមតុលាការជម្រាប។

**ប្រធានអង្គជំនុំ៖**

បាទ, អនុញ្ញាត យើងមានតែមធ្យោបាយធ្វើដូច្នេះ។ ហើយឯកសារហ្នឹងបានដាក់ជូនលោក នួន ជា រួចហើយ។ សូមលោកពិនិត្យឯកសារនេះ ហើយនៅព្រឹកថ្ងៃស្អែក យើងនឹងពិភាក្សាយកបញ្ហានេះមកពិភាក្សាដេញដោលបន្តទៀត។

ឥឡូវនេះសូមសហព្រះរាជអាជ្ញាបន្តនូវសំណួរថ្មីផ្សេងទៀត។

[១១:២៨:២៦]

**សួរដោយលោក ឌេល លីសាក់៖**

ប្រធានបទនៅខាងមុខ ដែលខ្ញុំនឹងសួរលោកអំពីមហាសន្និបាតឆ្នាំ១៩៦០នោះ នៅក្នុងសេចក្តីថ្លែងបើករបស់លោកនៅតុលាការនេះ លោកបាននិយាយអំពីទម្រង់នៃការតស៊ូស្របច្បាប់ និងខុសច្បាប់ផងដែរ។ ខ្ញុំនឹងបង្ហាញលោកនូវសេចក្តីថ្លែងការណ៍ តាំងពីនៅក្នុងសេចក្តីថ្លែងការណ៍របស់ ប៉ុល ពត នៅក្នុងឆ្នាំ១៩៧៧ ឯកសារ D4 ដែលមានខ្មែរ ERN000631148 អង់គ្លេស ERN00486236 ហើយបារាំង ERN00492824។ ហើយយើងអាច សូមអនុញ្ញាតតុលាការបង្ហាញឯកសារនេះនៅលើអេក្រង់ផងដែរ ដើម្បីភាគី ហើយនិងជនជាប់ចោទបានពិនិត្យ។

[១១:២៩:៤៨]

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត ហើយនិងឲ្យថតចម្លងយកឯកសារត្រង់ចំណុចដែលត្រូវដេញដោលដាក់ជាក្រដាសជូនទៅជនជាប់ចោទ ដើម្បីគាត់មានលទ្ធភាពពិនិត្យមើល។

**លោក ខេល លីសាក់៖**

បាទលោកប្រធាន យើងបានជូនទៅលោកជនជាប់ចោទហើយកាលពីព្រឹកមិញនេះ។ ឯកសារនេះនៅក្នុងសំណុំឯកសារនោះឯង។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការជួយសមសម្របសម្រួលលោក នួន ជា ដើម្បីបង្ហាញនូវឯកសារដែលសហព្រះរាជអាជ្ញាកំពុងតែដាក់ចំពោះមុខអង្គជំនុំជម្រះដើម្បីដេញដោលនេះ។

[១១:៣២:០៥]

**លោក នួន ជា៖**

ជម្រាបលោកប្រធាន ខ្ញុំមិនអាចទទួលយកឯកសារកូពីនេះបានទេ។ ខ្ញុំទទូចសុំយកឯកសារដើម និយាយហើយ និយាយទៀត។

**ប្រធានអង្គជំនុំ៖**

លោក នួន ជា អង្គជំនុំជម្រះសូមជម្រាបលោកថាកាលពីថ្ងៃម្សិលមិញ ទី១០ ខែមករា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចផ្ទាល់មាត់ពាក់ព័ន្ធនឹងឯកសារទង់បដិវត្តនេះរួចហើយ។ បើទោះបីជាបញ្ហាជំទាស់លើឯកសារទាំងនេះ អង្គជំនុំជម្រះនឹងថ្លឹងថ្លែងសម្រេចនៅពេលបញ្ចប់សវនាការដោយពិចារណាលើភស្តុតាងទាំងមូល។ នាពេលនេះជនជាប់ចោទមិនអាចជំទាស់ទៅនឹងការប្រើប្រាស់ឯកសារដែលអង្គជំនុំជម្រះ ឬភាគីបានដាក់ចំពោះអង្គជំនុំជម្រះ ឬភាគីហើយ។ លោកមានសិទ្ធិឆ្លើយតបទៅនឹងសំណួរដែលត្រូវបានសួរនោះ។ ប្រសិនបើជនជាប់ចោទប្រើប្រាស់កាលៈទេសៈនេះដើម្បីចាកចេញ ឬជៀសវាងពីការឆ្លើយទៅនឹងសំណួរដែលបានសួរ ដូចជាការសួររកឯកសារដើមរបៀបនេះជាដើមនោះ។ តុលាការចាត់ទុកថាសកម្មភាពរបស់ជនជាប់ចោទ គឺជាការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបទៅនឹងសំណួរដែលត្រូវបានសួរចំពោះលោក។

[១១:៣៣:៤៥]

**លោក នួន ជា៖**

ជម្រាបលោកប្រធាន ខ្ញុំរក្សាសិទ្ធិនៅស្ងៀម។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន កូនក្ដីរបស់ខ្ញុំគឺគាត់មិនប្រើប្រាស់សិទ្ធិរបស់គាត់ដើម្បីឆ្លើយតបទេ គឺថាគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ដោយទាមទារឲ្យមានការបង្ហាញយថាភាពជាមុនសិន។ អ៊ីចឹងការពិតគឺថាវាជាអត្ថបទថតចម្លងពីឯកសារដើម។ គាត់ស្នើសុំឲ្យបង្ហាញជូនមកគាត់នូវឯកសារដើម។ បាទ, អ៊ីចឹងត្រង់ចំណុចនេះ កូនក្ដីរបស់ខ្ញុំកំពុងជំទាស់តវ៉ាទៅលើយថាភាពនេះឯង ហើយខ្ញុំមិនចង់ឲ្យសហព្រះរាជអាជ្ញាគាត់ដកស្រង់នូវឃ្លា ឬប្រយោគណាមួយចេញពីឯកសារនេះតទៅទៀតទេ។

[១១:៣៥:៣០]

**ប្រធានអង្គជំនុំ៖**

សូមប្រគល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរប្រសិនបើមានការពាក់ព័ន្ធទៅនឹងឯកសារទស្សនាវដ្ដីទង់បដិវត្ត ដែលអង្គជំនុំជម្រះបានសម្រេចរួចហើយនេះ លោកអាចបង្ហាញនូវចំណុចឯកសារដែលពាក់ព័ន្ធ គឺបង្ហាញអំពីអត្តសញ្ញាណនៃឯកសារ ឬខ្លឹមសារនៃឯកសារដែលពាក់ព័ន្ធចំពោះមុខអង្គជំនុំជម្រះនាពេលនេះ ពីព្រោះជនជាប់ចោទបានបង្ហាញជំហរច្បាស់លាស់ហើយរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប។

ព្រះរាជអាជ្ញាយល់ទេ បញ្ហានេះប្រសិនបើពាក់ព័ន្ធទៅនឹងទង់បដិវត្តលេខពិសេស ដែលអង្គជំនុំជម្រះបានសម្រេចរួចហើយនេះ គឺលោកអាចបន្តបង្ហាញនូវចំណុចដែលពាក់ព័ន្ធនៅក្នុងអង្គហេតុដែលធ្វើសវនាការវគ្គទីមួយនេះ ដែលពាក់ព័ន្ធនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា។ អង្គជំនុំជម្រះនឹងធ្វើការកត់សម្គាល់បញ្ហាទាំងអស់នេះចូលទៅប្រតិចារឹក ដោយជនជាប់ចោទបានបង្ហាញជំហរច្បាស់លាស់ហើយចំពោះការបង្ហាញឯកសារនេះ គឺគាត់រក្សាសិទ្ធិមិនឆ្លើយតប។ តែអង្គជំនុំជម្រះបានសម្រេចរួចហើយថាឯកសារនេះ គឺទទួលយកជាឯកសារភស្តុតាងដាក់ដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ដូចខ្លឹមសារដែលមានបានសម្រេចកាលពីម្សិលមិញ ហើយព្រឹកមិញក៏យើងបានបញ្ជាក់បន្ថែមបន្តបន្ទាប់ហើយ។

[១១:៣៧:០៩]

ក្នុងករណីដែលលោកអាចមានសំណួរផ្សេងទៀត ដែលមិនពាក់ព័ន្ធជាមួយនឹងឯកសារទង់បដិវត្តនេះក៏លោកអាចសួរបាន ហើយជនជាប់ចោទអាចឆ្លើយ ឬក៏រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះជាសិទ្ធិរបស់ជនជាប់ចោទដែលមាន។ យើងបានប្រាប់រួចហើយ មុននឹងដេញដោល គឺសិទ្ធិរបស់ជនជាប់ចោទ គាត់មានសិទ្ធិដូច្នេះពេញនៅក្នុងដំណាក់កាលនីតិវិធីនៃការសួរដេញដោលតាំងពីដើមរហូតដល់ចប់។

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមសួរសំណួរមួយចំនួនទៀតថា តើគាត់បន្តអនុវត្តសិទ្ធិរបស់គាត់ ឬក៏គាត់រក្សាសិទ្ធិមិនឆ្លើយតបតទៅទៀត។សេចក្ដីថ្លែងការណ៍ដែលខ្ញុំបានលើកឡើងមកបង្ហាញនៅក្នុងឯកសារចុះខែកញ្ញា ១៩៧៧ ហ្នឹង គឺថាខ្ញុំសូមដកស្រង់ដូចតទៅ៖ "មហាសន្និបាតលើកទីមួយរបស់បក្សយើងបានបញ្ជាក់ នូវរូបភាពនៃការតស៊ូបដិវត្តន៍មួយចំនួន។ រូបភាពទីមួយគឺ ត្រូវប្រើហិង្សាបដិវត្តន៍ដោយប្រើនយោបាយ និងហិង្សាបដិវត្តន៍ដោយអាវុធ។ ហើយរូបភាពទីពីរ គឺជារូបភាពដោយស្របច្បាប់ពាក់កណ្ដាល និងមិនស្របច្បាប់ដោយយកប្រើ-- ដោយយកមិនស្របច្បាប់មកប្រើ"។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** សំណួររបស់ខ្ញុំ លោក នួន ជា ថាតើនៅក្នុងមហាសន្និបាត១៩៦០ បានសម្រេចប្រើប្រាស់រូបភាពតស៊ូមិនស្របច្បាប់ពាក់កណ្ដាល និងរូបភាពស្របច្បាប់ ដើម្បីសម្រេចឱ្យបាននូវទិសដៅរបស់បក្សកុម្មុយនីស្តកម្ពុជា?

[១១:៣៩:០៥]

**លោក នួន ជា៖**

**ឆ៖** ជម្រាបលោកប្រធាន ខ្ញុំរក្សាសិទ្ធិមិនឆ្លើយតប។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាអាចបន្តសំណួរសួរទៅចំណុចផ្សេងទៀត ពីព្រោះបានបង្ហាញច្បាស់លាស់ហើយ។ ហើយចំណុចនេះ យើងបានសរសេរចូលនៅក្នុងប្រតិចារឹករួចហើយ។

**សួរដោយលោក ខេល លីសាក់៖**

សូមអរគុណច្រើន។ ខៀវ សំផន បានសរសេរនៅក្នុងសៀវភៅគាត់ដោយពិចារណាទៅលើប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាបន្ទាប់ពីមហាសន្និបាត១៩៦០។ ខ្ញុំដកស្រង់សំណេររបស់គាត់ គឺដើម្បីប្រកាសឱ្យបានច្បាស់លាស់អំពីដំណើរថ្មី គ្រប់សមាជិកនៃចលនាតស៊ូទាំងអស់ត្រូវដាក់ពាក្យសុំចូលរួមជាសមាជិកបក្ស។ ឯកសារ D213.2 ខ្មែរ 00380369 អង់គ្លេស 0049232 បារាំង 00403835។ សំណួររបស់ខ្ញុំ លោក នួន ជា ថាតើបន្ទាប់ពីមហាសន្និបាតឆ្នាំ១៩៦០ សមាជិកទាំងអស់ត្រូវដាក់ពាក្យរបស់ខ្លួនសាជាថ្មីឡើងវិញ ដើម្បីសុំចូលរួមធ្វើជាសមាជិករបស់បក្ស។ តើមានដូច្នេះមែនទេ?

**ឆ៖** ខ្ញុំស្ដាប់មិនបានទេ ព្រោះខ្ញុំមិនដែលឃើញឯកសារ ដែល ខៀវ សំផន សរសេរ។

[១១:៤១:៣៩]

**ស៖** លោក នួន ជា លោកគឺជាអនុលេខាបក្ស ហើយមានមនុស្សតិចណាស់ ដែលបានចូលរួមនៅក្នុងមហាសន្និបាត១៩៦០។ ខ្ញុំសួរថាតើលោកមានចាំ ឬក៏អត់ចំពោះសមាជិកបក្ស ដែលត្រូវបានបក្សស្នើសុំឲ្យដាក់ពាក្យសាជាថ្មីឡើងវិញ ដាក់ពាក្យចូលជាសមាជិកបក្សសាជាថ្មីឡើងវិញនោះ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ។

**ស៖** សំណួរបន្ទាប់ ខ្ញុំចង់សួរទៅលោកនេះ គឺពាក់ព័ន្ធទៅនឹងការកែប្រែមាគ៌ាគោលនយោបាយបក្សពីឆ្នាំ១៩៦០ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះ ថាតើអ្នកណាអ្នកមានសិទ្ធិអំណាចក្នុងការកែប្រែមាគ៌ានយោបាយរបស់បក្ស ចេញពី-- ដោយផ្ដើមចេញពីមហាសន្និបាតឆ្នាំ១៩៦០នោះ?

[១១:៤២:៤៧]

**ឆ៖** អ្នកដែលមានសិទ្ធិកែប្រែមាគ៌ាបក្សមានតែមហាសន្និបាតបក្សទូទាំងប្រទេស ក្រៅពីនេះគ្មានអ្នកណាមានសិទ្ធិកែប្រែទេ។

**ស៖** ដូច្នេះមានន័យថា គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ដែលមិនអាចកែប្រែគោលនយោ-បាយបក្សទេគឺថា មាគ៌ាគោលនយោបាយបក្ស អាចកែប្រែបានតាមរយៈតែមហាសន្និបាតបក្សតែប៉ុណ្ណោះ។ តើនេះត្រឹមត្រូវទេលោក?

**ឆ៖** ត្រូវ។ បាទសូមគោរពលោកប្រធាន មានតែមហាសន្និបាតសមាជិកបក្សទូទាំងប្រទេសមានសិទ្ធិកែប្រែមាគ៌ានយោបាយរបស់បក្ស ក្រៅពីនេះគ្មានអ្នកណាមានសិទ្ធិកែប្រែទេ។ សូមបញ្ជាក់ហើយបញ្ជាក់ទៀត។

**ស៖** លោកអាចប្រាប់ខ្ញុំបានទេ ទាក់ទងទៅនឹងការកែប្រែគោលនយោបាយបន្ទាប់ពីឆ្នាំ១៩៦០ហើយនិងមុនឆ្នាំ១៩៧៥។ ខ្ញុំកែប្រែសំណួរខ្ញុំ ថាតើមានការកែប្រែមាគ៌ានយោបាយបក្សមុនថ្ងៃ១៧មេសា ១៩៧៥ ដែរទេ បន្ទាប់ពីមាគ៌ានយោបាយនេះបានសម្រេច ដោយមហាសន្និបាត១៩៦០រួចមក?

[១១:៤៤:២៥]

**ឆ៖** ជម្រាបលោកប្រធាន ខ្ញុំចាំមិនបានទេ។

**ស៖** មានន័យថា លោកមិនអាចចាំការកែប្រែមាគ៌ានយោបាយចន្លោះពី១៩៦០ ទៅមុន១៧មេសា ៧៥ មានន័យថា លោកមិនចាំទេ។ តើអ៊ីចឹងមែនទេលោក?

**ឆ៖** ខ្ញុំមិនចាំ ជម្រាបលោកប្រធាន-- គោរពលោកប្រធាន។ ដូចជាជម្រាបហើយ ជម្រាបទៀត កែប្រែមាគ៌ានយោបាយរបស់បក្ស ទាល់តែមហាសន្និបាតបក្សទូទាំងប្រទេសបានកែប្រែបាន។ ឯគណៈមជ្ឈិម គណៈអចិន្ត្រៃយ៍ ឬអីៗនេះកែប្រែមិនបានទេ។

**ស៖** អរគុណលោក នួន ជា។ ប្រធានបទទូទៅមួយទៀត ដែលខ្ញុំចង់បន្តទៅមុខទៀតនេះ គឺទាក់ទងទៅនឹងអង្គភាពយោធាសម្ងាត់ អង្គភាពការពារសម្ងាត់ បន្ទាប់ពីមហាសន្និបាត១៩៦០ អង្គជំនុំជម្រះបានសួរលោកខ្លះៗរួចមកហើយ ប៉ុន្តែខ្ញុំសូមបន្តពាក់ព័ន្ធទៅនឹងចំណុចនេះតទៅទៀត។ សំណួររបស់ខ្ញុំបន្តទៅទៀតនេះ គឺថាសក្ខីកម្មដែលលោកបានផ្តល់នៅថ្ងៃទី១៣ ធ្នូ ២០១១នោះ គឺថាមានការបង្កើតអង្គភាពការពារសម្ងាត់មួយ គឺសូមដកស្រង់សម្តី គឺថា "ដោយជ្រើសរើសពីកូនចៅកសិករ"។ សំណួររបស់ខ្ញុំថា ហេតុអ្វីបានជាជ្រើសរើសក្មេងៗដែលជាកូនចៅរបស់កសិករដូច្នេះ?

[១១:៤៦:៤៥]

**ឆ៖** ខ្ញុំសូមជម្រាបលោកប្រធាន មិនមែនយោធាទេ ជាកងការពារកម្មាភិបាល-- ជាកងសម្រាប់ជូនកម្មាភិបាលដើរធ្វើការងារ។ គ្មានអាវុធអីៗទេ មានតែដំបងអីៗបន្តិចបន្តួចប៉ុណ្ណឹង។ ដូច្នោះមិនមែនកងយោធាទេ។

**ស៖** បាទដូច្នេះទៅចុះ ក៏ប៉ុន្តែហេតុអ្វីបានជាជ្រើសរើសកុមារ ដើម្បីឲ្យបំពេញមុខងារនេះទៅវិញ?

**ឆ៖** តាមខ្ញុំចាំ កុមារថ្មីអស់នេះវាឃ្វាលគោផង ហើយវាជួយមើលកម្មាភិបាលផង ជាកូនចៅរបស់គេ បងប្អូនរបស់គេ គេការពារបងប្អូនគេ។ មិនមែនយើងទៅជ្រើសរើសយកមកទេ។ ឧបមាថាទៅណា ហៅយកក្មួយទៅៗជាមួយផងទៅ។

**ស៖** តើកុមារទាំងនោះមានអាយុប្រហែលជាប៉ុន្មានឆ្នាំដែរ? ផ្តើមចេញពីការសម្រេចពីមហាសន្និបាត១៩៦០ សម្រេចថា ជ្រើសរើសកុមារដើម្បីឲ្យចូលបម្រើកងការពារសម្ងាត់នេះ ពួកគេមានអាយុប្រហែលជាប៉ុន្មានដែរ?

**ឆ៖** តាមខ្ញុំចាំគ្មានសម្រេចអីទេ។ អាយុ-- តាមខ្ញុំចាំអាយុបួន-ប្រាំដណ្តប់ ទៅឃ្វាលគោផងទៅអីផងទៅ ក្មេងជនបទ។

**ស៖** តើអ្នកណាជាអ្នកទទួលខុសត្រូវ រៀបចំបង្កើតកងការពារសម្ងាត់នេះ បន្ទាប់ពីមហាសន្និបាត១៩៦០-៦១ នេះ?

[១១:៤៩:៥៨]

**ឆ៖** សូមជម្រាបលោកប្រធាន គ្មានអ្នកណារៀបចំទេ គេធ្វើដោយចិត្តគេ គេការពារខ្លួនគេ។ ខ្លួនការពារខ្លួនទៅ។

**ស៖** ខ្ញុំចង់បង្ហាញជូនលោកនូវព្រឹត្តិប័ត្រនៃទស្សនាវដ្តីទង់បដិវត្ត នៅដែលយើងបានដាក់ជូននៅក្នុងខែធ្នូ គឺឯកសារ D243/2.1.9 ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៧៧ គឺទស្សនាវដ្តីទង់បដិវត្ត។ ខ្ញុំមានឯកសារថតចម្លងមួយច្បាប់ ខ្ញុំអាចបង្ហាញជូនជនជាប់ចោទ និងសុំឲ្យយកផ្នែកដែលខ្ញុំដកស្រង់នេះបង្ហាញជូននៅលើអេក្រង់កុំព្យូទ័រ។

សូមការអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**លោក ឌេល លីសាក់៖**

លោកប្រធានលេខ ERN គឺជាភាសាខ្មែរនោះ 00063025 ជាអង់គ្លេស 00191413 និងជាភាសាបារាំង 00504035។

[១១:៥២:៥៨]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក នួន ជា សម្រង់សម្ដីទាក់ទងទៅនឹងអ្វីដែលលោកស្រីចៅក្រម ខាតវ៉ាយថ៍ បានសួរទៅលោកថាតើកងការពារសម្ងាត់ហ្នឹងត្រូវបានរៀបចំឲ្យទៅជាកងកម្លាំងប្រដាប់អាវុធនៅក្នុងឆ្នាំ១៩៦៦ ដោយរបៀបណា? ហើយនៅក្នុងទស្សនាវដ្តីទង់បដិវត្តបាននិយាយអំពីសេចក្ដីសម្រេចដូចខាងក្រោមនេះ៖

ខ្ញុំសូមដកស្រង់សម្ដី "នៅក្នុងឆ្នាំ១៩៦៦ សភាពការណ៍ទំនាស់រវាងបដិវត្តន៍ និងបដិវត្តន៍ប្រឆាំងបដិវត្តន៍កាន់តែខ្លាំងឡើងខ្លាំង។ ដូច្នេះមជ្ឈិមបានសម្រេចថាស្ថានភាពការណ៍នៅកម្ពុជាបដិវត្តន៍មកទំនាស់បដិវត្តន៍កាន់តែខ្លាំងឡើង។ ទំនាស់ស្លាប់រស់កាន់តែខ្លាំងឡើងស្រួចស្រាល់ឡើង។ បក្សត្រូវរៀបចំប្រើអាវុធដើម្បីកម្ទេចខ្មាំង ដើម្បីវាយខ្មាំង"។ តើនេះជាសេចក្ដីថ្លែងការណ៍មួយត្រឹមត្រូវមែន ដែលបានធ្វើឡើងដើម្បីបង្កើតនូវកង អង្គភាពយោធាប្រដាប់អាវុធបន្ទាប់ពីនៅក្នុងឆ្នាំ១៩៦៦ ដូច្នេះមែនទេ?

[១១:៥៤:១៥]

**ឆ៖** សូមជម្រាបលោកប្រធាន ឯកសារនេះ ខ្ញុំដូចខ្ញុំធ្លាប់ជម្រាបហើយ ថាខ្ញុំមិនទទួលទេ ពីព្រោះមិនមែនឯកសារដើម។ ខ្ញុំសូម ខ្ញុំទទូចសុំឯកសារដើម។ ទទូចហើយទទូចទៀត។ ហើយដែលលោកសួរអំមិញអ្នកណាចាត់ចែងអីចាត់ចែងនោះគ្មានអ្នកណាទេ។ ការការពារប្រជាជន គេការពារខ្លួនគេ។ ខ្ញុំលើកឧទាហរណ៍ ដូចជាប៉ូលិសទៅចាប់ទៅចងអី ដោយឥតហេតុ ឥតផលអី ឬទាហានអីទៅអីៗ ប្រជាជន គេការពារគេ ខ្លួនគេទៅ គេរួមគ្នាមកៗ ជួនណាក៏អត់នឹងប្រើអាវុធអីផង មកនិយាយគ្នាដោយស្រួលបួលទៅ។

**ស៖** លោក នួន ជា ខ្ញុំកំពុងនិយាយអំពីឆ្នាំ១៩៦៦ ថាតើត្រឹមត្រូវទេ នៅក្នុងឆ្នាំ១៩៧៦ គណៈមជ្ឈិមបានសម្រេចបង្កើតកងការពារសម្ងាត់ប្រដាប់អាវុធដើម្បីបង្កើតឲ្យទៅជាចលនាប្រដាប់អាវុធកងឈ្លបប្រដាប់អាវុធនោះ?

**ប្រធានអង្គជំនុំ៖**

សូមតំណាង-- សហព្រះរាជអាជ្ញាអន្តរជាតិតាំងសំណួរជាថ្មីម្តងទៀត ពីព្រោះការបកប្រែគឺជាភាសាខ្មែរឆ្នាំ១៩៧៦ តែខ្លឹមសារនៃសំណួរនេះ មិនស្របគ្នាទេ។ ៧៦ ឬក៏៦៦? អ៊ីចឹង កាលបរិច្ឆេទនេះគឺវាខុសគ្នាឆ្ងាយណាស់ នាំឲ្យខ្លឹមសារ វាអត់ឆ្លើយតបទៅនឹងស្ថានការណ៍កាលៈទេសៈ ដែលចង់តាំងសំណួរនេះទេ។ ហើយអ្នកបកប្រែដូចគ្នា សូមប្រយ័ត្នឲ្យបានអតិបរមានូវកាលបរិច្ឆេទនៃសំណួរដែលសួរ ពីព្រោះកាលបរិច្ឆេទនេះ វានាំឲ្យមានបញ្ហាក្នុងការស្តាប់ចម្លើយ ដែលវាផ្ទុយ ឬក៏វាខុសទៅនឹងខ្លឹមសារ និងគោលបំណងនៃការសួរ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សំណួរគឺថាតើនៅក្នុងឆ្នាំ១៩៦៦ មជ្ឈិមបក្សបានសម្រេចបង្កើតកងការពារសម្ងាត់ដើម្បីឲ្យក្លាយទៅជាកងឈ្លបប្រដាប់អាវុធនោះ តើត្រឹមត្រូវទេលោក នួន ជា?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ។ ពីព្រោះខ្ញុំមិនមែនទទួលខាងយោធា។

**ស៖** នៅពេលដែលឯកសារនេះ គឺថាយោងទៅលើព្រឹត្តិការណ៍ក្នុងឆ្នាំ១៩៦៦ ដែលមជ្ឈិមបក្សបានសម្រេចអំពីទំនាស់ស្លាប់រស់កាន់តែស្រួចស្រាល់ៗឡើង ហើយដែលបក្សត្រូវរៀបចំប្រើប្រាស់អាវុធតើមានអ្វីកើតឡើងនៅក្នុងឆ្នាំ១៩៦៦ ដែលនាំឲ្យមជ្ឈិមបក្សឈានទៅដល់ការសម្រេចថា ទំនាស់កាន់តែ

ខ្លាំងៗ ទំនាស់ស្លាប់រស់កាន់តែខ្លាំង និងស្រួចស្រាល់ឡើងបែបនេះ?

**ឆ៖** ខ្ញុំសូមជម្រាបលោកប្រធាន ការរៀបចំចាត់តាំងកងប្រដាប់អាវុធហ្នឹង មិនមែនជាបញ្ហាងាយណ៎ា ទៅប្រមូលមនុស្សឯណា គ្មានទេ។ ដូច្នោះ ប្រជាជនគេការពារខ្លួនគេ គ្មានអ្នកណាទៅចាត់ចែងអីទេ។

[១១:៥៨:៥៩]

**ស៖** លោក នួន ជា សំណួររបស់ខ្ញុំគឺយ៉ាងដូច្នេះទេ ថាតើលោកនៅចាំទេ អ្វីកើតឡើងនៅឆ្នាំ ១៩៦៦ ដែលនាំឱ្យមជ្ឈិមបក្សបង្កើតកងការពារសម្ងាត់ដើម្បីឈានទៅដល់ការបំពាក់អាវុធនេះ?

**ឆ៖** ជម្រាបលោកប្រធាន ដូចខ្ញុំជម្រាបហើយ។ ខ្ញុំៗចាំមិនបានទេ។ ពីព្រោះឈានទៅធ្វើកងការពារបំពាក់អាវុធហ្នឹង វាមិនមែនទៅធ្វើភ្លាមបានភ្លាមឯណា ទៅរកអាវុធនៅឯណា។ ខ្ញុំសួរមើល៍។ បើរដ្ឋអំណាចនៅលើកណ្ដាប់ដៃគេអស់ហើយ។ ដូច្នោះ មានតែរួមសាមគ្គីគ្នាទេ តស៊ូរុលនយោបាយទៅអីទៅ។ រឿងហ្នឹង បើនិយាយឲ្យវែងបន្តិចទៅ វាតាំងពីរឿងចាត់តាំងសមាគមន៍ស្រូវ សមាគមអីៗត្រូវសាមគ្គីគ្នាទៅ អីទៅ ខ្ចីឲ្យៗបុលអីទៅ។ ឯទៅចាត់តាំងកងអាវុធហ្នឹង ទៅយកអាវុធពីណា ពីព្រោះនៅតាមភូមិសុទ្ធតែជីវពលអស់ទៅហើយ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណច្រើន។ ឥឡូវនេះដល់ពេលវេលាសមល្មមនឹងសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ហើយ។ ដូច្នេះអង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់បន្ទប់រង់ចាំនៅខាងក្រោម ហើយនិងឲ្យនាំគាត់ត្រឡប់មកវិញនូវរសៀលនេះឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី។

សូមអញ្ជើញសម្រាកចុះ!

**លោក នួន ជា៖**

សូមស្នើលោកប្រធាន ដោយសុខភាពខ្ញុំមិនអំណោយ ថ្ងៃរសៀលនេះខ្ញុំសូមសម្រាក។ សូមលោកប្រធានអនុញ្ញាត ដូចពីម្សិលមិញអីចឹង។ ពីព្រោះខួរក្បាលខ្ញុំវាធ្វើទុក្ខណាស់។

**ប្រធានអង្គជំនុំ៖**

លោកសូមលះបង់សិទ្ធិមិនចូលរួមដោយផ្ទាល់នៅក្នុងការសវនាការនៅរសៀលនេះ ដោយសូមទៅបន្តការតាមដានដំណើរការសវនាការពីចម្ងាយតាមបន្ទប់នៅខាងក្រោម ដែលមានរៀបចំឧបករណ៍សោតទស្សន៍សម្រាប់លោកតានដានពីចម្ងាយ ឬយ៉ាងម៉េច?

**លោក នួន ជា៖**

នៅខាងក្រោមដែលមាន--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំ។ តែតម្រូវឲ្យមេធាវីការពារក្តីដាក់នូវលិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ ដោយមានការចុះហត្ថលេខា ឬក៏ផ្តិតម្រាមដៃបញ្ជូនមកអង្គជំនុំជម្រះភ្លាម។

**លោក អាង ឧត្តម៖**

សូម--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

[១២:០២:៣៤]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន លោក អៀង សារី ក៏សូមការអនុញ្ញាតចូលរួមសវនាការពីចម្ងាយនៅរសៀលនេះដែរ ដោយសារបញ្ហាសុខភាពរបស់គាត់ ពីព្រោះគាត់បានអង្គុយមួយព្រឹកនេះទ្រាំទ្រអង្គុយយូរហើយ។ សូមលោកប្រធានមេត្តាអនុញ្ញាត។

សូមអរគុណ! ហើយយើងខ្ញុំបាទនឹងដាក់ពាក្យតាមតម្រូវការ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតដូចគ្នា។ បានន័យថា អនុញ្ញាតឲ្យលោក អៀង សារី ដែលបានលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ នៅរសៀលនេះ ដោយទៅបន្តការតាមដានសវនាការនៅពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍នៅបន្ទប់ខាងក្រោម។ ហើយនៅរសៀលនេះសូមឲ្យបង្គាប់ឲ្យខាងអនុរក្ស-- អ៊ំ! ខាងបច្ចេកទេសសោតទស្សន៍សូមបន្តនូវប្រព័ន្ធសោតទស្សន៍

សម្រាប់ជនជាប់ចោទតាមដាននូវកិច្ចដំណើរការសវនាការដេញដោលពីចម្ងាយ។

សូមអញ្ជើញ!

[១២:០៣:៤១]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់ដឹងថា តើនៅរសៀលនេះតើមានការបញ្ជាក់ថា ដើម្បីបណ្តឹងរដ្ឋប្បវេណី ក្លាន រ៉ិត នឹងត្រូវចោទសំណួរដោយភាគីការពារក្តី ហើយបន្ទាប់មកទៀត បន្ទាប់ពីស្តាប់គាត់ហើយនុ៎ង តើយើងនឹងបន្តជាមួយសាក្សីផ្សេងទៀតដែរឬទេ?

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបថា នៅរសៀលនេះ ប្រសិនបើអង្គជំនុំជម្រះសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី ក្លាន រ៉ិត ទៅមានសល់ពេលវេលាសមល្មមនឹងបន្តសវនាការទៀតនោះ អង្គជំនុំជម្រះនឹងបន្តសួរដេញដោលចំពោះជនជាប់ចោទ ខៀវ សំផន។ លើកលែងតែពេលវេលាដែលសេសសល់ហ្នឹងវាតិចតួចពេក នោះអង្គជំនុំជម្រះនឹងសម្រេចតាមស្ថានភាពជាក់ស្តែងនៅរសៀលនេះ។

ដូច្នេះសូមភាគី ហើយនិងសាធារណជនជ្រាប ហើយដោយឡែកមេធាវីការពារក្តី អៀង សារី គឺផ្តល់ឯកសារលះបង់សិទ្ធិមកអង្គជំនុំជម្រះភ្លាម នៅឲ្យបានមុនពេលដំណើរការសវនាការនៅរសៀលនេះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:១៦ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣៣:៣៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមកម្មវិធីដែលបានគ្រោងទុក គឺថ្ងៃនេះបានបន្តការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ក្លាន រ៉ិត ដោយមេធាវីការពារក្តីទាំងបីក្រុម។ ហើយជាដំបូងគេនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅមេធាវីការពារក្តី នួន ជា ដើម្បីមាន

ឱកាសក្នុងការតាំងសំណួរចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើមាន។ សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរទៅលោក ក្លាន វ៉ិត មួយចំនួនប្រហែលជាម្ភៃនាទីប៉ុណ្ណោះ។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក សុន អរុណ៖**

**ស៖** លោក ក្លាន វ៉ិត ខ្ញុំជាមេធាវីការពារលោក នួន ជា។ ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរលោក។ ទីមួយគឺថា នៅឆ្នាំ១៩៦១ ពេលនោះនៅលោកនៅភូមិម៉ាលិក ឃុំម៉ាលិក ស្រុកបរកែវ ខេត្តរតនគិរី អ៊ីចឹងត្រឹមត្រូវទេ?

[១៣:៣៥:៤៣]

**លោក ក្លាន វ៉ិត៖**

**ឆ៖** បាទ, ត្រឹមត្រូវ។

**ស៖** អរគុណ។ លោកបានចូលធ្វើបដិវត្តន៍ ដោយមានលោក តា វី ហៅតា វង់ មកពីខេត្តកំពតដឹកនាំលោកឲ្យចូលក្នុងបដិវត្តន៍។ ត្រឹមត្រូវទេ?

**ឆ៖** បាទ, ត្រឹមត្រូវ។

**ស៖** លោកមានបានយល់ ហើយដឹងមុនថាកាលណាចូលបដិវត្តន៍ អាហ្នឹងមានន័យថាយ៉ាងម៉េច "បដិវត្តន៍" ហ្នឹង? ហើយលោកចង់ចូលខ្លួនឯង ឬក៏គេដឹកនាំហ្នឹងមក ហើយលោកដោយគេបង្ខំ?

**ឆ៖** បាទ, ខ្ញុំសូមឆ្លើយ ដូចជាអ៊ំ វង់ គាត់បង្ខំ។

**ស៖** នៅឆ្នាំ១៩៦១ បើគេបង្ខំ លោកអាចប្រកែកបាន ហេតុម៉េចបានជាលោកមិនប្រកែក ៦១ ដូចមិនទាន់ជា កុម្មុយនីស្តស្រុកខ្មែរយើងមិនទាន់ជាខ្លាំងក្លាណាស់ណាទេ។ ហេតុម៉េចបានជាលោកមិនប្រកែកមិនចង់ធ្វើ?

[១៣:៣៦:៥៩]

**ឆ៖** ខ្ញុំខ្លាច ខ្ញុំអត់ដែលឃើញ គេថាអង្គការខ្មែរមកពីក្រោមធ្វើបដិវត្តន៍ ខ្ញុំខ្លាច អាហ្នឹងខ្ញុំចេះតែតាមគេ ថាឲ្យចូលបក្ស។ បើថាចូលបក្សហើយមានអីអាតំណែងគេចាត់តាំងប្រធានឃុំ ប្រធានស្រុក។ គាត់និយាយឲ្យខ្ញុំអ៊ីចឹង ខ្ញុំខ្លាច ខ្ញុំធ្វើ។

**ស៖** សម័យ១៩៦១ ខ្ញុំក៏ទាន់ដែរសម័យហ្នឹង ខ្ញុំដឹងថាស្រុកខ្មែរទូទាំងប្រទេសបានសុខសប្បាយ មានហូបចុកគ្រប់បែបយ៉ាង មានសន្តិភាព។ ប៉ុន្តែខ្ញុំនៅតែឆ្ងល់ថា ហេតុអីបានជាលោកថាគេបង្ខំលោកឲ្យចូលបដិវត្តន៍ គេតែងតាំងលោកធ្វើជាមេភូមិ មេឃុំហើយ ឬក៏លោកឃើញតំណែងមេឃុំ មេភូមិហ្នឹងលោកចង់ធ្វើ? អ៊ីចឹងដែរអត់ទេ?

**ឆ៖** អត់ទេអ៊ីចឹង។ ជាក់ស្តែងខ្ញុំខ្លាច ខ្លាចខ្ញុំអត់ដែល គេថាអង្គការ អង្គការចេញពីព្រៃ មនុស្សមកពីភ្នំពេញ មកពីក្រុង វានៅព្រៃ វាអប់រំ ពួកខ្ញុំនៅជនបទ។ ពួកខ្ញុំអត់ដែលឃើញ គឺថាអ្នកធ្វើការអង្គការ។ អាហ្នឹងខ្ញុំខ្លាចធ្វើតាមគេ ធ្វើតាមគាត់ ចាត់ចែងឲ្យខ្ញុំធ្វើ។

[១៣:៣៨:៣០]

**ស៖** នៅសំណួរដែលចៅក្រមស៊ើបអង្កេតសួរលោក ក្លាន វ៉ិត លោក ក្លាន វ៉ិត បានឆ្លើយប្រាប់ចៅក្រមថា "នៅឆ្នាំ១៩៧៤ នៅម្តុំប៉ោះប៉យ ស្រុកអូរជុំ ខេត្តរតនគិរី លោក អៀង សារី បានប្រាប់ប្រជាជន និងលោកដែរ ពេលនោះថា ឲ្យឈប់ហៅវៀតណាមថាបងប្អូនវៀតណាមទៀតទៅ ហើយត្រូវហៅថាអាយួនណ្ណាទពាន ព្រោះថាពួកវៀតណាម មកយកទឹកខ្មែរយើងទៅកសាងទ័ពរបស់គេ"។ រឿងនេះពិតជាអ៊ីចឹងមែនទេ?

**ឆ៖** បាទ, មែន អ៊ំ អៀង សារី អប់រំ កាលនោះខ្ញុំធ្វើប្រធានភូមិ។ គាត់ថាមិត្ត វ៉ិត យើងកុំហៅយួនៗ ហៅយួនអីយើងប្រឆាំងបងប្អូនយើង បងប្អូនជីដូនមួយ សាច់ឈាមស្រស់ជាមួយគ្នា លាវ ខ្មែរ វៀតណាម។ យើងបងប្អូនសាច់ឈាមស្រស់ជាមួយគ្នា។ យើងហៅបងប្អូនវៀតណាម អាហ្នឹងវាការយើងស្រឡាញ់រាប់បានគ្នា។ ដល់ចុងក្រោយបំផុតឆ្នាំ៧៥, ៧៩ អ៊ី ៧៦,៧៧ ថា ចោទខ្ញុំចូលបក្សសម្ព័ន្ធវៀតណាម អាហ្នឹងគេចាប់ខ្ញុំមកនៅភ្នំពេញឃុំឃាំង ដោយសារចោទខ្ញុំចូលបក្សសម្ព័ន្ធវៀតណាម។ អ៊ីចឹងរឿងវា។ បាទ, ខ្ញុំអស់ប៉ុណ្ណឹង។

**ស៖** អរគុណ។ អញ្ជើញៗ!

**ឆ៖** បាទ, ប៉ុណ្ណឹងហើយ។ ចប់ប៉ុណ្ណឹងហើយ។

**ស៖** ពេលដែលលោក អៀង សារី ថា យួននឹងយកទឹកដីរបស់យើង។ តើលោកយល់យ៉ាងម៉េច? ហើយក្រោយមកលោកបានឃើញថា យួនហ្នឹងយកទឹករបស់យើងដែរទេ?

**ឆ៖** ក្រោយគាត់ប្រកាសនេះជាក់ស្តែងដល់ឆ្នាំ៧៥ ហ្នឹង ផ្ទុះមែនគ្រាប់កាំភ្លើងនៅព្រំដែនពួកខ្ញុំតាមព្រំដែនមានវ៉ៃគ្នាមែន។ មានកងភូមិភាគនៅបានលុងហ្នឹងទៅវ៉ៃ។ ខ្ញុំថា ពួកឯងទៅវ៉ៃមិនសួរអ៊ំ វង់

ខ្ញុំអត់ទទួលទេ។ ស្រុក បើពួកឯងទៅវ៉ៃយួនហ្នឹង យួនវាដេញមកដល់ទន្លេសេសានហ្នឹង ខ្ញុំទុកប្រជាជននៅឯណា? ខ្ញុំអត់ទទួលទេ។ ទាល់តែពួកឯង សួរគណៈភូមិភាគបានសម្រេច អាហ្នឹងខ្ញុំទទួល បើអង្គការភូមិភាគមិនសម្រេចថា លើប្រកាសថាវ៉ៃជាមួយយួន ខ្ញុំអត់ទទួលទេ។ ខ្ញុំអស់។

[១៣:៤១:២៤]

**ស៖** អរគុណ។ ក្នុងសំណួរដដែលក្នុងឯកសារដដែល។ ត្រង់សំណួររបស់ចៅក្រមស៊ើបអង្កេត ត្រង់សំណួរលេខ១០ ថានៅខែ៧ ឆ្នាំ១៩៧៥ កម្មាភិបាលប្រហែល៨០០នាក់ មកពីឃុំស្រុកតំបន់ និងភូមិភាគផ្សេងៗនៅក្នុងខេត្តរតនគិរីមកប្រជុំនៅបុរីកីឡា។ រយៈពេលប្រជុំនោះ គឺមានបួនថ្ងៃ។ ហើយពីព្រឹកមិញលោកបានឆ្លើយប្រាប់ចៅក្រមស៊ើបអង្កេតដែរថា លោកបានជួបលោក នួន ជា ពីរដង មកធ្វើមហាសន្និបាតពីរដងនៅក្រុងភ្នំពេញ។ អ៊ីចឹងពិតទេ?

**ឆ៖** បាទ, ខ្ញុំឃើញអ៊ំ ពេលប្រជុំនៅភ្នំពេញពីរលើកហ្នឹងហើយ ខ្ញុំឃើញគាត់ ក្រៅពីហ្នឹងអត់ឃើញទេ។

**ស៖** ពេលដែលលោកបានឃើញលោក នួន ជា ហ្នឹងមានភិនភាគយ៉ាងម៉េច? មុខមាត់យ៉ាងម៉េច? រាងរៅយ៉ាងម៉េច?

**ឆ៖** ភិនភាគគាត់ហ្នឹង ធាត់ហើយទាប។ មានបងប្អូនខ្មែរដែរគាត់ប្រាប់ នោះហើយប្រធានបើកវគ្គសាលាយើង ឈ្មោះគាត់អ៊ំ នួន ជា។ ខ្ញុំដឹងពីបងប្អូនយើងដែរ បងប្អូនខ្មែរគេប្រជុំជាមួយគ្នាអាហ្នឹងខ្ញុំបានដឹងស្គាល់ថា អ៊ំ នួន ជា បើពួកគាត់អត់ប្រាប់ ខ្ញុំអត់ដឹងទេ។

**ស៖** លោក ក្លាន វ៉ុត អញ្ជើញមកភ្នំពេញហ្នឹងមកធ្វើមហាសន្និបាត ឬធ្វើសន្និបាទ ឬមកសិក្សា?

**ឆ៖** មកប្រជុំ។

**ស៖** មកប្រជុំ?

**ឆ៖** បាទ។ ប្រជុំបើកវគ្គតាំង ប្រធានឃុំៗ គណៈស្រុក គណៈតំបន់ គ្រប់ប្រទេស ទូទៅប្រទេសកម្ពុជាយើងទាំងអស់។ អាហ្នឹងបាន វាច្រើន។

**ស៖** បើតាមចម្លើយរបស់លោកប្រាប់ចៅក្រមស៊ើបអង្កេត លោកថា នួន ជា អ្នកដឹកនាំ និងនិយាយពេលប្រជុំនោះ មានសំឡេងតូច មុខធំ ហើយវាល មិនដឹងមានន័យថាម៉េចទេ? ហើយវាល ធាត់ទាប។ លោកឆ្លើយប្រាប់ចៅក្រមស៊ើបអង្កេតថាអ៊ីចឹង។ អ៊ីចឹងមែនទេ ឬយ៉ាងម៉េច? លោកអាចកែប្រែឬក៏យ៉ាងម៉េចទៀត តាមលោកចំណាំមក។

[១៣:៤៤:១៣]

**ឆ៖** ខ្ញុំឃើញជាក់ស្តែង គឺថានោះហើយអ៊ំ នួន ជា យើង ប្រធានសាលាបើកវគ្គទូទាំងប្រទេសកម្ពុជាយើងអ៊ីចឹងបាទ។

**ស៖** តាំងពីលោកចូលទៅក្នុងកុម្មុយនីស្តខ្មែរមក លោកដែលជួប ប៉ុល ពត ទេ?

**ឆ៖** បាទជួប អ៊ំនោះធ្លាប់នៅនោះជាមួយពួកខ្ញុំនៅនោះ។ ដែលឃើញអ៊ំ ពត, អ៊ំ អៀង សារី, តា យ៉ា, តា វី បួននាក់ហ្នឹងធ្លាប់នៅភូមិភាគព្លសានពួកយើងខ្ញុំ។ អ៊ំ នួន ជា, អ៊ំ ខៀវ សំផន មិនដែលឃើញទេ។ អ៊ំ នួន ជា ឃើញតែពេលមកប្រជុំពីរលើកនៅភ្នំពេញនោះ ខ្ញុំឃើញអ៊ំ នួន ជា និយាយស្មោះត្រង់។

**ស៖** អ៊ីចឹង លោកបាន ជួប ប៉ុល ពត កាលពី ប៉ុល ពត ទៅតាំងទីតាំងនៅរតនគិរីអ៊ីចឹងន៎ែ?

**ឆ៖** បាទ, កាលនោះនៅព្រៃ។

**ស៖** លោក ប៉ុល ពត ហ្នឹងរាងរៅយ៉ាងម៉េច?

**ឆ៖** *(មីក្រូហ្វូនមិនដំណើរការ)*

**ប្រធានអង្គជំនុំ៖**

អ្នកអង្គុយនោះ ម៉េចអត់មានចុចក្បាលមីក្រូហ្វូន?

**លោក ក្លាន វ៉ិត៖**

**ឆ៖** ពោះគាត់ធំ ក្បាលគាត់តូច។ ពួកអ្នករាជការមកទីនេះ មកសួរពួកខ្ញុំអ៊ីចឹងដែរ ពួកទាហាន លន់ នល់ ថាបងប្អូនឃើញដែរ ជនជាតិខ្មែរក្បាលវាតូច ពោះវាធំ។ ពួកនោះពួកចេញមកពីភ្នំពេញ។ វាចលនាធ្វើជាមួយខ្មែរក្រហម។ ឃើញដែរ? ខ្ញុំអត់ឃើញទេ អត់ដឹងទេ អត់ដឹងដែរ។ ពួកខាង លន់ នល់ គេប្រាប់អ៊ីចឹងដែរ ជាក់ស្តែងខ្ញុំសែងគាត់ហ្នឹងឡើងភ្នំចុះភ្នំអ៊ីចឹងដែរ ពោះគាត់ធំ ក្បាលគាត់តូច ភ្លៅគាត់ធំ។ សែង ចេះតែសែងរហូតឡើងភ្នំចុះភ្នំ។ វាព្រៃ វាមានអន្ទាក់វាមានអី មានព្រៃគ្រប់ច្រក។

[១៣:៤៦:២០]

**ស៖** សូមអរគុណ។ លោកបានឆ្លើយជម្រាបប្រាប់ទៅខាងចៅក្រមស៊ើបអង្កេតបន្តទៅទៀតថា លោកបានផ្លាស់ប្តូរទីកន្លែងញឹកញាប់ កាលពីលោកនៅស្រុកនៅឡើយ ដោយសារលោកខ្លាចយួនវ៉ៃ តើរឿងហ្នឹងវាប្រាកដជា-- ឬមានរឿងអ៊ីចឹងកើតឡើងពេលក្រោយមកទេ ដែលលោកឆ្លើយថាលោកខ្លាចយួនវ៉ៃ?

**ធ៖** បាទ, អ៊ីចឹងមែន។

**ស៖** នៅក្នុងឯកសារ D22/42 ត្រង់ទំព័រផ្នែក ខ ក្រោយពេលរបបកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៧៥ លោករស់នៅកន្លែងណា?

**ធ៖** នៅភូមិអ៊ិន ឃុំតាឡាវ ស្រុកអណ្តូងមាស។

**ស៖** នៅពេលនេះ លោកបានឃើញទេការជម្លៀសខ្លួនរបស់ប្រជាពលរដ្ឋចេញពីទីក្រុងផ្សេងៗមានចូលទៅតំបន់ដែលលោករស់នៅទេ?

[១៣:៤៧:៤៥]

**ធ៖** នៅស្រុកឃុំពួកខ្ញុំអត់ឃើញ ប៉ុន្តែនៅឃុំគេផ្សេងឃើញៗបងប្អូនមកពីក្រោមគេជម្លៀស។ នេះនៅជាប់ដល់សព្វថ្ងៃខាងនេះៗ ខាងនេះអាទន្លេស្រែពក។ ភូមិនេះតូច ដល់គេជម្លៀសមកកម្លាំងមកពីភ្នំពេញបាន៨០០ អានេះឃើញជាក់ស្តែងខ្ញុំចុះ។ អានេះភូមិនេះពីដើមគេថាតិច ១៥៥នាក់។ ឥឡូវគេធ្វើសហករណ៍គេយកបងប្អូនជម្លៀសមក មនុស្សមកពីភ្នំពេញ អាហ្នឹងវាបាន ៨០០នាក់។ អាទីពីរ អាទីបី អាមួយ អាទីពីរទៀតនៅភូមិស្រែគរ ខេត្តស្ទឹងត្រែង នៅស្រែគរនេះ ជនជាតិលាវ មានគេដាក់បងប្អូនមកពីក្រោមនេះមានប៉ុន្មាន មាន៩០០នាក់ ទៅនៅនោះ។ ខ្ញុំឃើញជាក់ស្តែង ពីរកន្លែងហ្នឹង។

[១៣:៤៨:៣៨]

**ស៖** បាទអរគុណ។ ពេលដែលលោកបានឃើញអ្នកទីក្រុងទៅនៅជនបទអ៊ីចឹង តើឃើញសកម្មភាពរបស់ខ្មែរក្រហមជាមួយនឹងអ្នកទោសថ្មីហ្នឹង គេហៅ អ្នកថ្មី ហ្នឹង មាន គេធ្វើយ៉ាងម៉េចជាមួយអ្នកថ្មីហ្នឹង? មានបានឃើញនឹងភ្នែកទេ?

**ធ៖** អារឿងនោះជាក់ស្តែង ខ្ញុំឃើញនៅពេលខ្ញុំទៅប្រជុំ។ គេហៅទៅប្រជុំធ្វើទំនប់ ជាក់ស្តែងនៅស្រែគរហ្នឹង។ ខ្ញុំធ្វើទំនប់ហ្នឹងប្រាំពីរថ្ងៃ ប្រជុំតែពីរថ្ងៃ ធ្វើទំនប់ប្រាំពីរថ្ងៃ។ ជាក់ស្តែងមានបងប្អូនមិនដឹងមនុស្សថ្មី មិនដឹងមនុស្សចាស់ គេធ្វើរួមមនុស្ស ៨០០, ៩០០ ម្តងៗលើកភ្លឺនោះ ធ្វើទំនប់នៅស្រែគរហ្នឹង។ អ៊ំ វ៉ង់ នៅផ្ទាល់នៅស្រែគរហ្នឹង អ៊ំ វ៉ង់ ឈ្មោះ តា វីៗ ហ្នឹង គណៈភូមិភាគហ្នឹង។ គាត់ហ្នឹងហើយហៅពួកខ្ញុំប្រជុំ។ ប្រជុំហ្នឹងជាក់ស្តែងពីរថ្ងៃ អាធ្វើទំនប់ប្រាំពីរថ្ងៃ។ ថ្ងៃក៏ធ្វើយប់ក៏ធ្វើ។ យប់តាំងពីម៉ោងៗប្រាំមួយ ម៉ោងប្រាំហូបបាយ ម៉ោងប្រាំមួយចុះពលកម្ម យកចបកាប់ដី លើកទំនប់ដល់ម៉ោងប្រាំបួនបានសម្រាកដេក។ អាហ្នឹង ខ្ញុំឃើញជាក់ស្តែងនៅស្រែគរ។ ភូមិនេះមិនធំទេភូមិស្រែគរ ដោយសារវាមាន-- វាដឹងបើចង់បានប្រាំបីប្រាំបួនរយបងប្អូនមកពីក្រោម ខ្ញុំឮប្រធានភូមិគេ

ឈ្មោះ ដាំ គាត់ប្រាប់។ ភូមិខ្ញុំតូចទេ ប្អូនពីដើម ឥឡូវគេជម្លៀសបងប្អូនមកពីក្រោមបានវាច្រើន វាចូលនៅក្នុងភូមិស្រែគរនេះ។ អានេះជាក់ស្ដែង។

អ៊ំរង់ នៅផ្ទាល់នឹងស្រែគរនុ៎ង ធ្វើទំនប់ នេះទំនប់សព្វថ្ងៃនៅតើ។ សូមចប់។

**ស៖** ពេលដែលលោកទៅនៅភូមិទាំងពីរហ្នឹង រស់នៅបានប៉ុន្មានថ្ងៃនៅភូមិមួយៗ?

[១៣:៥០:៤២]

**ឆ៖** នៅភូមិស្រែគរ លើកទំនប់៧ថ្ងៃ គេប្រជុំរៀនសូត្រ២ថ្ងៃ អានេះជាក់ស្ដែង។ នៅភូមិជាប់នេះ ឃើញជាក់ស្ដែងពួកខ្ញុំសម្រាកហូបបាយនៅនោះ ពីព្រោះខ្ញុំចុះមកពីខេត្តរតនគិរី មកប្រជុំចុះប្រជុំនៅនេះនៅភ្នំពេញហ្នឹងហូបបាយនៅនោះ នោះបានឃើញមានបងប្អូនគេជជែកគ្នាថា ភូមិនេះបានច្រើនកម្លាំងៗគេជម្លៀសមកពីក្រោម ហ្នឹងបានច្រើនភូមិនេះតូច។ នេះភូមិជាប់សព្វថ្ងៃនេះ ខាងនេះស្រែពក។

**ស៖** អរគុណណាស់។ ពេលដែលលោករស់នៅនឹង៧ថ្ងៃមួយកន្លែងហ្នឹង តើលោកមានឃើញទិដ្ឋភាពយ៉ាងម៉េចទេ គេកាប់សម្លាប់ ឬក៏ប្រជាជនដែលទៅពីក្រុងទៅហ្នឹងៗធ្វើការនឿយហត់ស្លាប់អត់បាយ អត់ម្ហូប អត់អីអ៊ីចឹងទេ? អ៊ីចឹងពិតមែនទេ ឬក៏គេមានហូបអីបរិបូរ?

**ឆ៖** បាទរឿងជាក់ស្ដែងខ្ញុំ មិននៅផ្ទាល់ទេ ព្រោះខ្ញុំអាពេលពលកម្មៗរួមជាមួយគេ អាកន្លែងរស់នៅខ្ញុំនៅតាមមាត់ទន្លេ។ គេថានៅ៧ៗ មន្ទីរអង្គការភូមិភាគអានេះគេថា៧ ប្រជាជននោះចេញមកពីភូមិ ហើយការងារសកម្មភាពគេល្អមិនល្អ ខ្ញុំអត់ឃើញជាក់ស្ដែងទេ។ ឃើញកម្លាំងពេលវេលាលើកទំនប់លើកដីនោះ អាហ្នឹងឃើញគ្នា។

**ស៖** សូមអរគុណណាស់។ នៅខែកញ្ញា ឆ្នាំ១៩៧៨ លោកត្រូវបានតាខេង ជាប្រធានកងពលភូមិភាគព្រៃសាន និងអង្គរក្សម្នាក់ទៀតឈ្មោះ មិត មាន រួមជាមួយអ្នកបើកបរកាណូតពីរនាក់ និងអ្នកដទៃទៀតមួយចំនួនទៀតបានទៅដល់ភ្នំពេញ តើលោកចាំទេពេលនោះ?

[១៣:៥២:៣៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបារម្ភថាខ្លាចមិនបានស្ដាប់ឮសំណួរទាំងអស់របស់សហភាតា

របស់ខ្ញុំនេះ ក៏ប៉ុន្តែសំណួរអម្បាញ់មិញនេះ គឺថាផ្តោតទៅលើព្រឹត្តិការណ៍ដែលភាគីផ្សេងៗទៀតនោះ មិនបានចោទសំណួរនោះទេ អ៊ីចឹងយើងចង់ឲ្យគាត់នោះកំណត់សំណួរមកត្រឹមតែលើវគ្គទីមួយនៃការជម្រះសេចក្តីបានហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ ប៉ុន្តែការជំទាស់ហ្នឹងគ្មានប្រសិទ្ធភាពទេ គឺការសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សី មិនមែនកំហិតត្រឹមវិសាលភាពនៃអង្គហេតុសម្រាប់ធ្វើសវនាការវគ្គទីមួយទេ គឺក្នុងក្របខណ្ឌវិសាលនៃអង្គហេតុ យកមកធ្វើនៅសវនាការដំបូង ដែលអង្គជំនុំជម្រះបានកំណត់ហើយ ដែលយើងបានហៅម្យ៉ាងទៀតថា សំណុំរឿងលេខ ០០២/០១។ អ៊ីចឹងការសួរក្របខណ្ឌវិសាលភាពនៃការសួរដេញដោលចំពោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីវាខុសពីការសួរចម្លើយជនជាប់ចោទៗទេ ដែលយើងកំហិតត្រឹមវគ្គទីមួយ អង្គហេតុដែលកំណត់សម្រាប់ធ្វើវគ្គទីមួយអំពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា។

លោក ក្លាន រ៉ិត អាចឆ្លើយនឹងសំណួរអំមិញបានទេ ឬក៏ត្រូវការឲ្យមេធាវីសួរសំណួរ-- តាំងសំណួរសាជាថ្មីម្តងទៀត?

**លោក ក្លាន រ៉ិត៖**

បាទបើសួរថ្មីដូចខ្ញុំនិយាយអំមិញហើយ។

[១៣:៥៤:៤១]

**សួរដោយលោក សុន អរុណ៖**

**ស៖** បើអ៊ីចឹងមានន័យថា លោកមកដល់ មកភ្នំពេញជាមួយក្រុមប៉ុន្មាននាក់ដែលខ្ញុំបានជម្រាបអំមិញអ៊ីចឹង? អាហ្នឹងមកដល់ភ្នំពេញមែនអ៊ីចឹងទេណា? អ៊ីចឹងហ្អែនៅខែកញ្ញា ឆ្នាំ១៩៧៨ លោកបានមកដល់ភ្នំពេញ?

**ឆ៖** តាខេង ហ្នឹងហើយយកពួកខ្ញុំមក។ ពួកខ្ញុំ១២នាក់ តាខេងយកមក ម៉ោងបួនចេញពីស្ទឹងត្រែង ពួកខ្ញុំ ១២នាក់ដល់ភ្នំពេញ។ ដល់ភ្នំពេញព្រឹកព្រលឹម មិនទាន់ហូបបបរឃើញឡានគេមកដាក់ទង់ក្រហម។ គេហៅឈ្មោះ អ៊ំរ៉ន, តាប៉យ, តាឆុម ពីណាម្នាក់ទៀត? បួននាក់ តាយ៉ង់។ ហៅពួកគាត់ថា ពួកអ៊ំៗ ពួកខ្ញុំមកយកពួកអ៊ំបួននាក់ឈ្មោះនេះ ឈ្មោះអ៊ំរ៉ន, ឈ្មោះតាប៉យ, ឈ្មោះតាយ៉ង់, ឈ្មោះតាឆុម ឡើងឡាន។ ពួកនោះ នៅស្ងៀម។ គាត់ខឹងយ៉ាងម៉េច អានឈ្មោះពួកអ៊ំៗអត់ដឹងឈ្មោះ

ខ្លួនឯង គាត់ថាឲ្យឡើងឡាន មិនឲ្យឡើងឡាន។  មានម្នាក់ ឆុម គាត់ថា ម៉េចឡើងឡានៗ? ពួកខ្ញុំដែលប្រជុំមុននុំងទៅទាំងអស់ ២០ទៅ២០, ៣០ទៅអស់៣០។ ឥឡូវម៉េចក៏ត្រូវការពួកខ្ញុំ១២នាក់ ហៅពួកខ្ញុំបួននាក់ទៅ។ អាហ្នឹងពួកខ្ញុំល្ងើល្ងើ។

គាត់ឆ្លើយថា ពួកតាកុងឡាន ពួកមកយកនោះថា សភាពការណ៍ឥឡូវវាមិនដូចពីដើមទេ។ គេត្រូវអ្នកណា អ្នកនោះទៅមុន អ្នកណាគេមិនត្រូវការគេទុកក្រោយ។ ពួកនោះឡើងយកអីវ៉ាន់ទៅស្រក់ទឹកភ្នែកស្រក់អី ឡើងឡានទៅប្រុយ។ អានេះឃើញជាក់ស្តែង។ តាខេង ជូនដំណើរហើយត្រឡប់ទៅវិញស្ទឹងត្រែង។ បាទពិត។

[១៣:៥៦:៣៦]

**ស៖** សូមអរគុណណាស់ ចម្លើយ។ ប៉ុន្តែចង់សួរចម្លើយមកដល់ភ្នំពេញដែលហ្នឹង ថាលោកមកដល់ភ្នំពេញ គេយកបួននាក់ទៅ ប៉ុន្តែលោកឃើញទិដ្ឋភាពទូទៅនៅភ្នំពេញហ្នឹង ក្រៅពីរឿងដូចលោកក្លាន វ៉ិត និយាយអំមិញអ៊ីចឹង ក្រៅពីរឿងហ្នឹង លោកឃើញទិដ្ឋភាពទូទៅក្នុងក្រុងភ្នំពេញហ្នឹងស្ងាត់ជ្រងំឬក៏អ៊ូអរធម្មតាដូចលោកដឹងពីមុនមក?

**ឆ៖** បាទ អត់អ៊ូអរទេ ស្ងាត់ ស្ងាត់ឈឹង។ ឃើញតែមនុស្សដាំបាយឲ្យពួកខ្ញុំ ឃើញតែមនុស្សគេប្រចាំឃ្លាំង មានតែប៉ុណ្ណឹងទេ។ ក្រៅពីហ្នឹងអត់ឃើញទេមនុស្ស។ អត់មានឮឡាន ឮម៉ូតូ ឮអីសោះ។ ចប់។

**ស៖** ពេលដែលលោកមកដល់ភ្នំពេញ លោកមានប្រសាសន៍ លោកនិយាយអំមិញហើយថា គេយកគ្នាបួននាក់ដាក់ឡានៗទ្រុងមួយ។ នៅពេលនោះ លោកឃើញអ្វីខ្លះទេ ក្រៅពីដែលគេយក ពេលដែលលោកទៅដល់ គេយកលោកទៅដាក់ទួលស្លែង អ៊ីចឹងអ្វី? គេយកលោកទាំងបួននាក់ហ្នឹងទៅដាក់ទួលស្លែង។ អ៊ីចឹងអត់ទេ?

**ឆ៖** អារឿងជាក់ស្តែងអត់ឃើញទេ។ ឃើញគេឡើងឡាន គេយកទៅប្រុយ។ មិនដឹងទៅដាក់ទួលស្លែង មិនដឹងជាដាក់ឯណាបើអត់ឃើញ។ ប៉ុន្តែខ្ញុំ ពួកខ្ញុំនៅឯនោះហើយ ព្រោះពេលហូបបាយគេយកពួកខ្ញុំទៅនៅផ្សេងទៀត នៅកន្លែងគឺថា មន្ទីរភូមិភាគពិ្លសាន។ ហើយឲ្យពួកនេះទៅហើយ គេយកពួកនេះទៅបួននាក់ ហើយហូបបាយគេឲ្យពួកខ្ញុំទៅនៅផ្សេងទៀត។

[១៣:៥៨:២៧]

**ស៖** សូមអរគុណណាស់។ នៅថ្ងៃ-- នៅឯកសារលេខ D22/42 នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ វេលាម៉ោងប្រាំមួយព្រឹក ត្រង់ឃ្លាមួយថា បន្ទាប់មកខ្ញុំក៏ឮសំឡេងមីក្រូប្រកាសថា បន្តិចទៀតនេះ ពួកអីៗធ្វើដំណើរទៅប្រទេសក្រៅហើយ តើសម្ដីរបស់លោកឆ្លើយប្រាប់សហចៅក្រមស៊ើបអង្កេតនេះ លោកមានន័យថាយ៉ាងម៉េច? លោកយល់ថាម៉េចបានប្រាប់គេថា អីៗគេធ្វើដំណើរទៅប្រទេសក្រៅហើយ។ អាហ្នឹងមានន័យថាម៉េច? លោកអាចពន្យល់បាន តុលាការបានទេ?

**ឆ៖** បាទអារឿងនោះអ៊ីចេះ។ ពួកអ៊ំៗហ្នឹងគាត់ចេញពីភ្នំពេញ គាត់ហៅពួកខ្ញុំប្រជុំ។ គាត់ប្រជុំសាមសិបនាទី។ គាត់ថា បងប្អូនឥឡូវយើងសារភាពប្រាប់យួនហើយ។ យួនមិនដឹងថ្ងៃណាវា ថ្ងៃប្រាំខែមួយ ៧៩ មិនដឹងថ្ងៃណា។ ឥឡូវយើងសារភាពប្រាប់យួនហើយណ៎ា បងប្អូនយើង។ ពួកខ្ញុំអត់នៅនេះហើយ ចេញទៅក្រៅហើយ បងប្អូននៅនេះ ធ្វើយ៉ាងម៉េចកុំប្រកែប្រកាន់ជាមួយគេណ៎ា គេឲ្យធ្វើស្អីធ្វើ យើងត្រឡប់ទៅវិញតស៊ូនយោបាយទៀត។ យើងសារភាពគេបណ្ដោះអាសន្ន ស្អែកយើងតស៊ូ។ តស៊ូជាមួយៗយួន។ អ៊ីចឹងដល់ព្រឹកស្អែកព្រលឹម គាត់ជិះយន្តហោះទៅ ខ្ញុំឡើងដំបូលផ្ទះហ្នឹង ខ្ញុំឃើញគេជិះយន្តហោះទៅនោះ ទៅក្រោម។ យន្តហោះពីរគ្រឿង កន្ទុំរុយ ជាក់ស្ដែង។ បាទអស់។

**ស៖** លោកដឹងថាអ្នកជិះយន្តហោះហ្នឹងអ្នកណាទេ? ប្រហាក់ប្រហែល ឬស្មានថាអ្នកណាទេជិះយន្តហោះពីរបីគ្រឿងហ្នឹងទៅ?

**ឆ៖** ស្មានអី ពួកអ៊ំគាត់ប្រាប់ហើយ។ ពួកអ៊ំ ពត, អ៊ំ អៀង សារី ហ្នឹង គាត់ប្រាប់អង្គរក្សគាត់យ៉ំ។ អាកែន, វ៉ែន, វ៉ន អង្គរក្សរបស់គាត់នុ៎ង កាលនៅព្រៃហ្នឹង។ ប៉ាន់កូនខ្លួនឯងបង្កើតហ្នឹង រៀបចំកន្លែងរស់នៅរបស់គាត់ ដុតភ្លើងដុតអី រកខសរកអី។ ដល់គេទៅហ្នឹង ពួកគាត់បីនាក់ហ្នឹងយ៉ំ កែន, វ៉ែន, វ៉ន ជនជាតិ។ ជនជាតិទំពួនពីរនាក់ ជនជាតិគ្រឹងមួយនាក់។ អង្គរក្សគាត់យ៉ំៗចង់ទៅតាម ពួកអ៊ំថាអ៊ូកូនៗក្មួយៗទៅតាមពួកខ្ញុំអត់មានភារកិច្ចហើយ ពួកខ្ញុំ។ ពួកកូននៅនេះហើយៗនៅជាមួយគេនៅនេះជាក់ស្ដែង។ អាហ្នឹងមិនមែនស្មានទេ ដឹងពិតប្រាកដអ៊ីចឹងហើយ ខ្ញុំស្មានថាពួកអាយន្តហោះពួកគាត់អ៊ីចឹង។

[១៤:០១:២១]

**ស៖** សូមអរគុណណាស់ នេះជាសំណួរចុងក្រោយរបស់ខ្ញុំ។ លោក ក្លាន វិត បានប្ដឹងមេៗខ្មែរក្រហមដែលជាប់ឃុំឃាំងឥឡូវនេះ។ តើលោកមានបំណងអ្វី?

**ឆ៖** ប្ដឹងអី មិនមែនប្ដឹងទេ ជាក់ស្ដែងប្រាប់ គេសួរ អង្គការសួរចេះតែប្រាប់ហ្នឹងហើយ ការជាក់ស្ដែង។ មិនមែនរករឿងរកហេតុឱ្យគេ អីៗតាៗទេ ព្រោះជាក់ស្ដែង ព្រោះខ្ញុំកូនគាត់ ចៅគាត់។ ខ្ញុំប្រាប់ដោយការជាក់ស្ដែង។ ឧទាហរណ៍ដូចពួកខ្ញុំកូនគាត់ កូនគាត់ហើយ ពួកគាត់ហើយចាត់តាំងធ្វើប្រធានភូមិ ប្រធានឃុំ ប្រធានស្រុក ប្រធានតំបន់ ពួកគាត់ហើយ។ ដល់ក្រោយចុងបំផុតថាចូលបក្សសម្ព័ន្ធយុវជន។ ខ្ញុំថាបើខ្ញុំចូលបក្សសម្ព័ន្ធយុវជន អីហ្នឹងហើយអ្នកប្រធានចូលបក្សសម្ព័ន្ធយុវជនហ្នឹង។ អីអត់ដឹងទេ ម៉ែខ្ញុំ ពុកខ្ញុំបង្កើតអត់ដឹងថាចូលបក្សនោះ បក្សនេះ ចេះតែកាន់ផ្ដាក់ធ្វើចម្ការ ចេះតែធ្វើខ្ទមចេះតែធ្វើវា ធ្វើអន្ទាក់។ ឥឡូវដោយថាអង្គការចលនាឱ្យធ្វើខ្ញុំបដិវត្តន៍ហ្នឹង ដឹងថាឱ្យចូលបក្ស បើចូលបក្សបានហើយ អាហ្នឹងពេញសិទ្ធិចាត់តាំងប្រធានភូមិ ប្រធានឃុំ ប្រធានស្រុកអីចឹង។ អាហ្នឹងខ្ញុំឆ្លើយអីចឹង។

**ស៖** អ៊ំមិញលោកឆ្លើយថា លោកមិនប្ដឹង នួន ជា មិនប្ដឹង ខៀវ សំផន មិនប្ដឹង អៀង សារីទេ។ មិញថាអីចឹងណ៎ា។ ប៉ុនឥឡូវលោកជាដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសួរថាលោកប្ដឹងហ្នឹងដើម្បីអ្វី? លោកចង់បានអី?

**ឆ៖** ចង់បានអី ចង់បានរស់។ ឧទាហរណ៍ដូចខ្ញុំឈឺ ខ្ញុំចង់បានរស់ បើថាការអាក្រក់ការស្អីដូចធ្វើ មិនមែនធ្វើខ្លួនឯង។ ធ្វើដោយសារអីៗតាៗហ្នឹងហើយ នាំខ្ញុំធ្វើ។ ដល់ចុងបំផុតថាមិនល្អទៀត។ អាហ្នឹងខ្ញុំខឹង។

**លោក សុន អរុណ៖**

ខ្ញុំអស់សំណួរហើយ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកមេធាវី។ ជាកិច្ចបន្ត អង្គជំនុំជម្រះប្រគល់វេទិកាទៅក្រុមមេធាវីការពារក្ដីលោក អៀង សារី ដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើមាន។ សូមអញ្ជើញ!

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន និងសូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រមសមាជិក សូមគោរពអង្គសវនាការទាំងមូល។ ហើយសួស្ដីលោក ក្លាន រ៉ិត។ ខ្ញុំ អាង ឧត្តម ជាមេធាវីការពារក្ដី ជាសហមេធាវីការពារក្ដីរបស់លោក អៀង សារី។ ហើយសុំសួរសំណួរលោកមួយចំនួន។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** សំណួរជាបឋមរបស់ខ្ញុំ ខ្ញុំចង់សួរលោកថា មកទល់ពេលនេះ ឬចាប់ផ្ដើមពីពេលណាមក លោកចេះអាន និងចេះសរសេរភាសាខ្មែរទេ នៅពេលនេះ?

[១៤:០៤:៥១]

**លោក ក្លាន វ៉ិត៖**

**ឆ៖** បាទ ខ្ញុំអត់ចេះទេ ខ្ញុំអត់បានរៀន ខ្ញុំអត់ចេះ។

**ស៖** មុននឹងមកឆ្លើយសំណួរទាំងឡាយនៅតុលាការនេះ តើមានអ្នកណាបានអានឯកសារអ្វី ដើម្បីរំឭកដល់លោកក្នុងការត្រៀមមកចូលរួមឆ្លើយសំណួរនៅពេលសវនាការនេះទេ?

**ឆ៖** អត់ពីណាអានត្រៀមទេ ដោយសារខ្ញុំស្ដាប់ខ្លួនឯង ជាក់ស្ដែងការធ្វើ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំមានឯកសារបី ទាក់ទងឯកសារបីដើម្បីសួរលោក។ នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៨ លោកបានផ្ដល់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មែនទេ?

**ឆ៖** ខ្ញុំអត់យល់។ តាំងពាក្យរដ្ឋប្បវេណី ខ្ញុំអត់យល់។ ខ្ញុំអត់យល់ខ្មែរ ពាក្យខ្មែរ ខ្ញុំអត់យល់។ អត់ដឹង។

**ស៖** ខ្ញុំសូមសួរលោកបន្តទៀតថា លោកបានដាក់ពាក្យប្ដឹងទេ?

**ឆ៖** ខ្ញុំសូមឆ្លើយ ដូចខ្ញុំនិយាយអំមិញ។ អត់មានការពាក្យបណ្ដឹងទេ ដោយសារអង្គការគេសួរ គេសួរ ខ្ញុំចំណាំការងារធ្វើជាមួយពួកអ៊ំៗ យ៉ាងម៉េចខ្ញុំប្រាប់ឲ្យគេដឹងអ៊ីចឹង។

**ស៖** នៅក្នុងពាក្យបណ្ដឹងសុំតាំងខ្លួនដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៨ ហ្នឹង លោកបានផ្ដល់ព័ត៌មានទាំងឡាយនៅចំពោះមុខមេធាវីផង ពិតមែនទេ?

**ឆ៖** បាទ ពិត គេសួរ។ អត់លាក់លៀមទេ គេសួរ ខ្ញុំប្រាប់។ ខុសត្រូវ ខ្ញុំអត់ដឹង តែខ្ញុំដឹង ខ្ញុំធ្វើ ខ្ញុំប្រាប់ការងារខ្ញុំធ្វើជាមួយពួកអ៊ំៗ។

**ស៖** សូមអរគុណ។ នៅលើឯកសារនុ៎ង តើលោកបានចុះហត្ថលេខា ឬបានផ្ដិតមេដៃ មែនទេ?

**ឆ៖** បាទ បានៗផ្ដិតមេដៃ ចុះហត្ថលេខាមែន។

**ស៖** អ៊ីចឹង លោកទទួលស្គាល់ថា ឯកសារហ្នឹង វាត្រឹមត្រូវ ពិតប្រាកដ និងពេញលេញ មែនទេ?

**ឆ៖** បាទ រឿងហ្នឹង ត្រឹមត្រូវ មិនត្រឹមត្រូវ ខ្ញុំអត់ដឹងទេ។ ខ្ញុំអត់ចេះអក្សរ ខ្ញុំគោរពគេ ខ្ញុំខ្លាច។ មនុស្សណាចេះតែខ្ញុំខ្លាច គេឲ្យធ្វើស្អីធ្វើការជាក់ស្ដែង។ ការពិត ខ្ញុំមិនមែនខ្ញុំកុហក មិនមែនថាខ្ញុំរករឿងរកហេតុឲ្យគេទេ ការជាក់ស្ដែងពិត។

[១៤:០៨:៣៤]

**ស៖** សូមអរគុណ។ ឯកសារមួយទៀត គឺនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០៩ លោកបានផ្ដល់កិច្ចសម្ភាសន៍ដល់អ្នកស៊ើបអង្កេតរបស់សាលាក្ដីខ្មែរក្រហម តើមែនទេ?

**ឆ៖** បាទ មែន។

**ស៖** សូមអរគុណ។ ហើយក៏បានមានធ្វើកំណត់ហេតុនៃកិច្ចសម្ភាសន៍ លោកបានផ្ដល់កំណត់ហេតុនៃកិច្ចសម្ភាសន៍ហ្នឹងដែរ មែនទេ?

**ឆ៖** អារឿងកំណត់ ខ្ញុំអត់មានកំណត់។ ខ្ញុំប្រាប់តែការងារធ្វើជាក់ស្ដែង។ ខ្ញុំអត់កំណត់ខែ កំណត់ឆ្នាំ កំណត់រឿងខ្ពស់ រឿងធំ រឿងតូចទេ។ កាលហ្នឹង ខ្ញុំរាយការណ៍ ការស្មោះត្រង់ខ្ញុំធ្វើជាក់ស្ដែង។

[១៤:០៩:៥០]

**ស៖** ឯកសារទាំងហ្នឹង គេបានអានឲ្យលោកស្ដាប់ ហើយលោកក៏បានបញ្ជាក់ថា លោកអត់មានជំទាស់នឹងឯកសារដែលទាំងនោះទេ មែនទេ?

**ឆ៖** បាទ អត់មានទំនាស់ ការជាក់ស្ដែងអត់មានជំទាស់។

**ស៖** អ៊ីចឹងលោកក៏បានចុះហត្ថលេខា ឬផ្ដិតមេដៃលើឯកសារនុ៎ង មែនទេ?

**ឆ៖** មែនហើយ។

**ស៖** សូមអរគុណ។ អ៊ីចឹងបានន័យថា លោកបានយល់ព្រមទៅលើឯកសារនេះ ថាវាពិត វាត្រឹមត្រូវវាពេញលេញ។ មែនទេ?

**ឆ៖** ត្រឹមត្រូវៗ ការជាក់ស្ដែង។ ការងារធ្វើ ការងារស្ដាប់ ការងារឃើញ។

[១៤:១០:៤៨]

**ស៖** សូមអរគុណ។ ឯកសារមួយទៀត គឺមានចំណងជើងថា ព័ត៌មានបន្ថែមទាក់ទងទៅនឹងករណី០០១/១៥.៧.២០០៧ ដែលមានលេខឯកសារ 22/42.3។ តើលោកបានផ្ដល់ព័ត៌មានបន្ថែមលើឯកសារនេះមែនទេ?

**ឆ៖** មានតែត្រឹមខ្ញុំនិយាយអំមិញហ្នឹងហើយ។ ខ្ញុំអត់ចេះធ្វើឯកសារខ្លួនឯងបន្ថែមបន្ថយទេ ខ្ញុំរាយការណ៍ឲ្យពួកគេ មេធាវីគាត់សួរខ្ញុំៗ ប្រាប់ឲ្យស្មោះត្រង់តាមការជាក់ស្តែង។

**ស៖** មុននឹងផ្តិតមេដៃលើឯកសារនេះ អ្នកកត់ត្រាបានអានឲ្យលោកស្តាប់ឡើងវិញ មែនទេ?

**ឆ៖** បាទ, មានគេអានឲ្យស្តាប់ ត្រូវ ឬមិនត្រឹមត្រូវ។ មាន។

**ស៖** លោកស្គាល់ឈ្មោះ រម៉ាម យុន ទេ?

[១៤:១២:២៦]

**ឆ៖** ម៉េចមិនស្គាល់! បងប្អូនស្រុកជាមួយគ្នា។

**ស៖** សូមអរគុណ។ កាលពីធ្វើកិច្ចសម្ភាសន៍ ផ្តល់ពាក្យបណ្តឹងទាំងឡាយ ឯកសារដែលខ្ញុំរៀបរាប់អំមិញនេះ ធ្វើជាមួយគ្នានឹងលោក រម៉ាម យុន ដែរឬមែនទេ?

**ឆ៖** អត់ទេ រៀងៗខ្លួនតើ! រៀងៗខ្លួន អត់មានធ្វើជាមួយទេ។

**ស៖** នៅថ្ងៃទី០៦ គឺដើមឆ្នាំមុន គឺថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ហើយនៅម្សិលមិញនេះទៀត នៅពេលដែលគេសួរលោកបានឆ្លើយថា លោកត្រូវបានគេបង្ខំឲ្យចូលរួមបដិវត្តន៍។ ត្រឹមត្រូវទេ លោកបាននិយាយបែបនេះ?

**ឆ៖** បាទត្រឹមត្រូវ។

**លោក អាង ឧត្តម៖**

ខ្ញុំសូមបង្ហាញឯកសារ។ សូមលោកប្រធានមេត្តាអនុញ្ញាតឲ្យក្រុមការងារខ្ញុំបង្ហាញឯកសារ ហើយខ្ញុំសូមអានឲ្យចំចំណុចតែម្តង ដើម្បីកុំឲ្យខាតពេលច្រើន ដូចលោកព្រះរាជអាជ្ញាបានធ្វើដែរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

បើកមេក្រូសិន!

**លោក អាង ឧត្តម៖**

D247/1 ERN00403454។

[១៤:១៥:០៣]

**ប្រធានអង្គជំនុំ៖**

ហាប៉ុន្មានទៅ? 00403454 ឬ59?

បើកក្បាលមេក្រូ!

**លោក អាង ឧត្តម៖**

00403459។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទសូមអរគុណលោកប្រធាន។ តើភាគីការពារក្តីហ្នឹងអាចផ្តល់លេខERN ជាភាសាបារាំង ហើយនិងភាសាអង់គ្លេសផងបានទេ។ បាទ សូមអរគុណ។

[១៤:១៦:១៦]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ នេះជានីតិវិធីនៃការបង្ហាញឯកសារនៅចំពោះអង្គជំនុំជម្រះនាពេលសវនាការ ទាំងភាគី ទាំងអង្គជំនុំជម្រះត្រូវបង្ហាញនូវអត្តសញ្ញាណឯកសារ ហើយទាំងបីភាសា។ សូមលោកមេធាវីរៀបចំបង្ហាញនូវឯកសារពីរទៀតដែលជាភាសាអង់គ្លេស ហើយនិងជាភាសាបារាំង។

**លោក អាង ឧត្តម៖**

សូមអភ័យទោស លេខជាភាសាបារាំងគឺ E-- សុំទោស គឺ00434843-00434850 ជាភាសាអង់គ្លេស 00404460-00404467 ខ្មែរ 00403457-00403464។

[១៤:១៩:១៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទសូមអរគុណលោកប្រធាន។ តាមពិតជាភាសាបារាំងគឺថាមានសំណៅដែលកែប្រែមួយដែលមានចំណងជើងថា D247 ហើយលេខ ERN គឺ 00751731 រហូតដល់ 00757317។ តើលោកអាចឲ្យលេខERN ជាបារាំង និងអង់គ្លេសនៃទំព័រដែលលោកនឹងអានខាងមុខហ្នឹងទេ?

**សួរដោយលោក អាង ឧត្តម៖**

មានលេខ ERN ជាភាសាអង់គ្លេស ហើយសុំទោសដោយសារតែក្រុមយើងខ្ញុំមិនប្រើភាសា

បារាំង អ៊ីចឹងប្រហែលជាខ្ញុំអាចជូនត្រឹម បើសិនក្រុមការងាររកភាសាបារាំងបានអត់អី។ ប៉ុន្តែពួកខ្ញុំរកប្រើតែភាសាអង់គ្លេស និងខ្មែរ។ លេខ ERN អង់គ្លេសគឺ 404462។

**ស៖** បាទខ្ញុំសូមបន្តបានទាន។ លោក ក្លាន វ៉ិត អម្បាញ់មិញលោកទើបនឹងឆ្លើយសំណួររបស់លោកមេធាវី សុន អរុណ ថា លោកត្រូវបានអ៊ំ វង់ បង្ខំឲ្យចូលបដិវត្តន៍ តើលោកពិតជាបាននិយាយអ៊ីចឹងមែនទេ?

**ឆ៖** បាទអ៊ីចឹងហើយ។ ពិតអ៊ីចឹង។

**ស៖** នៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី លេខ D247/1 លេខ ERN ជាភាសាខ្មែរ 00403459 នៅក្នុងចម្លើយលេខ ៥ ខណ្ឌទី៣ ខាងក្រោមនេះ ខ្ញុំអាន។ ខ្ញុំសូមដកស្រង់ "ខ្ញុំបានចូលបដិវត្តន៍ឆ្នាំ១៩៦១ នៅភូមិម៉ាលិក ឃុំម៉ាលិក ស្រុកបរកែវ ខេត្តរតនគិរី ដោយមានឈ្មោះតា វី ហៅតា វង់ កំណើតនៅកំពត ថង ស៊ី ហៅ ចាន់ ដែង ជនជាតិ ឡាវ ខាំ ផៃ កំណើតរ៉ុនសៃ បានមកណែនាំខ្ញុំ និងអ្នកភូមិផ្សេងទៀត។ ខ្ញុំដឹងថា ជាបដិវត្តន៍ តែមិនដឹងថា ជាបដិវត្តន៍អ្វី ឬបក្សខាងណា។ ថង ស៊ី ផ្ទាល់បានប្រាប់ខ្ញុំថា ឲ្យតស៊ូ និងកម្ចាត់ខ្មាំង ប្រសិនបើបងប្អូនខឹងនឹងខ្មាំង ត្រូវសាមគ្គី។ ខ្ញុំមិនដឹងថា ថង ស៊ី ទទួលការណែនាំគោលការណ៍នេះពីអ្នកណានោះទេ" ចប់សម្រង់ដកស្រង់។

បានន័យថា នៅក្នុងសម្តីរបស់លោកគឺ អត់មានអ្នកណាបង្ខំឲ្យលោកចូលបដិវត្តន៍ទេ តាមឯកសារនេះ។ មែនទេ?

[១៤:២៤:០៥]

**ឆ៖** បាទ ប៉ុន្តែឃើញពួកគាត់ហ្នឹងអប់រំខ្ញុំ។ អ៊ំ ចាន់ ដែន, ថង ស៊ី ឈ្មោះ សម្ងាត់ ឈ្មោះ ចំហគាត់នោះ ចាន់ ដែង, ខាំ ផៃ ជនជាតិលាវដែរ ដូចពិតអ៊ីចឹងហើយ។

**ស៖** ហើយនៅក្នុងកំណត់ហេតុសួរសាក្សីចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ដដែលលោកអត់បានអះអាងថា មានអ្នកណាបង្ខំលោកឲ្យចូលបដិវត្តន៍ទេ។ ដូចសំណួរខ្ញុំអំមិញអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំយល់ថា បង្ខំហើយគាត់អប់រំពីរលើកបីលើក ហ្នឹងខ្ញុំបានយល់ចេះតែធ្វើតាម។ បើថាយល់ខ្លួនឯងមិនដែលធ្វើមិនដែលស្តាប់។ អាហ្នឹងខ្ញុំថាពួកគាត់អប់រំ ចាប់បង្ខំ ខ្ញុំអត់លះបង់ អាហ្នឹងដល់សព្វថ្ងៃខ្ញុំអត់ចង់រៀនអក្សរ អត់ចង់រៀនសំបុត្រ។ សូមអស់។

**ស៖** នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៨ លោកក៏បានអះអាងថា មានណាអ្នកបង្ខំឲ្យចូលបដិវត្តន៍ដែរ មែនទេ?

**ឆ៖** មានដូចខ្ញុំថាអំមិញហើយ។ បើគេមិនអប់រំម៉េចចេះធ្វើខ្លួនឯង។ ពីណាទៅចេះ ខ្ញុំអត់ចេះបដិវត្តន៍ អត់យល់បដិវត្តន៍ទេ។ ដឹងយ៉ាងម៉េចគេថាបដិវត្តន៍ មិនដឹងឈើមិនដឹងថ្ម មិនដឹងដី ដោយសារគេអប់រំ គេឃោសនាហ្នឹងបានដឹង បានយល់អ៊ីចឹង។ អ៊ីចឹងហ្នឹងខ្ញុំថាគេបង្ខំ។ សូមចប់។

[១៤:២៦:១៩]

**ស៖** អ៊ីចឹងការអប់រំណែនាំឲ្យចូលបដិវត្តន៍នេះលោកថា ជាការបង្ខំមែនទេ?

**ឆ៖** បាទ, ដូចជាការបង្ខំហើយបាទ។

**ស៖** លោក មិនមែនលោកចូលបដិវត្តន៍ដោយខ្លួនឯងផង ដោយស្ម័គ្រចិត្តផង មិនមែនអ៊ីចឹងឬយ៉ាងម៉េច?

**ឆ៖** ជាក់ស្ដែងដោយខ្លាច អត់ដែលឃើញ អត់ដែលដឹង អត់ដែលឮគេថាបដិវត្តន៍។ អាហ្នឹងចេះតែធ្វើតាមគេ និយាយស្មោះត្រង់តែហ្នឹង។

**ស៖** សូមអរគុណ។ ពីឆ្នាំ១៩៦១ ដល់១៩៧៩ លោកក៏ជាកម្មាភិបាលខ្មែរក្រហមម្នាក់ដែរ អ៊ីចឹងមែនទេ?

**ឆ៖** បាទ មែនហ្នឹងហើយ ធ្វើតាមគេ។ គេអប់រំ គេអូសទាញបើមិនទៅវាខ្លាច គណៈភូមិភាគហ្នឹងគេវៃចោល គណៈតំបន់គេវៃចោល គណៈស្រុកគេវៃចោល ឃើញជាក់ស្ដែងដូចអ៊ំ វង់ អ៊ំ យ៉ា ជាក់ស្ដែង ធ្វើបដិវត្តន៍ក្រ តាំងពីក្រខ្សត់អត់ឃ្លាន ងាប់ឥតមានប្រយោជន៍អី។ ហ្នឹងដោយសារនុ៎ងហើយខ្ញុំខ្លាច ខ្ញុំចេះតែតាមធ្វើ ធ្វើឲ្យយល់ ធ្វើឲ្យដឹង ធ្វើឲ្យចង់ខ្លួនឯងអត់ទេ។ អត់មានប្រយោជន៍អីសោះមកអ៊ំតាពត ហ្នឹងធ្វើប៉ុណ្ណឹងៗអត់មានកើតស្ដេចដែរ ស្លាប់មុនគេ។ អាហ្នឹងឃើញជាក់ស្ដែង ខ្ញុំឃើញអ៊ីចឹង។ អត់មានប្រយោជន៍អីសោះ។

**ស៖** សូមអរគុណ។ អំឡុងពេលហ្នឹងជាពិសេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង លោកត្រូវបានតែងតាំងដំឡើងតំណែងបីដង មែនទេ?

[១៤:២៨:៣៨]

**ឆ៖** បាទពិតអ៊ីចឹង។

**ស៖** គឺនៅឆ្នាំ១៩៧០ បដិវត្តន៍បានតែងតាំងលោកឲ្យធ្វើជាមេភូមិត្រឹមត្រូវទេ?

**ឆ៖** បាទត្រឹមត្រូវ។

**ស៖** សូមអរគុណ។ នៅឆ្នាំ១៩៧៤ លោកត្រូវបានតែងតាំងឲ្យធ្វើជាមេឃុំតាឡាវ ត្រឹមត្រូវទេ?

**ឆ៖** បាទត្រឹមត្រូវ។

**ស៖** សូមអរគុណ។ នៅឆ្នាំ១៩៧៦ លោកត្រូវបានតែងតាំងជាអនុលេខតំបន់២១ ត្រឹមត្រូវទេ?

**ឆ៖** អនុស្រុកៗ មិនមែនអនុតំបន់ទេ។

**ស៖** អ៎ សូមទោស។ អនុស្រុកបាទ។

**ឆ៖** អនុស្រុក។

**ស៖** បាទ។

**ឆ៖** អនុស្រុក២១ ពិត។ អ្នកដែលតែងតាំងនោះ អ៊ំវង់, អ៊ំយ៉ា, តាខាត់, តាប៊ុត, តាឡឹន គណៈភូមិភាគ គេហៅគណៈភូមិភាគ គេចាត់តាំងនៅបានលុងហ្នឹង។ ខ្ញុំអត់ព្រម បីថ្ងៃគេបង្អាក់ដល់ថ្ងៃទីបួនគេប្រកាស បើពួកមិត្តវ៉ិតព្រម ឬមិនព្រម ឯងមិនគោរពបក្ស សិទ្ធិលើឯង។ គេចង្អុលមុខអ៊ីចឹង។ បើឯងមិនចង់ធ្វើប្រធាន ធ្វើអនុប្រធាន។ ឲ្យ ធិន ហ្នឹង ធ្វើអនុតំបន់ផង អនុលេខាស្រុកផង។ អាហ្នឹងខ្ញុំយល់ព្រម។ គេយកអ្នកជំនួយការហ្នឹងឈ្មោះ ស្វាង ជនជាតិខ្មែរ ហើយដកពេលកងវរសេនាធំរបស់គេ។ គេទទួលការងារនៅជាមួយខ្ញុំនៅស្រុក២១។ ឈ្មោះ ស្វាង ជំនួយការខ្ញុំ គាត់ចេះសរសេរអក្សរទាក់ទងទៅមកជាមួយតំបន់ ជាមួយភូមិភាគហ្នឹង អត់លាក់លៀមទេ ពិតប្រាកដ។ សូមចប់។

[១៤:៣០:៤៦]

**ស៖** ការតែងតាំងលោកជាអនុលេខាស្រុក២១ ហ្នឹង ធ្វើនៅឆ្នាំ១៩៧៦ ហើយប្រព្រឹត្តទៅនៅទីណា? ការតែងតាំងនៅឯណា កាលនោះ?

**លោក ញ៉ែម សំណាង៖**

ម្តងទៀតអ៊ំ។

**លោក ក្លាន វ៉ិត៖**

**ឆ៖** នៅវ៉ីនសៃ។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** សូមអរគុណ។ គឺតែងតាំងឲ្យលោកធ្វើជាអនុលេខាស្រុក២១ ហ្នឹងដោយអ៊ំ វង់ មែនទេ?

**លោក ក្លាន ទ្វិត៖**

**ឆ៖** បាទ គាត់ហ្នឹងហើយ!

**ស៖** សូមអរគុណ។ អ៊ីចឹង មុនតំណែងឋានៈទាំងអស់នេះ ជាមុខតំណែងដែលមានការទទួលខុសត្រូវមែនទេ?

**ឆ៖** បាទ, ពួកគាត់ៗហ្នឹងហើយទទួលចាត់តាំងខ្ញុំ បើថាការខុសការត្រូវ ឯងមិនចេះមិនដឹង ពួកខ្ញុំទទួលការងារដឹកនាំ ណែនាំឲ្យការងារ មិនមែនធ្វើខ្លួនឯងចេះទេ។ គាត់ឆ្លើយអ៊ីចឹង។

**ស៖** បាទសូមអរគុណ។ មុខតំណែងដែលលោកបានទទួលការតែងតាំងទាំងអស់នេះគឺតម្រូវឲ្យមានមនុស្សមួយចំនួនធ្វើការឲ្យលោកមែនទេ?

**ឆ៖** មានតែពួកគាត់ហ្នឹងហើយដែលនាំ ឈ្មោះប្រធានតំបន់នេះឈ្មោះ ធិន នៅវីនសៃ។ គាត់ប្រធានស្រុកផង លេខាតំបន់ផង ធិន។ បងខាំភី នេះ, បង រម៉ាម យុន ហ្នឹងគាត់អនុ ធិន។

**ស៖** បាទអរគុណ។ ក្នុងនាមលោកជាប្រធានភូមិ ប្រធានឃុំ ឬអនុលេខាស្រុក លោកតែងមានមនុស្សមួយចំនួនធ្វើការក្រោមការណែនាំ ឬបង្គាប់បញ្ជារបស់លោកដែរមែនទេ?

[១៤:៣៣:០៥]

**ឆ៖** បាទមានៗ។

**ស៖** សូមអរគុណ។ អ៊ីចឹងឋានៈលោកកាន់តែខ្ពស់ អ៊ីចឹងមនុស្សដែលធ្វើការក្រោមលោកក្រោមការបង្គាប់ណែនាំ បញ្ជារបស់លោកចំនួនមនុស្សក៏កាន់តែច្រើនទៅតាមនុ៎ងដែរមែនទេ?

**ឆ៖** ក្ដាប់ ឧទាហរណ៍ ខ្ញុំក្ដាប់ពួកប្រធានឃុំ ប្រធានភូមិ អប់រំដើម្បីកសាងសហករណ៍ហ្នឹងហើយបាទ។

[១៤:៣៣:៥៦]

**ស៖** សូមអរគុណ។ ខ្ញុំងាកទៅរកឯកសារ D22/42 លេខ ERN ជាភាសាខ្មែរ 00279574 លេខERN ជាភាសាអង់គ្លេស--។

សូមអភ័យទោសទាន ដោយសារភ្លាំងភ្លាត់មិនបានរៀបលេខ ERN ឲ្យបាន-- ERN ជាភាសាអង់គ្លេស 00346107។ ខ្ញុំសូមឲ្យសហការីខ្ញុំបញ្ចាំង-- សូមបង្ហាញនូវកថាខណ្ឌទី១ ខ្ញុំសូមអាន តែកថាខណ្ឌទី១ ខ្ញុំសូមដកស្រង់ “ខ្ញុំគឺជាជាជនជាតិភាគតិចកាចក់ រស់នៅភូមិអ៊ុន ឃុំតាឡាវ ស្រុកអណ្ដូង

មាស ខេត្តរតនគិរី។ ខ្ញុំធ្លាប់តស៊ូក្នុងព្រៃជាមួយ ប៉ុល ពត, អៀង សារី ក្នុងខេត្តរតនគិរី ដើម្បីផ្តួលរំលំរបប លន់ នល់ ជាពិសេសនៅពេលដែលមិនទាន់ផ្តួលរលំរបប លន់ នល់ បាន។ ខ្ញុំធ្លាប់យកសត្វផ្សេងៗមានដូចជាសត្វជ្រូក សត្វគោ ដើម្បីដោះដូរអាវុធជាមួយវៀតណាមនៅតាមព្រំដែន។ លុះដល់ខែមេសា ឆ្នាំ១៩៧៥ ពេលដែល ប៉ុល ពត ដណ្តើមបានទីក្រុងភ្នំពេញហើយ ខ្ញុំត្រូវបាន អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យតែងតាំងខ្ញុំជាអនុលេខាស្រុក២១ ឬស្រុកអណ្តូងមាស ដើម្បីមើលការខុសត្រូវលើប្រជាជនដែលរស់នៅទីនោះ"។ ព័ត៌មានដែលថា លោក អៀង សារី បានតែងតាំងលោកជាអនុលេខាស្រុក២១ នោះជាព័ត៌មានមិនពិតទេ មែនទេ?

[១៤:៣៨:១០]

**ឆ៖** បាទការចាត់តាំងគាត់អត់ឃើញទេ។

**ស៖** បាទសូមអរគុណ។ ហើយលោកក៏អត់បានដឹងប្រាកដទេថា លោក អៀង សារី កាលនោះមានតំណែងពិតប្រាកដ-- ខ្ញុំចង់និយាយពីខែមេសា ឆ្នាំ១៩៧៥ហ្នឹងមានតំណែងពិតប្រាកដជាអ្វីទេ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មែនទេ?

**ឆ៖** ឮតែគេថា គណៈភូមិភាគៗទាំងអស់ពួកគាត់បីបួននាក់ហ្នឹង។

**ស៖** លោកឮថា លោក អៀង សារី ជាគណៈភូមិភាគ?

**ឆ៖** បាទ មិនត្រឹមតែម្នាក់គាត់ទេ ទាំងអស់បីបួននាក់ហ្នឹង។ ទាំងអ៊ំពត, អ៊ំ អៀង សារី, អ៊ំ នួនជា ឮគេហៅឈ្មោះ ឮឈ្មោះមកពី ពេលគេបើកវគ្គ អ៊ំយ៉ា, អ៊ំវង់ហ្នឹងគាត់ប្រកាស។

**ស៖** អ៊ីចឹងនៅខែមេសា ឆ្នាំ១៩៧៥ហ្នឹង លោក អៀង សារី មិនមែនជាឧបនាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រីក្រសួងការបរទេសទេ មែនទេ?

**ឆ៖** រឿងហ្នឹងធំ ខ្ញុំអត់ដឹងទេ ខ្ញុំដឹងតែគេហៅគណៈភូមិភាគប៉ុណ្ណឹងទេ។

[១៤:៣៩:២៩]

**ស៖** ខ្ញុំសូមសួរសំណួរលោកមួយទៀត។ លោកបានជួបលោក អៀង សារី ប៉ុន្មានដងក្នុងអំឡុងពេលពីឆ្នាំ៦០ តាំងពីកន្លងពេលមកពេល-- ពីដើមមករហូតមក លោកធ្លាប់ជួបលោក អៀង សារី ប៉ុន្មានដង?

**ឆ៖** ជាក់ស្តែងគាត់ហៅអប់រំ វាមានបីលើក បើឃើញគាត់ហៅគាត់អប់រំសិក្ខាសាលាហ្នឹងភូមិកុហាន ការតស៊ូនយោបាយមួយលើក។ អានេះអ្នកបកប្រែហ្នឹងឈ្មោះ ធិន ទំពូន នៅជាមួយគាត់។ ដល់លើកទីពីរ អប់រំមន្ទីរនៅភូមិហាយ លើកទីពីរ។ លើកទីបី គាត់អប់រំធ្វើបុណ្យ នៅភូមិចាយ។ មានបីលើក ហ្នឹងខ្ញុំស្គាល់ថាអ៊ំ អៀង សារី។ ប៉ុន្តែការងារភារកិច្ចរបស់ធំតូច ខ្ញុំអត់ដឹង មានភារកិច្ចទាក់ទងបរទេស ខ្ញុំអត់ដឹង។ ខ្ញុំឃើញតែអានេះអ៊ំ អៀង សារី។ មានតែប៉ុណ្ណឹងទេ។

**ស៖** កាលនោះគេហៅឈ្មោះគាត់ជាឈ្មោះផ្លូវការ ឬជាឈ្មោះបដិវត្តន៍?

**ឆ៖** កាលនោះគេហៅឈ្មោះ គាត់ឈ្មោះ បងវ៉ាន់។ គេអត់ហៅទេ អ៊ំ អៀង សារី។ គេហៅអ៊ំវ៉ាន់, បងវ៉ាន់ៗ ឈ្មោះពីរ ឈ្មោះគាត់។ មានតែអ៊ំពត មានតែឈ្មោះ តាពតៗ។ អាមួយហ្នឹងទៀត តាខាំផង សុន សេន ផង តា ខៀវ ផង។ អាហ្នឹងគាត់មានឈ្មោះបីនាក់ តាខៀវ ហ្នឹង។ ខៀវៗ, ខាំៗ ឈ្មោះបីនៅគាត់នុំង។ អាហ្នឹងឃើញគាត់ជាមួយអ៊ំហ្នឹងមានបីលើក។ បួនលើកនៅចុងបំផុត គាត់ត្រឡប់មកមួយនេះ នៅក-៥។ អាមេរិក វាទម្លាក់គ្រាប់បែកហ្នឹង ពួកគាត់ចេញមកខាងនេះ ពាក់កណ្តាលយប់ចេញពីក-៥ ឆ្លងមកនៅខាងនេះទន្លេ។ គេថា ក-៩ នៅខាងនេះត្រើយ កាលនោះគេថាក-៩។ ចេញពីនោះសហករណ៍ ក-៥ កន្លែងពួកខ្ញុំធ្វើឲ្យកន្លែងគាត់ហ្នឹងរស់នៅហ្នឹង។ រយៈនៅនុំងមួយឆ្នាំ ពិតប្រាកដ។

[១៤:៤១:៥៧]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ការស្នើសុំ៣០នាទី ឥឡូវលើសដល់ដប់នាទីហើយ តើលោកមានប៉ុន្មានសំណួរទៀតក្នុងការសួរនេះ ដើម្បីអង្គជំនុំជម្រះលៃលកបញ្ហានេះ ព្រោះម៉្យាងជិតដល់ពេលសម្រាប់ត្រូវសម្រាកផង។

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន ហើយក៏សូមអភ័យទោស ដោយសារប្រហែលជាខ្ញុំបាទដំណើរការទៅយឺតបន្តិចបានជាស្មង់ពេលវេលាអត់ត្រូវ។ ខ្ញុំបាទសល់តែឯកសារមួយសន្លឹក មួយទំព័រនេះទេ ដែលត្រូវសួរហើយសំណួរប្រហែលជាបី ខ្លីៗប៉ុណ្ណោះ។ ខ្ញុំសូមអនុញ្ញាតឲ្យបញ្ចប់នៅពេលនេះតែម្តង។ សូមលោកប្រធានមេត្តាអនុញ្ញាត ហើយសូមឲ្យសហការីខ្ញុំបង្ហាញឯកសារ បើលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**លោក អាង ឧត្តមៈ**

D22/42.3 លេខ ERN ភាសាអង់គ្លេស 00279568។ ខ្ញុំសូមអនុញ្ញាតអានឯកសារនេះទាំងស្រុង ហើយខ្ញុំនឹងលើកសំណួរពេលក្រោយ។

ខ្ញុំសូមដកស្រង់ទាំងស្រុងៈ “ព័ត៌មានបន្ថែមទាក់ទងនឹងករណី០០១/១៥ ប្រហែលជា១៨ មិនដឹង ៧-២០០៧-អវតក-កសចប-អបជ០១ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៨។ ដើមឆ្នាំ១៩៧៩ ខ្មែរក្រហមចាប់មិត្តភក្តិស្គាល់គ្នាពេលប្រជុំកម្មាភិបាលខ្មែរក្រហមចំនួន១០នាក់ពីស្ទឹងត្រែងទៅភ្នំពេញ។

១) ក្លាន វ៉ិត ខ្លួនខ្ញុំផ្ទាល់ អនុស្រុក២១ គឺស្រុកអណ្ដូងមាស។

២) រម៉ាម យុន អនុតំបន់ វ៉ឺនសៃ។

៣) ភុង អនុតំបន់១៥ ស្រុកលំផាត់។

៤) ជា ឬ ផា ជនជាតិឡាវ លេខាស្រុកឈ្ងួ ខេត្តស្ទឹងត្រែង។

៥) ប៉យ លេខាស្រុក២៣។

៦) បៀន លេខាស្រុក២២។

៧) យ៉ុំ និងលេខាស្រុកសៀមប៉ាង។

៨) ឆុម ប្រធានទាហាន ភូមិភាគឦសាន។

៩) ថា វ៉ន ជនជាតិឡាវ អនុតំបន់ស្ទឹងត្រែង។

១០) សុវណ្ណ អនុស្រុកសៀមប៉ាង។

ទៅដល់ភ្នំពេញ ខ្មែរក្រហមយកពួកខ្ញុំទៅដាក់ផ្ទះមួយមានរូបថតស្ដេច ផែនទីប្រទេសផ្សេងៗ និងមានសុទ្ធតែកញ្ចក់ ប្រហែលមួយខែ។ ខ្មែរក្រហមបានសួរពីប្រវត្តិខ្ញុំម្ដងម្នាក់ៗ ហើយឲ្យធ្វើសួនដាំដំឡូង។ មួយខែក្រោយមក គេបំបែកខ្ញុំបួននាក់ ក្លាន វ៉ិត, រម៉ាម យុន, ហុង, ជា ទៅវត្តស្លែង មន្ទីរអប់រំ ចំណែកមិត្តភក្តិប្រាំមួយនាក់ទៀត ត្រូវខ្មែរក្រហមចាប់យកទៅគុកទួលស្លែង ហើយបាត់ដំណឹងរហូត។

[១៤:៤៦:៣៣]

ខ្ញុំសូមប្ដឹងពីការបាត់ខ្លួនរបស់មិត្តខ្ញុំប្រាំមួយនេះ។ រតនគិរី ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៨។ ស្នាមមេដៃស្ដាំ ក្លាន វ៉ិត”។

**សួរដោយលោក អាង ឧត្តមៈ**

**សៈ** ខ្ញុំចង់សួរថា ក្នុងដំណើរដែលលោកបានទៅភ្នំពេញ មាននៅដើមឆ្នាំ១៩០០ នោះ លោក

បានទៅភ្នំពេញមែនឬអត់?

**ឆ៖** ទៅមែន។

**ស៖** ទៅនោះ គេចាប់ ឬគេហៅទៅ?

**ឆ៖** បាទ ពីភូមិភាគហ្នឹង គេហៅមក។

**ស៖** ចេញដំណើរ លោកចាំទេ ចេញដំណើរពីស្រុកទៅដល់ភ្នំពេញប៉ុន្មានថ្ងៃបានទៅដល់ភ្នំពេញ?

**ឆ៖** គេហៅមកពីនោះ នៅចាំនៅស្ទឹងត្រែង។ គ្នា១២នាក់ហ្នឹង ចាំគ្នាគ្រប់ គ្នា១២នាក់ហ្នឹង តាខេង យកមកភ្នំពេញ។

**ស៖** ១២នាក់ រួមទាំងបើកកាណូតផង ឬយ៉ាងម៉េច?

**ឆ៖** ទាំងពួកគាត់ ទាំងពួកខ្ញុំ ភូមិភាគប៉្លសានហ្នឹង។

**ស៖** លោកថា ទៅដល់ភ្នំពេញមួយខែ ខ្មែរក្រហមឲ្យធ្វើប្រវត្តិរូបម្តងម្នាក់ គឺប្រហែលបើលោកថាដើមឆ្នាំ៧៩ គឺនៅក្នុងមួយខែនេះ គេឲ្យលោកធ្វើប្រវត្តិរូបម្តងម្នាក់ៗ ហើយនិងធ្វើសួនច្បារដាំបន្លែផង មែនទេ?

[១៤:៤៨:៣១]

**ឆ៖** បាទ, អាហ្នឹងពិតអ៊ីចឹងហើយ ពីព្រោះខ្ញុំកាប់គាស់បានដាំថ្នាំជក់ ម្ទេស ត្រប់ បានហូបខ្លួនឯង ថ្នាំបានមិនបានជក់។ ដាំបានប៉ុណ្ណេះៗ ជាក់ស្តែងពិតអ៊ីចឹងហើយ។

**ស៖** ហ្នឹងរយៈពេលមួយខែ ហើយមួយខែក្រោយមកទៀត គេក៏បំបែកពួកលោកទាំងបួននាក់ចេញឲ្យទៅវត្តស្លែង អ៊ីចឹងមែនទេ?

**ឆ៖** បាទ, ព្រឹកព្រលឹមគេមកយក គេថាឥឡូវឲ្យពួកអ៊ំបួននាក់នេះទៅវត្តស្លែង ថ្ងៃនេះយួនវាចូលមក។ អាហ្នឹងគេយកទៅស្រែនៅទួលស្លែង។ មនុស្សនៅទួលស្លែងហ្នឹង ៤៨០នាក់ ដល់ម៉ោងបីហ្នឹង គេទម្លាក់គ្រាប់បែកនៅកប៉ាល់-- នៅស្ពានជ្រោយចង្វារហ្នឹងភ្លើងឆេះ។ ដល់ម៉ោងបួនហ្នឹង អាឡានយួនវាចូលមកពេញភ្នំពេញ ពួកខ្ញុំនៅនោះហើយ អត់រត់នៅណាទេ ពិត។

**ស៖** សំណួរបញ្ជាក់ថា ឃើញមនុស្ស៤០០នាក់ នៅគុកទួលស្លែងមែនទេ?

**ឆ៖** បាទៗ ទៅកន្លែងស្រែ កន្លែងគេច្រូតស្រូវហ្នឹងណា មនុស្សនុំង។ ប្តីគេបាត់ៗហ្នឹង ប្រពន្ធគេមកជាមួយពួកខ្ញុំ គេទុកនៅនោះ គេច្រូតស្រូវ កូនអីទៅចងអង្រឹងចោល*(ឮមិនច្បាស់)* ហ្នឹង អាម៉ែ

វាហ្នឹងច្រូតស្រូវ ដល់ម៉ោងដប់មួយនោះ ដប់មួយនេះចេញហូបបាយ កូនង៉ានោះយំនៅនុ៎ងហើយ លង៉ារៗៗដូចឆ្កែនុ៎ង។ ព្រោះខ្ញុំទៅព្រឹកនុ៎ង ទៅខ្ទមស្រែនុ៎ង អ៎ អាណិតមែនទែន ដូចកូនឆ្កែ។

**ស៖** កាលហ្នឹងនៅ លោកដែលមានឱកាសទៅ គេនាំទៅគុកទួលស្លែងទេ? ខ្ញុំសួរម្តងទៀត។

**ឆ៖** អត់ទាន់ទៅទេ ល្មមតែឃ្លួនគេចូលមក។ គេថា អ៊ំយើងនៅពីរថ្ងៃទៀត យើងប្រជុំទៀត ប្រជុំម្តងនេះហើយហើយ។ ល្មមបានមួយថ្ងៃស្អែក ខានស្អែកពីបឃ្លួនចូលមក អាហ្នឹងពួកខ្ញុំរួច បានគេទៅកាច់សម្លាប់នៅទួលស្លែង អ៊ីចឹង។

[១៤:៥០:៥៤]

**ស៖** កាលនោះលោកនៅទួលស្លែងមែនទេ?

**ឆ៖** ថ្ងៃឃ្លួនចូលមក ខ្ញុំនៅស្រែៗ គឺថាស្រែនៅទួលស្លែង មិនដឹងស្រែអី ឃើញគេច្រូតមនុស្ស ៤៨០នុ៎ង។

**ប្រធានអង្គជំនុំ៖**

ព្រះរាជអាជ្ញាសូមបញ្ជាក់ឡើងវិញ បញ្ហាក្រែងលោមានការភ័ន្តច្រឡំលើទីកន្លែង។ មួយវត្តស្លែងដែលជាមន្ទីរអប់រំ មួយទៀតគុកទួលស្លែង ដែលនៅកណ្តាលរាជធានីភ្នំពេញ។ អ៊ីចឹងវាមានពីរផ្នែកពាក្យស្លែងដូចគ្នា ប៉ុន្តែមួយទៀតទៅវត្តស្លែងជាមន្ទីរអប់រំ។ ចំណែកឯមួយទៀត មួយក្រុមដែលមនុស្សគេយកទៅហ្នឹង គឺយកទៅដាក់គុកទួលស្លែង។

[១៤:៥១:៤៦]

ដូច្នេះពាក្យស្លែងនេះ គឺមានទីតាំងខុសគ្នានៅក្នុងឯកសារនេះ ចៀសវាងការភ័ន្តច្រឡំលើទាំងការសួរ ហើយបើសំណួរមានការភ័ន្តច្រឡំ អាចភ័ន្តច្រឡំទាំងការឆ្លើយផង។ សូមបញ្ជាក់ឲ្យបានច្បាស់លាស់អំពីទីតាំងវត្តទួលស្លែង ដែលមានចែងសរសេរច្បាស់លាស់នៅក្នុងលាយលក្ខណ៍អក្សរ ដែលបញ្ជាក់ថាជាមន្ទីរអប់រំ ហើយនិងមួយទៀត គឺគុកទួលស្លែង។

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធានដែលបានជួយណែនាំ។ តាមពិតខ្ញុំបាទមិនច្រឡំទេ គឺគាត់អ្នកឆ្លើយទេច្រឡំ គឺខ្ញុំកំពុងណែនាំឲ្យគាត់ចូលចំណុចរវាងចំណុចពីរនេះមែន។ ពីព្រោះមានឱកាស ខ្ញុំសួរថា គាត់ត្រូវបាននាំទៅវត្តស្លែង គាត់ថាគាត់នៅទួលស្លែង ឃើញមនុស្ស៤០០នាក់នៅនុ៎ង។ គាត់ច្រឡំខ្លួនគាត់ ខ្ញុំកំពុងរកមធ្យោបាយទាញបំបែកឲ្យចូលសាច់រឿងទាំងពីរហ្នឹង។

ប្រហែលជាខ្ញុំសួរសំណួរមួយសំណួរចុងក្រោយ ដើម្បីឲ្យលោក ក្អាន រិត បញ្ជាក់។ ខ្ញុំចង់សួរថា--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី! យ៉ាងម៉េចទៅ?

**លោក ពេជ អង្គ៖**

សូមៗអនុញ្ញាត ជូនមេធាវី បាណាបេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

[១៤:៥៣:១៩]

**លោក បាណាបេ ណេគ្វី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា សហភាតាខ្ញុំគួរតែមើលទៅលើឯកសារពាក់ព័ន្ធនឹងដើមបណ្ដឹងរដ្ឋប្បវេណី។ គាត់បានសរសេរហេតុការណ៍ គឺថានាំគាត់ទៅកាន់វត្តស្លែង ក្នុងឯកសារនោះ។ គឺគាត់អត់មានច្រឡំរវាងកន្លែងពីរហ្នឹងទេ គឺខាងមេធាវីការពារក្ដីទេ ដែលសួរសំណួរពាក់ព័ន្ធនឹងទួលស្លែងហើយនិងវត្តស្លែងនោះ។ ដូច្នេះសូមឲ្យគាត់បញ្ជាក់ឲ្យបានច្បាស់។ សូមឲ្យគាត់មើលៗពីរពាក្យនៅកន្លែងហ្នឹងវិញ ហើយសូមឲ្យទៅចូលកាន់ចំណុចផ្សេងវិញបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ប៉ុន្តែអ្វីដែលលោកមេធាវីលើកឡើងនេះ យើងជាប្រធានអង្គជំនុំជម្រះបានធ្វើការកត់សម្គាល់ និងប្រាប់ដល់មេធាវីដែលកំពុងតាំងសំណួរចំពោះដើមបណ្ដឹងរដ្ឋប្បវេណីហ្នឹងយ៉ាងជាក់ច្បាស់ហើយ។ យើងគិតថា ប្រហែលជាភាសារបស់យើងមិនមានការចំណុចណាភ័ន្តច្រឡំ ឬមិនច្បាស់ទេ។

ដូច្នេះលើកក្រោយមិនគប្បីលើកឡើងដដែល នូវអ្វីដែលអង្គជំនុំជម្រះបានបញ្ជាក់រួចហើយនោះទេ។ សូមអញ្ជើញលោកមេធាវី!

[១៤:៥៤:៣៩]

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន។ សំណួរចុងក្រោយរបស់ខ្ញុំ ខ្ញុំសូមអានដដែល។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** មួយខែបន្ទាប់នៅក្រោយមក គេបំបែកពួកលោកបួននាក់គឺក្លាន រ៉ុត, រម៉ាម យុន,ធុំ និងជាទៅវត្តស្ដែង មន្ទីរអប់រំ។ អ៊ីចឹងមែនអត់?

**ឆ៖** បាទ នៅវត្តស្ដែង កន្លែងគេច្រូតស្រូវ។ នៅនោះហើយ ពីព្រោះព្រឹកគេយកទៅ ម៉ោងប្រាំបីព្រឹក ឲ្យពួកខ្ញុំ គេឲ្យឡានជិះជូនពួកខ្ញុំមកដល់ខ្ទមនោះ ឃើញមនុស្សគេច្រូតស្រូវ កុះករ។ មិនមែនទួលស្លែងគុកនោះទេ។

**ស៖** ចំណែកមិត្តភក្តិប្រាំមួយទៀតត្រូវខ្មែរក្រហមចាប់យកទៅគុកទួលស្លែង ហើយបាត់ដំណឹងរហូត។ តើអ៊ីចឹងមែនទេ?

**ឆ៖** រឿងគេយកទៅទួលស្លែង ទួលអី អត់ដឹងទេ។ ប៉ុន្តែពួកខ្ញុំកាប់ដីព្រឹក គេថាយកអ្នកនោះទៅធ្វើការមួយភ្លែត រិចអីវ៉ាន់យកទៅទេដែរ? អត់ទេ អត់យកទៅទេ ទៅមួយភ្លែត ទៅបាត់។ ព្រលឹមទៀតយកម្នាក់យកទៅម្នាក់ ស្ងាត់ឈឹង។ អាហ្នឹងបើខ្ញុំថាបើកាប់សម្លាប់ពួកខ្ញុំអត់ដឹង ឃុំឃាំងអត់ដឹងទេកន្លែងណាអត់ទេ ដឹងតែប៉ុណ្ណឹងពួកខ្ញុំ ពិតណាស់។

**ស៖** អ៊ីចឹងបានន័យថាលោក ក្លាន រ៉ុត ខ្លួនឯងមិនដែលត្រូវគេនាំខ្លួនទៅគុកទួលស្លែងទេ មែនទេ?

**ឆ៖** បាទ គ្រាន់តែគេ គេទៅប្រជុំ គេថាអានោះហើយទួលស្លែង មានអាកន្លែងដើមឈើតិចតួចប្រជុំ។ ប្រវត្តិរូប ប្រវត្តិរូបគេធ្វើអ៊ីចេះ អ៊ំមកនៅនេះសប្បាយ ឬស្អុតស្អាញ? នៅភូមិ នៅនេះ នៅណាសប្បាយ? ខ្ញុំថានេះម៉េចសប្បាយ មកនៅរៀនលើកមុនមនុស្ស១០០,២០០ ចេះតែចូលសាលាមកលើកនេះឃើញតែមនុស្សអត់បាយ ម៉េចនឹងសប្បាយ! អត់សប្បាយទេក្មួយ ទីមួយ។ ទីពីរយ៉ាងម៉េចនឹកគ្រួសារដែរ នឹកប្រពន្ធកូន នឹកភូមិផ្ទះ ម៉េចមិននឹក! នៅស្ងាត់ស្ងៀមៗម្នាក់ឯង មិនដឹងរស់ មិនងាប់ដឹងខុសដឹងត្រូវស្អី អង្គការអត់ប្រាប់ ទីពីរ។

[១៤:៥៧:២១]

ទីបីទៀត គេសួរម៉េចអ៊ំពិនិត្យមើលវៀតណាមឈ្នះ ឬមិនឈ្នះ វៀតណាម? ខ្ញុំថាសួរខ្ញុំវៀតណាមឈ្នះម៉េចមិនមែនខ្ញុំទេកាន់កងទ័ពនោះ សិទ្ធិលើអង្គការតើ! អង្គការក្ដាប់កម្លាំងកងទ័ពហ្នឹងប៉ុន្មានៗនាក់។ វាច្រើនវាតិចដឹង ខ្ញុំមនុស្សកាន់ចបធ្វើស្រែ ពីណាទៅដឹងឈ្នះវៀតណាមនោះ។ អ៊ីចឹងណា គេប្រវត្តិរូប គេសួរតែរឿងនោះ។ អាហ្នឹងគេថា អ៊ំនៅពីរថ្ងៃទៀតយើងប្រជុំទៀត ប្រជុំថ្ងៃនេះម្ដងហើយហើយ ទាំងអស់

ពួកអ៊ំពីរបីប្អូននាក់។ ពួកខ្ញុំល្មមបានថ្ងៃស្អែក ខានស្អែកពីបឃ្លួនចូល អាហ្នឹងពួកខ្ញុំរស់។

**លោក អាង ឧត្តម៖**

សូមអរគុណលោក ក្លាន វិត ហើយសូមអរគុណលោកប្រធាន។ ខ្ញុំបាទសល់មួយសំណួរទេ ហើយសូមអភ័យទោសដោយសារមិនបានគោរពពេលវេលាទាន! ហើយសល់មួយសំណួរសំខាន់ ហើយខ្ញុំសុំមិនបាច់បញ្ចាំងទេ ខ្ញុំសូមអានយ៉ាងខ្លីបំផុតដើម្បីបញ្ជាក់សេចក្តីថ្លែងការណ៍របស់គាត់អំមិញនេះ គឺឯកសារ D22/42។ ហើយខ្ញុំសូមអានលើចំណុច ឬមួយលោកប្រធានត្រូវការឲ្យបញ្ចាំង ឬក៏មិនបាច់ទាន?

[១៤:៥៨:៣៨]

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញអានចុះ! ហើយបញ្ចាំង ហើយបញ្ចាំងទៀតហ៎! បញ្ចាំងនៅ? បញ្ចាំងបានហើយសូមអញ្ជើញទាំងពីរទៅ!

បើកក្បាលមេក្រូ ហើយនិយាយម្តងទៀត។

**លោក អាង ឧត្តម៖**

ខ្ញុំសូមអានចំណុចថ្ងៃទី៧ ខែមករា ឆ្នាំ២០០៩ ត្រឹមខណ្ឌទីពីរ "ថ្ងៃទី៧ ខែមករា ឆ្នាំ២០០៩ វេលាម៉ោងប្រាំមួយព្រឹកមានឡាន"--

**ប្រធានអង្គជំនុំ៖**

ឈប់ៗ! អាចអានច្រឡំទេដឹង ២០០៩ ឬក៏១៩៧៩?

បើកក្បាលមេក្រូ!

**លោក អាង ឧត្តម៖**

សូមអភ័យទោសទាន! ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ វេលាម៉ោងប្រាំមួយព្រឹក មានឡានបាំងកន្លះគ្របស្តង់ដោយមានអ្នកបើកបរចំនួនពីរនាក់ មិនស្គាល់ឈ្មោះបានមកនាំខ្ញុំ មិត្តផា, មិត្តខាំភី, មិត្តភុង ឲ្យចូលក្នុងស្តង់ទាំងអស់គ្នា ដោយគេប្រាប់ពួកខ្ញុំថា យកទៅទួលស្លែង។ ពេលទៅដល់ទួលស្លែងគេបើកឲ្យពួកខ្ញុំចេញពីស្តង់ក្រោយឡាន។ ភ្លាមនោះពួកខ្ញុំឃើញមនុស្សទាំងប្រុស ទាំងស្រី និងក្មេងៗយ៉ាងច្រើនកំពុងនៅទីនោះ ប្រហែលជាង៤០០នាក់។ ខ្ញុំសូមបញ្ចប់ការដកស្រង់ទាំងនេះ។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** ខ្ញុំសូមសួរសំណួរលោក ក្លាន រ៉ិត ថាអ៊ីចឹងនៅថ្ងៃទី៧ ខែមករា ឆ្នាំ២០០៩ហ្នឹង លោកអត់បានទៅគុកទួលស្លែងហ្នឹងទេ? មែនទេ?

**លោក ក្លាន រ៉ិត៖**

**ឆ៖** បាទៗ អត់បានទៅ។ ទៅអាកន្លែងវត្តស្លែង គេច្រូតស្រូវនោះឯង។

**ស៖** បាទ សូមបញ្ជាក់កាលបរិច្ឆេទលោក គឺខ្ញុំអានទៅច្រឡំ គឺ៧ មករា ១៩៧៩។ សូមអរគុណលោកប្រធាន ហើយសូមអរគុណលោក ក្លាន រ៉ិត។ ខ្ញុំសូមជូនលេខERNដែលខ្ញុំអានអំមិញនេះជាភាសាអង់គ្លេសគឺ 00346168។ សូមអរគុណទាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណមេធាវី។ អរគុណលោក ក្លាន រ៉ិត។ ឥឡូវពេលនេះសមល្មមនឹងឈប់សម្រាក ហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីម្ភៃនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តដំណើរការសវនាការ។ សូមសម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៥:០២ នាទី ដល់ម៉ោង ១៥:២៣ នាទី)*

[១៥:២៣:០៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សូមអញ្ជើញ អាង ឧត្តម មានបញ្ហាអីទៀតទេ?

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមអនុគ្រោះពេលវេលាប្រហែលជាពីរនាទី ដើម្បីខ្ញុំបានបង្ហាញឯកសារមួយសន្លឹកៗនេះ។ សូមជម្រាបខ្ញុំបាទមិនមានសំណួរ ហើយក៏មិនមានអីទេគ្រាន់តែចង់ទាញការចាប់អារម្មណ៍របស់តុលាការ ពីព្រោះអម្បាញ់មិញ ខ្ញុំបានសួរលោក ក្លាន រ៉ិត ថាចម្លើយ ការសាកសួរទាំងឡាយត្រូវបានធ្វើរួមគ្នាជាមួយលោក រម៉ាម យុន ឬអត់? លោក ក្លាន រ៉ិត បានឆ្លើយថាអត់បានធ្វើជាមួយគ្នាទេ។ ដើម្បីទាញចំណាប់អារម្មណ៍របស់តុលាការបន្ថិចលើចំណុចនេះ។ ខ្ញុំសូម

បង្ហាញឯកសារមួយសន្លឹក គឺលេខ E លេខD-- សូមឲ្យសហការីខ្ញុំបង្ហាញផងមួយសន្លឹកម្ដងៗ។ D22/42.3 ជាភាសាអង់គ្លេស 002-- (សូមទោស) លេខ ERN ខ្មែរ 00279570 ជាភាសាបារាំង 00279568 ជាភាសាបារាំង 00752092 និងឯកសារមួយទៀត D22/43.2 ដែលមានលេខ ERN ភាសាខ្មែរ 00279543 ជាភាសាអង់គ្លេស 00279545 ជាភាសាបារាំង 00755585 យើងកត់សម្គាល់ឃើញថា--

[១៥:២៦:០០]

**ប្រធានអង្គជំនុំ៖**

ឈប់ៗសិន។ អញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

បាទសូមអរគុណលោកប្រធាន។ មេធាវី អាង ឧត្តម គឺថាគាត់ ថាគាត់លែងមានសំណួរចោទទៀតហើយអម្បាញ់មិញហ្នឹង។ អ៊ីចឹងគឺថាឥឡូវយើងគួរតែបង្ហាញ-- ខ្ញុំគិតថាគាត់ឈប់ អំមិញ គាត់ថាគាត់ឈប់មានសំណួរទៀតហើយ ស្រាប់តែឥឡូវមកបង្ហាញឯកសារអីទៀតអ៊ីចឹងខ្ញុំគិតថាគួរតែឈប់បង្ហាញឯកសារអីទៀតទៅ។

[១៥:២៦:៤១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតឲ្យការបង្ហាញឯកសារចុងក្រោយរបស់មេធាវីការពារក្ដី អៀង សារី ដោយមិនមានការតាំងសំណួរអ្វីដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះទៀតទេ។

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន។ ឯកសារ D22/43.2 និងឯកសារ D22/43.3 គឺបើយើងពិនិត្យមើលភិនភាគទឹកដៃសរសេរក៏ដូចគ្នាថ្ងៃ កាលបរិច្ឆេទនៃឯកសារក៏ដូចគ្នា ព័ត៌មានដូចគ្នាទាំងស្រុងតែម្ដងលើកលែងតែឈ្មោះមនុស្ស។ គឺនៅឯកសារ D22/43.2 ជារបស់លោក រម៉ាម យុន ត្រង់ឈ្មោះទីមួយគាត់ដាក់ រម៉ាម យុន ទីពីរដាក់ ក្លាន រ៉ិត។ ឯដោយឡែកឯកសារ D22/42.3 ត្រង់ឈ្មោះ ទីមួយគាត់ដាក់ ក្លាន រ៉ិត ទីពីរគាត់ដាក់ រម៉ាម យុន។ អានេះ ខ្ញុំគ្រាន់តែទាញចំណាប់អារម្មណ៍តុលាការថា មានការប្រុងប្រយ័ត្នក្នុងការធ្វើឯកសារនេះ តើអ្នកឆ្លើយនឹងនៅជាមួយគ្នា បានព័ត៌មានអីដូចគ្នាម្ល៉េះ។ ដូចគ្នាសឹងទាំងស្រុងទៅហើយ តើព័ត៌មានហ្នឹងចេញ ទោះជាសាក្សីអ្នកផ្ដិតមេដៃហ្នឹងបានផ្ដិតមែន ប៉ុន្តែចេញ

ពីឆន្ទៈ ពីចម្លើយពិតប្រាកដរបស់អ្នកឆ្លើយ ឬអត់? ដើម្បីជាឧទាហរណ៍ទៅអនាគត ប្រហែលជាអាចមានបញ្ហានេះទៀត យើងនឹងលើកយកមកពិចារណា។ អ៊ីចឹងបានន័យថានៅដំណាក់កាលសួរចម្លើយ ឬស៊ើបអង្កេតហ្នឹង ការសួរចម្លើយ ឬស៊ើបអង្កេតហ្នឹងអាចមានបញ្ហាអ៊ីចេះកើតឡើង។

អ៊ីចឹងសូមតុលាការមេត្តាចាប់អារម្មណ៍ផងទាន ហើយសូម បើមានបញ្ហានេះថ្ងៃក្រោយកើតឡើងទៀត ខ្ញុំនឹងលើកមកជូនទៀត។ នេះគ្រាន់តែសូមជម្រាបថា វា១ព័ត៌មាន ឯកសារ អ្នកធ្វើតាក់តែងដូចគ្នា ហើយអ្នកឆ្លើយអត់ចេះអក្សរអីដូចគ្នាអ៊ីចឹងបានន័យថា វា តើចម្លើយហ្នឹងចេញពីឆន្ទៈរបស់អ្នកឆ្លើយពិតប្រាកដ ឬអត់?

បាទ សូមអរគុណលោកប្រធាន។

[១៥:២៩:៣១]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញមេធាវីតំណាងនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីជាតិ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ អម្បាញ់មិញ ខ្ញុំមានបំណងនៅក្នុងការជំទាស់ទាក់ទងទៅនឹងការធ្វើអត្ថាធិប្បាយរបស់លោក អាង ឧត្តម ដែលជាមេធាវីបានសួរទៅលើលោក ក្លាន វ៉ុន អម្បាញ់មិញ ហើយបានលើកអំពីឯកសារផង ហើយលោកបានធ្វើការអធិប្បាយទៅលើឯកសារទាំងពីរនេះ។ ពេលនេះ ខ្ញុំបាទយល់ថា គឺជាពេលសម្រាប់សួរសំណួរមិនមែនជាពេលសម្រាប់ធ្វើការអត្ថាធិប្បាយ ឬក៏ធ្វើការសន្និដ្ឋានទេ ហើយសូមលោកប្រធានក្នុងករណីក្រោយៗសំណូមពរថា លោកប្រធានជួយធ្វើយ៉ាងណាកុំឲ្យមានការអធិប្បាយនៅក្នុងពេលធ្វើសំណួរ ដែលជាការសន្និដ្ឋានដែលនឹងត្រូវធ្វើនៅពេលក្រោយ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ទីមួយលោកមេធាវីជាភាគីដែលលោកមានភារកិច្ចក្នុងការតាមដាននូវការតាំងសំណួររបស់ភាគីម្ខាងទៀត ដើម្បីធ្វើការជំទាស់មុនពេលឆ្លើយ ថាសំណួរនឹងគួរតែជំទាស់ អង្គជំនុំជម្រះនឹងសម្រេចអំពីបញ្ហានោះ។ នេះជារឿងរបស់ភាគីដោយឡែកអង្គជំនុំជម្រះក៏មានភារកិច្ចនេះដែរ ប៉ុន្តែភារកិច្ចដោយឡែក ដោយសារភាគីមានការត្រួតពិនិត្យគ្នាទៅវិញទៅមកនៅក្នុងអំឡុងពេលពិភាក្សាដេញដោល។

[១៥:៣១:១៦]

បញ្ហាទីពីរ ឯកសារអម្បាញ់មិញនេះ គឺគេដាក់ដើម្បីធ្វើការសង្កេត ព្រោះជាផ្នែកមួយដែលគេយល់ឃើញថា មានប្រយោជន៍សម្រាប់កិច្ចការពាររបស់គេ។ ជាការពិតណាស់អង្គជំនុំជម្រះបានត្រៀមខ្លួនជាស្រេចក្នុងការដកចេញមិនឲ្យភាគីធ្វើសេចក្ដីសន្និដ្ឋានកណ្ដាលទីនេះឡើយ តែភាគីអាចធ្វើការកត់សម្គាល់នូវឯកសារភស្តុតាងដែលពាក់ព័ន្ធបាន។ ពីព្រោះដល់ពេលគេធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់នោះទើបអង្គជំនុំជម្រះអនុញ្ញាត។ អ៊ីចឹងហើយបានជា ពីម្សិលមិញអង្គជំនុំជម្រះបានជម្រាបជូនដល់ភាគីរួចហើយថា ការជំទាស់ដែលបានឆ្លើយរួចហើយ មិនអាចជំទាស់បានទេ។ ការជំទាស់រួមរបៀបនេះចំពោះការផ្ដល់សក្ខីកម្មរបស់សាក្សី អ្នកជំនាញ ឬដើមបណ្ដឹងរដ្ឋប្បវេណី ភាគីត្រូវទៅធ្វើនៅចុងបញ្ចប់នៃកិច្ចពិភាក្សាដេញដោល។

[១៥:៣២:៤៣]

ជាបន្តទៅនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅមេធាវីការពារក្ដី ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះដើមបណ្ដឹងរដ្ឋប្បវេណី ក្លាន រ៉ិត ប្រសិនបើមាន សូមអញ្ជើញ។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមគោរពអង្គសវនាការ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះក្នុងនាមដើម-- ក្នុងនាមអ្នកការពារលោក ខៀវ សំផន យើងខ្ញុំអត់មានសំណួរអីចំពោះលោក ក្លាន រ៉ិតទេ។ បាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការបង្ហាញជំហរចុងក្រោយនេះ ដែលវាខុសគ្នាឆ្ងាយពីជំហរដែលបានបង្ហាញកាលពីម្សិលមិញ។

អរគុណលោក ក្លាន រ៉ិត ដែលបានផ្ដល់សក្ខីកម្មចំពោះអង្គជំនុំជម្រះ ប៉ុន្តែមុននឹងបញ្ចប់អង្គជំនុំជម្រះសូមផ្ដល់វេទិកាទៅលោក ក្លាន រ៉ិត ដើម្បីមានឱកាសក្នុងការថ្លែងនូវសេចក្ដីទុក្ខសោកវេទនា ដែលលោកបានឆ្លងកាត់ ដោយសារអង្គហេតុទាំងឡាយដែលបានធ្វើការចោទប្រកាន់ចំពោះជនជាប់ចោទហើយត្រូវបានអង្គជំនុំជម្រះកំណត់យកមកធ្វើសវនាការនៅដំណាក់កាលដំបូងនេះ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។

[១៥:៣៤:៤៧]

**លោក ក្លាន វ៉ិត៖**

បាទខ្ញុំសូមឆ្លើយ ខ្ញុំជាមួយអ៊ំលោក ខៀវ សំផន ខ្ញុំអត់មានរឿងរ៉ាវនិយាយអីទេ។ ខ្ញុំអត់មានការនិយាយស្តី អត់មានឃើញមុខមាត់គាត់ទេ។ ឮតែគេថាលោក ខៀវ សំផន ប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

យើងមិនសួរជាក់លាក់ចំពោះលោក ខៀវ សំផន ទេ ចំពោះអង្គហេតុដែលបានចោទប្រកាន់ ហើយដែលបានលើកឡើងដែល ធ្វើការដេញដោលកន្លងមកនេះ ក្នុងនាមលោកជាដើមបណ្តឹងរដ្ឋប្បវេណី តើលោកមានបំណងសម្តែងនូវការទុក្ខសោករបស់លោក ដែលលោកបានឆ្លងកាត់បទពិសោធន៍នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យចំពោះមុខអង្គជំនុំជម្រះដែរឬទេ?

**លោក ក្លាន វ៉ិត៖**

ខ្ញុំអត់មានការចម្លើយទេ លោកប្រធាន។ ប៉ុន្តែអត់ស្តាប់ឮការងារអីទេ ឮតែគេថា គណៈភូមិភាគ លោកអ៊ំបួននាក់ហ្នឹងគណៈភូមិភាគ។ ខ្ញុំឮតែប៉ុណ្ណឹងទេ។ គេហៅអ៊ំ ខៀវ សំផនៗ ហ្នឹង ប៉ុណ្ណឹងឯង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណៗ លោក ក្លាន វ៉ិត ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញចូលមកផ្តល់សក្ខីកម្មតាមការកោះហៅរបស់អង្គជំនុំជម្រះ។ ឥឡូវនេះ ដំណើរការនៃការស្តាប់សក្ខីកម្មរបស់លោក ក្នុងនាមលោកជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះមុខអង្គជំនុំជម្រះ ឃើញថាចប់សព្វគ្រប់ហើយ អង្គជំនុំជម្រះអស់ មិនមានសំណួរអ្វីសួរលោកទៀតទេ។

[១៥:៣៦:៣៤]

ដូច្នេះ គឺលោកអាចវិលត្រឡប់ទៅលំនៅដ្ឋាន ឬក៏គោលដៅរបស់លោកដែលលោកចង់ទៅបានហើយ ប៉ុន្តែដោយសារលោកធ្វើដំណើរផ្លូវឆ្ងាយ ដែលត្រូវរៀបចំចាត់ចែងដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញនោះ ដូច្នេះគឺលោកអាចត្រឡប់ទៅវិញតាមរយៈការសម្របសម្រួលរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើម្បីបានវិលត្រឡប់ទៅលំនៅដ្ឋាន ឬក៏គោលដៅដែលលោកចង់ទៅបានហើយ។

ហើយដោយសារពេលវេលានៅសល់តិចតួច ដូច្នេះអង្គជំនុំជម្រះសម្រេចផ្អាកកិច្ចដំណើរការសវនាការត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ចាប់វេលាម៉ោងប្រាំបួនព្រឹក។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងបីនាក់ មកកាន់សាលសវនាការនេះនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោង

ប្រាំបួន។

សូមសម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:៣៧នាទី)*